រាជរដ្ឋាភិបាលកម្ពុជា
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សៀវភៅណែនាំ

# ស្តីពី

# ការលើកកម្ពស់សេវាសង្គមប្រកបដោយសមធម៌

ខែកក្កដា ឆ្នាំ២០១២

# មាតិកា

**ទំព័រ**


**សារតា** .......... i

*ផ្នែកទីមួយ ៖ តម្រង់ទិស*

**១. គោលវិធីវដ្តជីវិតនិងសារៈសំខាន់ នៃការវិនិយោគក្នុងវ័យដំបូង** .......... ១

១.១. គោលវិធីវដ្តជីវិត .......... ១

១.២. ការវិនិយោគក្នុងវ័យដំបូង .......... ២

១.៣. គោលវិធីចម្រុះទៅលើការអភិវឌ្ឍកុមារ .......... ២

១.៤. ហេតុអ្វីបានជាមានសេវាសង្គមប្រកបដោយសមធម៌? .......... ៣

១.៥. ជំនាញវិភាគពីតម្រូវការ បញ្ហា និងការឆ្លើយតបផ្សេងៗ .......... ៤

១.៦. មូលនិធិសមធម៌សុខភាព .......... ៥

១.៧. សៀវភៅអសយដ្ឋានសេវាកម្មសម្រាប់អ្នកដែលងាយរងគ្រោះ (២០១០) .......... ៥

**២. ផលប៉ះពាល់នៃគ្រោះមហន្តរាយទៅលើការអភិវឌ្ឍកុមារ** .......... ៧

២.១. ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ .......... ៧

២.២. គ្រោះមហន្តរាយអាចបង្អាក់ការអភិវឌ្ឍកុមារ .......... ៧

២.៣. សហគមន៍ងាយរងគ្រោះ .......... ៨

២.៤. សហគមន៍រឹងមាំ .......... ៨

២.៥. ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ .......... ៩

២.៦. ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ( តួនាទីរបស់ គ.ក.ន.ក) .......... ៩

**៣. តួនាទី និងភារកិច្ចរបស់ គ.ក.ន.ក** .......... ១១

៣.១. តួនាទីនិងភារកិច្ចរបស់ គ.ក.ន.ក .......... ១១

៣.២. ការចុះបញ្ជីអត្រានុកូលដ្ឋាន .......... ១១

**៤. ការប្រើប្រាស់ទិន្នន័យបង្កើនសមត្ថភាពកសាងផែនការ និងការចាត់អាទិភាព** .......... ១៣

៤.១. ឧបករណ៍កសាងផែនការនិងការធ្វើសេចក្ដីសម្រេចចិត្ត .......... ១៣

៤.២. ការរៀបចំ និងការចាត់ចែងកិច្ចប្រជុំឲ្យមានប្រសិទ្ធភាព ........ ១៧
**៥. ការកសាងផែនការថវិការផ្ដោតលើសមធម៌ និងការកៀរគរធនធាន** ........ ២៣
៥.១. សេចក្ដីណែនាំស្ដីពីការកសាងផែនការថវិកាផ្ដោតលើសមធម៌ ........ ២៣
៥.២. ការកៀរគរធនធាន ........ ៣៦
**៦. ការតាមដានត្រួតពិនិត្យការវាយតម្លៃនិងរបាយការណ៍** ........ ៣៧
៦.១. ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ ........ ៣៧
៦.២. ទម្រង់របាយការណ៍និងកំណត់ហេតុ ........ ៤៩
*ផ្នែកទីពីរ ៖ ការផ្ដោតស៊ីជម្រៅលើសមធម៌សង្គម*
**១. ការធ្វើការជាមួយសហគមន៍ដើម្បីត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការដោះស្រាយ** ........ ៥៩
១.១. ការប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ ........ ៥៩
១.២. គ្រោះមហន្តរាយអាចបង្អាក់ការអភិវឌ្ឍកុមារ ........ ៥៩
១.៣. សហគមន៍ងាយរងគ្រោះ ........ ៦០
១.៤. សហគមន៍ដែលរឹងមាំ ........ ៦០
១.៥. ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ ........ ៦០
១.៦. បញ្ជីប៉ាន់ប្រមាណបន្ទាន់ ........ ៦៦
**២. ការថែទាំកុមារនៅតាមគ្រួសារ និងយន្តការគាំទ្រសហគមន៍ តួនាទីរបស់ គ.ក.ន.ក** ........ ៦៨
**៣. ការប្រើប្រាស់ទិន្នន័យដើម្បីមានឥទ្ធិពលលើអ្នកដទៃ** ........ ៧១
៣.១. កំណត់គ្រួសារងាយរងគ្រោះ ........ ៧១
៣.២. ការវិភាគអ្នកពាក់ព័ន្ធ ........ ៧២
៣.៣. កាតស៊ូមតិដើម្បីសេវាសង្គមប្រកបដោយសមធម៌ ........ ៧២

# សារចារ

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) ត្រូវបានបង្កើតឡើងដើម្បីធ្វើជាជំនួយការឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល និងកិច្ចការផ្សេងៗទៀតទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ។

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) មានតួនាទីសំខាន់ៗដូចជា ៖ ផ្តល់អនុសាសន៍ស្វែងរកមតិគាំទ្រ សម្របសម្រួល ត្រួតពិនិត្យ និងរាយការណ៍អំពីបញ្ហាដែលទាក់ទង ស្ត្រី និងកុមារ ដើម្បីធានាថាពួកគេទទួលបាននូវសេវាកម្មសមស្របប្រកបដោយគុណភាពទាំងផ្នែក សេដ្ឋកិច្ច និងសង្គមកិច្ច។

គណៈកម្មាធិការនេះត្រូវសហការជាមួយភ្នាក់ងារផ្តល់សេវានានា (ដូចជា សាលារៀន មណ្ឌលសុខភាព មន្ត្រីសេវាសង្គម និងនគរបាល) ដើម្បីរៀបចំសកម្មភាពដូចជា ៖

- លើកទឹកចិត្តឱ្យមានតម្រូវការសេវាកម្ម និងលើកកម្ពស់ការអនុវត្តការថែរក្សាសុខភាពគ្រួសារ។ ឧទាហរណ៍ ៖ តាមរយៈការជំរុញឲ្យបំបៅកូនដោយទឹកដោះម្តាយ ការចាក់ថ្នាំបង្ការគ្រប់មុខ ការចុះបញ្ជីអត្រានុកូលដ្ឋាន ការរៀបចំយុទ្ធនាការចុះឈ្មោះចូលរៀន និងការផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងពីសុខភាពបន្តពូជ ការពន្យារកំណើត ការឆ្លងមេរោគអេដស៍ ការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។
- ការសម្របសម្រួលឲ្យគ្រួសាររងគ្រោះទទួលបានសេវាកម្ម។ ឧទាហរណ៍ ៖ តាមរយៈការចាត់ចែងឲ្យមានអ្នកផ្តល់សេវាដឹកជញ្ជូនស្ត្រីមានផ្ទៃពោះពីគ្រួសារក្រីក្រពីផ្ទះទៅពិនិត្យ និងសម្រាលកូននៅមណ្ឌលសុខភាព ឬការផ្តល់កង់ឱ្យកុមារនៅភូមិដាច់ស្រយាលដើម្បីជិះទៅសាលារៀន។
- ការគាំទ្រឱ្យទទួលបានទឹកស្អាតប្រើប្រាស់ និងកន្លែងលាងសម្អាតដៃ ដែលបានកែលម្អជាមួយសាប៊ូ និងសម្ភារៈអនាម័យ ក្នុងសាលារៀន និងមណ្ឌលសុខភាព។
- ការត្រួតពិនិត្យគុណភាពសេវានៅមូលដ្ឋាន។ ឧទាហរណ៍ ៖ ការចុះត្រួតពិនិត្យការងារតាមផ្ទះរបស់ក្រុមគាំទ្រសុខភាពភូមិ និងជំរុញឲ្យមានសមភាពយេនឌ័រក្នុងការកសាងផែនការភូមិ ឃុំ សង្កាត់ ។
- ធ្វើការជាមួយសហគមន៍ដើម្បីត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងដោះស្រាយបញ្ហាផ្សេងៗ។

សៀវភៅនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើបទពិសោធន៍ជោគជ័យរបស់ គ.ក.ន.ក នានា។ ការសិក្សាប៉ាន់ប្រមាណសមត្ថភាព គ.ក.ន.ក ដោយក្រសួងមហាផ្ទៃ និងយូនីសេហ្វ ឆ្នាំ២០០៩ ការប៉ាន់ប្រមាណតម្រូវការដែលធ្វើដោយក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី និងវីប៊ីអិនខេ បានកំណត់បញ្ហាអាទិភាពដែលស្ត្រី និងកុមារកំពុងជួបប្រទះ និងឆ្លុះបញ្ចាំងពីផលប៉ះពាល់នៃបញ្ហាទាំងនោះ ទៅលើស្ត្រី និងកុមារដែលមានភាពខុសៗគ្នាពីតំបន់មួយទៅតំបន់មួយទៀត។ ឧទាហរណ៍ នៅឆ្នាំ២០១១ មានខេត្តចំនួន១៨ ទទួលរងគ្រោះដោយទឹកជំនន់ធ្ងន់ធ្ងរ។ ទឹកជំនន់នេះបានប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ សុខភាព អាហារូបត្ថម្ភ និងការសិក្សារបស់សិស្ស។ ចំណែកនៅឯខេត្តកំពង់ស្ពឺវិញតែងតែជួបភាពរាំងស្ងួតជាញឹកញាប់ និងខ្វះទឹកស្អាតប្រើប្រាស់ ដែលនាំឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ និងអនាម័យ។ ហេតុការណ៍

នេះតម្រូវឲ្យសហគមន៍ទាំងនោះ ត្រូវបង្កើតផែនការត្រៀមទុកសម្រាប់សង្គ្រោះបន្ទាន់ ដើម្បីដោះស្រាយគ្រោះមហន្តរាយដែលអាចនឹងកើតឡើងនាពេលអនាគត។

ការប៉ាន់ប្រមាណនេះក៏បានរំលេចផងដែរថា បញ្ហាជាច្រើនដែលស្ត្រី និងកុមារកំពុងជួបប្រទះនោះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងភាពក្រីក្រ និងអសមធម៌នៅក្នុងសង្គម។ ឧទាហរណ៍ ៖ អត្រាស្លាប់នៃកុមារដែលមានអាយុក្រោម០៥ឆ្នាំ ដែលរស់នៅសហគមន៍ក្រីក្រ មានអត្រាខ្ពស់ជាងអត្រាស្លាប់នៃកុមារដែលមានអាយុក្រោម០៥ឆ្នាំរស់នៅក្នុងសហគមន៍អ្នកមាន។ ដូចនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែធានាថា ការកសាងផែនការសកម្មភាព និងថវិកាត្រូវតែឆ្លើយតបទៅនឹងបញ្ហាសមធម៌ឲ្យបានគ្រប់គ្រាន់។

ការប៉ាន់ប្រមាណនេះ ក៏បានរំលេចនូវផ្នែកកសាងសមត្ថភាពជាអាទិភាពនានាសម្រាប់ គ.ក.ន.ក ដែលទើបនឹងបង្កើតថ្មីដែរ។ ការកសាងសមត្ថភាពនោះ គឺផ្តោតទៅលើការបំពេញតួនាទីរបស់ គ.ក.ន.ក និងណែនាំតម្រង់ទិសដល់សមាជិកថ្មីអំពីការកសាងផែនការ ជំនាញចាត់ចែង ការស្វែងរកមតិគាំទ្រផ្អែកលើភស្តុតាងជាក់ស្តែង ជំនាញតស៊ូមតិ ជំនាញសម្របសម្រួល និងការប្រមូល និងវិភាគទិន្នន័យ ដើម្បីចាត់អាទិភាព និងកសាងផែនការថវិកា។

សៀវភៅណែនាំនេះត្រូវបានបែងចែកជាពីរផ្នែក ៖

***ផ្នែកទី១ ៖ តម្រង់ទិស***

នៅផ្នែកទី១នេះ គឺសម្រាប់បញ្ជាក់ប្រាប់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារដែលទើបបង្កើតថ្មី ឬគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារដែលមានសមាជិកផ្លាស់ប្តូរច្រើន។ ផ្នែកទី១នេះមានប្រធានបទ៦ដូចខាងក្រោម ៖

១. គោលវិធីវដ្តជីវិត និងសារៈសំខាន់នៃការវិនិយោគក្នុងវ័យដំបូង

២. ផលប៉ះពាល់នៃគ្រោះមហន្តរាយទៅលើការអភិវឌ្ឍកុមារ

៣. តួនាទី និងភារកិច្ចរបស់គ.ក.ន.ក

៤. ការប្រើប្រាស់ទិន្នន័យដើម្បីបង្កើនសមត្ថភាពកសាងផែនការ និងការចាត់អាទិភាព

៥. ការកសាងផែនការថវិកាផ្តោតលើសមធម៌ និងការកៀរគរធនធាន

៦. ការតាមដានត្រួតពិនិត្យការវាយតម្លៃ និងរបាយការណ៍

***ផ្នែកទី២ ៖ ការផ្តោតស៊ីជម្រៅលើសមធម៌សង្គម***

ផ្នែកទី២រៀបចំសម្រាប់គណៈកម្មាធិការដែលធ្វើការបានពី៦ខែទៅមួយឆ្នាំ និងសម្រាប់អ្នកដែលចង់យល់ដឹងបានស៊ីជម្រៅអំពីសេវាសង្គមប្រកបដោយសមធម៌ និងអ្នកដែលកំពុងធ្វើការអំពីរបៀបកំណត់ការគាំទ្រស្ត្រី និងកុមារងាយរងគ្រោះ ។ ផ្នែកទី២នេះមានប្រធានបទចំនួន៣គឺ ៖

១. កិច្ចសហការជាមួយសហគមន៍ដើម្បីត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងដោះស្រាយ

២. ការថែទាំកុមារនៅតាមគ្រួសារ និងយន្តការគាំទ្រសហគមន៍

៣. ការប្រើប្រាស់ទិន្នន័យដើម្បីមានឥទ្ធិពលលើអ្នកដទៃ។

# ផ្នែកទី១

# តម្រង់ទិស

# ១. គោលវិធីវដ្តជីវិត និងសារៈសំខាន់នៃការវិនិយោគ ក្នុងវ័យដំបូង

## ១.១. គោលវិធីវដ្តជីវិត

គោលវិធីវដ្តជីវិតមើលទៅលើដំណាក់កាលផ្សេងៗ នៃការអភិវឌ្ឍចាប់ពីការចាប់បដិសន្ធិនៅក្នុងផ្ទៃ (-៩ខែ) រហូតដល់ពេលចាប់កំណើតជាកុមារតូច បឋមវ័យ ពេញវ័យជំទង់ និងក្លាយជាមនុស្សពេញវ័យ ដើម្បីស្វែងយល់ពីបញ្ហានានា និងតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍនាដំណាក់កាលនីមួយៗ។

| *វដ្តនៃជីវិត* |
|---|
| ❑ ការអភិវឌ្ឍកុមារតូចពី -៩ខែ ដល់៥ឆ្នាំ<br>ក្នុងដំណាក់កាលនេះ ត្រូវយកចិត្តទុកដាក់ទៅលើការថែរក្សាគភ៌មុន និងក្រោយពេលសម្រាល ការសម្រាលកូនដោយសុវត្ថិភាព ការបំបៅកូនដោយទឹកដោះម្តាយ ការចុះបញ្ជីកំណើត និងអាហារូបត្ថម្ភ ការប្រកាន់ខ្ជាប់នូវអនាម័យដូចជាលាងដៃនឹងសាប៊ូ និងការប្រើប្រាស់បង្គន់អនាម័យ ការទទួលបានទឹកស្អាតប្រើប្រាស់ ការអប់រំឪពុកម្តាយ ការចាក់ថ្នាំបង្ការឲ្យបានគ្រប់ចំនួន ការទម្លាក់ ព្រូន ការអប់រំកុមារតូច(មត្តេយ្យ) ភាពយឺតយ៉ាវនៃការអភិវឌ្ឍ កិច្ចការពារកុមារ បង្កើតបរិស្ថានប្រកបដោយសុវត្ថិភាពសម្រាប់កុមារ (ទាំងនៅក្នុងផ្ទះ សាលារៀន និងនៅក្នុងសហគមន៍)។ |
| ❑ បឋមវ័យពី៦ ដល់១២ឆ្នាំ<br>ក្នុងដំណាក់កាលនេះ ត្រូវយកចិត្តទុកដាក់ទៅលើការចូលសាលារៀនរបស់កុមារ ការអនុវត្តអនាម័យ ដូចជាការលាងដៃនឹងសាប៊ូ ការប្រើប្រាស់បង្គន់អនាម័យ ការទទួលបានទឹកស្អាតប្រើប្រាស់នៅសាលារៀន សមត្ថភាពរៀនសូត្រ និងកិច្ចការពារកុមារ។ |
| ❑ វ័យជំទង់ពី១៣ ដល់១៨ឆ្នាំ<br>ក្នុងដំណាក់កាលនេះ ត្រូវយកចិត្តទុកដាក់ទៅលើអត្តសញ្ញាណរបស់បុគ្គល ការអភិវឌ្ឍទាំងផ្នែករាងកាយ និងសុខភាពផ្លូវភេទ (ការអប់រំសុខភាពបន្តពូជ) ការពិចារណាថា តើគួរធ្វើអ្វីក្នុងឆាកជីវិតរបស់ខ្លួន? ការឈប់រៀនដើម្បីស្វែងរកការងារធ្វើ (នៅជិតផ្ទះ ឬចំណាកស្រុកដើម្បីរកការងារធ្វើ) បទឧក្រិដ្ឋដែលបង្កដោយយុវជន និងការព្យាយាមសាកល្បងនូវអ្វីដែលថ្មី។ ឧទាហរណ៍ ការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន ការប្រឈមមុខនឹងការជួញដូរផ្លូវភេទ ជាពិសេសក្មេងស្រីជំទង់។ |
| ❑ ពេញវ័យ<br>ក្នុងដំណាក់កាលនេះ ត្រូវយកចិត្តទុកដាក់ទៅលើការរៀបអាពាហ៍ពិពាហ៍ ការចុះសំបុត្រអាពាហ៍ពិពាហ៍ ការពន្យារកំណើត ការសម្រេចចិត្តមានកូន (ទាក់ទងការថែទាំមុន និងក្រោយពេលសម្រាល) ការសម្រាកនៅមណ្ឌលសុខភាព អំពើហិង្សាក្នុងគ្រួសារ ភាពជាឪពុកម្តាយ និងបញ្ហាចាស់ជរា។ |

## ១.២. ការវិនិយោគក្នុងវ័យដំបូង

ពេលមានផ្ទៃពោះ និងក្រោយពេលសម្រាល និងក្នុងវ័យកុមារភាព៦ឆ្នាំដំបូង គឺជាពេលវេលាមួយដ៏មានសារៈសំខាន់បំផុតក្នុងការអភិវឌ្ឍរបស់កុមារ។ វាជាគ្រឹះដ៏សំខាន់មួយសម្រាប់សុខុមាលភាពផ្នែកកាយសម្បទា ផ្លូវអារម្មណ៍ ផ្លូវចិត្តសង្គម និងបញ្ញា។



កង្វះរបបអាហារ និងការផ្តល់អាហារមិនបានគ្រប់គ្រាន់ ការបំបៅដោះកូនមិនបានត្រឹមត្រូវ ឆ្លងជំងឺរ៉ាំរ៉ៃ និងកង្វះការយកចិត្តទុកដាក់ក្នុងដំណាក់កាលនេះនាំឲ្យប៉ះពាល់ដល់ការអភិវឌ្ឍពេញលេញរបស់កុមារ និងអាចមានផលប៉ះពាល់ជាអវិជ្ជមានថែមទៀតដល់កុមារនាពេលអនាគត ដូចជា បញ្ហាសុខភាពទន់ខ្សោយ អវិជ្ជា និងភាពក្រីក្រ ដែលនៅជាប់ជាមួយកុមាររហូតដល់ពេញវ័យ។ ការបង្ហាញពីកង្វះខាតដ៏សន្ធឹកសន្ធាប់នេះបង្កើនការលំបាកច្រើនឡើងៗ និងជាញឹកញាប់តែងទទួលផលអាក្រក់ដែលមិនអាចថយក្រោយបាន។

តាមរយៈការវិនិយោគ៦ឆ្នាំដំបូងនេះ កម្ពុជាអាចជំនះបានវដ្តនៃភាពក្រីក្រ (ដែលផ្សារភ្ជាប់ពីជំនាន់មួយទៅជំនាន់មួយទៀត) និងលើកកម្ពស់ការរីកចម្រើនប្រកបសមធម៌។ ពេលវេលាដ៏មានប្រសិទ្ធភាព និងជោគជ័យបំផុតដើម្បីការពារមិនឲ្យមានវិសមភាព គឺជាពេលកំពុងមានផ្ទៃពោះ និងវ័យដំបូងនៃជីវិតនេះឯង។ ការវិនិយោគនៅក្នុងវ័យដំបូង គឺជាកត្តាដែលធ្វើឲ្យមានសមភាពបំផុតក្នុងការកាត់បន្ថយនូវគម្លាតផ្នែកសេដ្ឋកិច្ច និងបង្ការការកើនឡើងនៃគម្លាតនេះ។

**គ.ក.ន.ក ដើរតួយ៉ាងសំខាន់ក្នុងការទទួលខុសត្រូវទៅលើ ៖**

ក. តម្រូវការរបស់ស្ត្រី និងកុមារ ព្រមទាំងជនដែលងាយរងគ្រោះ

ខ. ជំរុញឲ្យមានសេវាសង្គមប្រកបដោយសមធម៌ និងដោយគ្មានការរើសអើង

គ. ធានាឲ្យបានថាបញ្ហារបស់ស្ត្រី និងកុមារត្រូវបានយកចិត្តទុកដាក់យ៉ាងមាំទាំដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកផ្តល់សេវាផ្សេងៗទៀត។

## ១.៣. គោលវិធីចម្រុះនៅលើការអភិវឌ្ឍកុមារ

ការអភិវឌ្ឍកុមារបានទទួលស្គាល់ថា តម្រូវការផ្នែករាងកាយនៃសុខភាព អាហារូបត្ថម្ភ មិនអាចបំបែកចេញពីតម្រូវការខាងស្មារតី សង្គម និងអារម្មណ៍បានឡើយ។ ដូច្នេះការអភិវឌ្ឍកុមារទាមទារឲ្យមានការរៀបចំសកម្មភាពនានាដែលឆ្លើយតបទៅនឹងតម្រូវការរួមរបស់កុមារ និងធានាឲ្យបានថាកុមារមានសិទ្ធិទទួលបានការអភិវឌ្ឍផ្នែកសុខភាព អាហារូបត្ថម្ភ បញ្ញាស្មារតី អារម្មណ៍ ព្រមទាំងកិច្ចការពារផងដែរ។

ឧទាហរណ៍

- ម្តាយត្រូវទទួលបានសេវាពិនិត្យសុខភាពមុន និងក្រោយពេលសម្រាលកូន
- កុមារទទួលបានតម្រូវការខាងអាហារូបត្ថម្ភដោយការបំបៅកូនដោយទឹកដោះតែមួយមុខគត់ក្នុងអំឡុងពេល៦ខែដំបូង និងការផ្តល់អាហារបំប៉នផ្សេងៗបន្ទាប់ពី៦ខែ និងត្រួតពិនិត្យការឡើងទម្ងន់របស់កុមារ និងទៅទទួលសេវាសុខភាពដើម្បីទទួលបានថ្នាំជីវជាតិអាបន្ថែម និងថ្នាំទម្លាក់ព្រូន។

- កុមារគ្រប់រូបបានចាក់ថ្នាំបង្ការគ្រប់ចំនួន
- កុមារគ្រប់រូបលូតលាស់នៅក្នុងបរិយាកាសដែលមានការស្រឡាញ់ ការថែទាំ ការទំនាក់ទំនងប្រកបដោយការគាំទ្រ។

## គោលវិធីចម្រុះទៅលើការអភិវឌ្ឍកុមារ

គោលវិធីចម្រុះទៅលើការអភិវឌ្ឍកុមារ រៀបចំចាត់ចែងឲ្យមានសកម្មភាពនានាដែលអាចឆ្លើយតបនឹង**តម្រូវការរួមរបស់កុមារ**។




### ១.៤. ហេតុអ្វីបានជាត្រូវមានសេវាសង្គមប្រកបដោយសមធម៌?

សមធម៌ គឺផ្តោតទៅលើមូលដ្ឋាននៃភាពត្រឹមត្រូវ មិនលំអៀង និងយុត្តិធម៌ក្នុងសង្គម។ ឧទាហរណ៍សមធម៌ធានាថា ស្ត្រីគ្រប់រូបទទួលបានសេវាសុខភាពបន្តពូជ ព្រមទាំងព័ត៌មានសំខាន់ៗដែលទាក់ទងនឹងសុខភាព ទោះជាពួកគាត់ក្រីក្ររស់នៅតំបន់ឆ្ងាយដាច់ស្រយាល ឬជនជាតិដើមភាគតិចក្តី។

ភាពមិនមានសមធម៌ ឬអសមធម៌ សំដៅដល់គម្លាតនៃភាពខុសគ្នារវាងក្រុមប្រជាជននានា មិនទាក់ទងនឹងកត្តាជីវសាស្ត្រ តែជាភាពអយុត្តិធម៌ និងអាចចៀសវាងបាន។ ឧទាហរណ៍ គ្រួសារដែលក្រីក្របំផុតមានអត្រាក្មេងស្រីមានជំងឺក្រិន១៦%ខ្ពស់ជាងក្មេងប្រុស។

តាមការស្រាវជ្រាវពីបណ្តាប្រទេសនានាបានបង្ហាញថា ការផ្តោតលើសមធម៌បានពន្លឿនការរីកចម្រើនឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ផ្នែកសុខាភិបាលកាន់តែរហ័ស និងចំណាយកាន់តែមានប្រសិទ្ធភាពជាងដូចជា ៖

- កាត់បន្ថយអត្រាមរណភាពមាតា និងទារក
- កាត់បន្ថយជំងឺក្រិន (កុមារដែលមានកម្ពស់ទាបជាងអាយុ)
- លើកទឹកចិត្តឲ្យកុមារទាំងអស់បានចូលរៀនគ្រប់គ្នា
- បង្កើនវិធានការការពារការឆ្លងមេរោគអេដស៍ពីម្តាយទៅកូនឲ្យបានទាំងស្រុង
- កាត់បន្ថយគម្លាតរវាងក្រុមដែលត្រូវបានគេយកចិត្តទុកដាក់ច្រើន និងក្រុមដែលគេយកចិត្តទុកដាក់តិចបំផុត។

ចំណូលគ្រួសារទាបក៏អាចជាឫសគល់នៃមូលហេតុដែលនាំឱ្យកុមារខ្វះអាហារូបត្ថម្ភ និងជាកត្តាកំណត់ភាពមិនមានសមធម៌ដ៏សំខាន់មួយផងដែរ។ ក្រាហ្វិកខាងក្រោមបានបង្ហាញថា អត្រាកុមារខ្វះជាតិដែក មានអត្រាខ្ពស់ជាងគេបំផុតចំពោះកុមារដែលរស់ក្នុងគ្រួសារក្រីក្រ ហើយអត្រាកុមារក្រិនមានអត្រាខ្ពស់ជាងគេបំផុតចំពោះកុមារដែលរស់នៅក្នុងគ្រួសារក្រីក្រខ្លាំង។ ដូច្នេះភាពក្រីក្រខ្លាំង និងចំណូលគ្រួសារទាប មានឥទ្ធិពលផ្ទាល់ទៅលើការអភិវឌ្ឍរបស់កុមារ។

កត្តាសំខាន់ៗ ដែលនាំឲ្យមិនមានសមធម៌មានដូចជា ការឡើងថ្លៃតម្លៃចំណីអាហារ និងប្រេងឥន្ធនៈ ចំណាកស្រុក នគរូបនីយកម្ម និងគ្រោះមហន្តរាយធម្មជាតិ។ ការផ្តោតទៅលើសមធម៌អាចជួយឲ្យគ្រួសារក្រីក្រកាត់បន្ថយចំណាយបាន។




## ១.៥. ជំនាញវិភាគពីតម្រូវការបញ្ហា និងការឆ្លើយតបផ្សេងៗ

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) នឹងមានជំនាញវិភាគពីតម្រូវការ និងបញ្ហានៃដំណាក់កាលនីមួយៗនៃវដ្តជីវិត។ គ.ក.ន.ក នឹងវិភាគពីការឆ្លើយតបដ៏សមរម្យមួយដើម្បីជួយសហគមន៍ក្នុងការដោះស្រាយបញ្ហា និងជួយធ្វើឲ្យប្រសើរឡើងនូវស្ថានភាពវិបត្តិផ្សេងៗដែលជះឥទ្ធិពលដល់សមធម៌សម្រាប់ស្ត្រី និងកុមារព្រមទាំងជនងាយរងគ្រោះប្រកបដោយសមធម៌ផងដែរ។ ជាពិសេសនៅពេលដែល គ.ក.ន.ក បានមើលឃើញពីបញ្ហា តម្រូវការ និងការឆ្លើយតបសមស្របហើយសមាជិក គ.ក.ន.ក នឹងលើកបញ្ហាចាត់អាទិភាពបញ្ចូលទៅក្នុងការប្រជុំប្រចាំខែ ក៏ដូចជាបញ្ចូលទៅក្នុងផែនការសកម្មភាព ព្រមទាំងធ្វើការសម្រេចចិត្តថា តើត្រូវធ្វើផែនការអំពីសកម្មភាពណាខ្លះដើម្បីឆ្លើយតបទៅនឹងស្ថានភាពនោះ?

## ១.៦. មូលនិធិសមធម៌សុខភាព

សារៈប្រយោជន៍ចម្បងនៃមូលនិធិសមធម៌សុខភាពនេះ គឺធ្វើឲ្យជីវភាពរស់នៅរបស់គ្រួសារក្រីក្របានប្រសើរឡើង ដោយផ្តល់ឲ្យពួកគាត់នូវគុណភាពសេវាសុខភាពដោយមិនបាច់បង់ប្រាក់។ ប្រសិនបើមិនមានមូលនិធិសមធម៌សុខភាពនោះទេ ពួកគាត់ប្រាកដជាមានភាពលំបាកយ៉ាងខ្លាំងក្នុងការស្វែងរកប្រាក់មកព្យាបាលនៅពេលដែលសមាជិកណាម្នាក់នៅក្នុងគ្រួសារក្រីក្រមានជំងឺ ។ ប្រសិនបើពួកគាត់មិនមានប្រាក់នោះ ពួកគាត់នឹងមិនយកអ្នកជំងឺទៅមណ្ឌលសុខភាពទេ។ មានពេលខ្លះអ្នកជំងឺឈឺធ្ងន់បានបង្ខំឲ្យគ្រួសារលក់ដី គោ ក្របី និងទ្រព្យសម្បត្តិផ្សេងៗដែលពួកគាត់មាន ដែលធ្វើឲ្យគាត់កាន់តែធ្លាក់ខ្លួនក្រទៅៗ។

មូលនិធិសមធម៌សុខភាព គឺជាយន្តការហិរញ្ញវត្ថុខាងផ្នែកតម្រូវការដើម្បីធ្វើឲ្យប្រជាពលរដ្ឋក្រីក្រទទួលបានសេវាសុខភាពប្រកបដោយសមធម៌កាន់តែប្រសើរឡើង។ មូលនិធិសមធម៌សុខភាពប្រើសម្រាប់បង់ថ្លៃព្យាបាលអ្នកក្រីក្រនៅពេលដែលពួកគាត់ចូលទៅរកសេវាព្យាបាលនៅក្នុងមន្ទីរពេទ្យ (កញ្ចប់បន្ថែមនៃសកម្មភាពសេវាសុខភាពផ្សេងៗ) នឹងបង់ថ្លៃធ្វើដំណើរ និងថ្លៃម្ហូបអាហារផ្សេងៗ។ អ្នកទទួលផលនានាត្រូវបានកំណត់ដោយយោងទៅតាមលក្ខណៈវិនិច្ឆ័យដែលអាចទទួលយកបាន ទាំងនៅសហគមន៍មានចំណាត់ថ្នាក់អត្តសញ្ញាណគ្រួសារក្រីក្រ នៅមណ្ឌលសុខភាព និងតាមរយៈការធ្វើបទសម្ភាសន៍។

**ប្រភព ៖** ការអនុវត្តគោលការណ៍ណែនាំអំពីមូលនិធិសមធម៌សុខភាពក្រសួងសុខាភិបាល (ខែមករា ឆ្នាំ២០០៩)

### មូលនិធិសមធម៌សុខភាព

- មូលនិធិសមធម៌សុខភាពចំណាយទៅលើមន្ទីរពេទ្យ និងមណ្ឌលសុខភាពនានាមួយចំនួន ដើម្បីផ្តល់នូវការថែរក្សាសុខភាពទៅដល់គ្រួសារក្រីក្រ
- ក្នុងការធ្វើសហប្រតិបត្តិការនៅមន្ទីរពេទ្យ និងមណ្ឌលសុខភាពនានា គ្រួសារក្រីក្រ មិនបាច់បង់ប្រាក់សម្រាប់សេវានានាក្នុងការថែរក្សាសុខភាពឡើយ
- មូលនិធិសមធម៌ក៏ត្រូវបង់ថ្លៃធ្វើដំណើរ និងថ្លៃម្ហូបអាហារសម្រាប់គ្រួសារក្រីក្រ

21

## ១.៧. សៀវភៅអាសយដ្ឋានសេវាកម្មសម្រាប់ជនដែលងាយរងគ្រោះ ឆ្នាំ២០១០

សៀវភៅអាសយដ្ឋានសេវាកម្មសម្រាប់ជនដែលងាយរងគ្រោះឆ្នាំ២០១០ បានបោះពុម្ពផ្សាយដោយអង្គការមិនមែនរដ្ឋាភិបាលមួយឈ្មោះថា អង្គការចែករំលែកបទពិសោធន៍ដើម្បីសម្របទៅតាមការអភិវឌ្ឍន៍ (SEAD) ដោយបានធ្វើកិច្ចសហការជាមួយអង្គការយូនីសេហ្វ និងក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ព័ត៌មានក្នុងសៀវភៅនេះ ជួយយ៉ាងសំខាន់ទៅដល់ប្រជាជនដែលងាយរងគ្រោះក្នុងការស្វែងរកសេវាកម្មសំខាន់នានា។ ការបោះពុម្ពសៀវភៅនេះ មានបំណងផ្តល់ជូននូវអាសយដ្ឋាន និងលេខទូរស័ព្ទទាក់ទងដែលងាយស្រួលអាចទៅរកសេវាជាច្រើន ដូចជា ថែទាំសុខភាព គាំទ្រចិត្តសាស្ត្រ វគ្គបណ្តុះបណ្តាល និងអប់រំការស្វែងរកមតិគាំទ្រជាជំនួយផ្នែកសិទ្ធិមនុស្ស និងការបង្កើនប្រាក់ចំណូល។ល។

ប្រសិនបើលោកអ្នកកំពុងស្វែងរកសេវាកម្មណាមួយនៅក្នុងខេត្តដែលលោកអ្នករស់នៅ សូមចូលទៅកាន់ទំព័រឈ្មោះខេត្តរបស់លោកអ្នក ដោយស្វែងរកតាមលំដាប់ឈ្មោះអក្សរនៃស្ថាប័ន។ សម្រាប់ខេត្តនីមួយៗ លោកអ្នកនឹងឃើញចំណាត់ថ្នាក់សេវាកម្ម និងចំណាត់ថ្នាក់សេវាកម្មរងតាមលំដាប់ ។




( *សៀវភៅអាសយដ្ឋានសេវាកម្មសម្រាប់អ្នកដែលងាយរងគ្រោះ* )

លោកអ្នកអាចទាញយកឯកសារណាមួយដោយផ្ទាល់ដោយចុចទៅលើឈ្មោះខេត្ត។ លោកអ្នកអាចទាញយកឯកសារច្រើនដោយគ្រាន់តែជ្រើសរើស *ប្រអប់* ផ្សេងៗគ្នាមួយចំនួន រួចចុចលើពាក្យ "Continue" ដែលឋិតនៅផ្នែកខាងក្រោមនៃទំព័រនេះ។

**ឧទាហរណ៍ ៖** ការស្វែងរកសេវាកម្មសម្រាប់ក្មេងពិការនៅក្នុងខេត្តកំពង់ឆ្នាំង

## អង្គការជនពិការកម្ពុជា

អង្គការក្នុងស្រុកផ្សព្វផ្សាយសិទ្ធិរបស់អ្នកពិការ ផ្តល់ភាពអង់អាចដល់ជនពិការ ផ្តល់ការតស៊ូមតិជាមួយនឹងស្ថាប័នពាក់ព័ន្ធ និងការពារពាល់ការរំលោភបំពានមកលើជនពិការ រួមទាំងបញ្ចូលនូវវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ ៖

- ភូមិត្នង ឃុំអូរឫស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង
- ទូរស័ព្ទលេខ ០១៧ ២៥០ ៣១៣

# ២. ផលប៉ះពាល់នៃគ្រោះមហន្តរាយទៅលើការអភិវឌ្ឍកុមារ

## ២.១. ការប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជាធ្វើឲ្យមានបម្រែបម្រួលមួយចំនួនដូចជា ៖

- ការកើនឡើងនូវកំដៅ
- ការប្រែប្រួលពេលវេលា និងថេរវេលានៃរដូវកាល (រដូវភ្លៀងមានរយៈពេលខ្លី ចំណែកឯរដូវក្ដៅមានរយៈពេលវែង)
- ការកើនឡើងជាញឹកញាប់នៃទឹកជំនន់ និងភាពរាំងស្ងួត
- កម្រិតទឹកសមុទ្រកើនឡើងនៅតំបន់ឆ្នេរសមុទ្រ។

ការប្រែប្រួលអាកាសធាតុបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្ថានភាពនៃការរស់នៅ និងជីវភាពរបស់ប្រជាពលរដ្ឋ ជាពិសេសទៅលើស្ត្រី និងកុមារ ដែលបញ្ហាទាំងនេះតម្រូវឱ្យ គ.ក.ន.ក ត្រូវត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងឆ្លើយតបឲ្យបានទាន់ពេល និងទទួលបានប្រសិទ្ធភាពខ្ពស់។

គ្រោះមហន្តរាយសំដៅទៅលើស្ថានភាពណាមួយដែលគំរាមកំហែងជីវិត និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ដែលតម្រូវឲ្យមានសកម្មភាពការពារបន្ថែមទៀតដើម្បីថែរក្សា ការពារ និងធានាអាយុជីវិតរបស់ពួកគេ។ គ្រោះមហន្តរាយអាចកើតឡើងភ្លាមៗ ឬមិនបានរំពឹងទុកជាមុន ឬក៏កើតឡើងយឺតៗ ហើយស្ថានភាពនោះបណ្ដាលឲ្យមានគ្រោះថ្នាក់រហូតដល់បាត់បង់ជីវិត បំផ្លាញទ្រព្យសម្បត្តិ និងបង្អាក់ដល់សកម្មភាពនានាដល់បុគ្គលគ្រួសារ ឬសហគមន៍ដែលទាមទារឲ្យមានការប្រុងប្រយ័ត្ន និងស្វែងរកដំណោះស្រាយភ្លាមៗចំពោះគ្រោះមហន្តរាយនោះ។ គ្រោះមហន្តរាយអាចជាទឹកជំនន់ ភ្លើងឆេះផ្ទះ ភាពរាំងស្ងួត។ល។

## ២.២. គ្រោះមហន្តរាយអាចបង្អាក់ការអភិវឌ្ឍកុមារ

កុមារត្រូវទទួលរងបទពិសោធន៍អំពីគ្រោះមហន្តរាយខុសគ្នាពីមនុស្សពេញវ័យពីព្រោះ ៖

- នៅក្នុងវ័យដំបូងរបស់កុមារ វាជះឥទ្ធិពលផ្ទាល់ទៅដល់ការអភិវឌ្ឍផ្នែកកាយសម្បទា បញ្ញា ស្មារតីអារម្មណ៍ និងផ្នែកសង្គម
- គ្រោះមហន្តរាយអាចនាំឲ្យមានការព្រាត់ប្រាស់ក្រុមគ្រួសារ បាត់បង់សមាជិកគ្រួសារ។ ពួកគេមានអាម្មណ៍ត្រូវគេបោះបង់ និងអាចមានហិង្សាក្នុងចិត្ត
- គ្រោះមហន្តរាយងាយប៉ះពាល់ដល់កាយសម្បទារបស់កុមារ ដូចជា ពួកគេងាយឆ្លងជំងឺផ្សេងៗ
- គ្រោះមហន្តរាយអាចប៉ះពាល់ទៅដល់ការអប់រំរបស់កុមារ ដូចជា មិនអាចទៅសាលារៀនបាន
- ក្នុងករណីដែលមានអសុន្តិសុខស្បៀង ឬភាពរាំងស្ងួត កុមារជាច្រើន ជាពិសេសកុមារី បានបោះបង់ចោលការសិក្សា។

## ២.៣. សហគមន៍ងាយរងគ្រោះ

សហគមន៍មួយចំនួនងាយនឹងទទួលភាពរងគ្រោះជាងសហគមន៍ឯទៀត។ ភាពងាយរងគ្រោះនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងភាពក្រីក្រ និងភាពនៅដាច់ឆ្ងាយពីសង្គម។ ភាពងាយរងគ្រោះមានធាតុផ្សំពីរគឺ ៖

ក. **ហានិភ័យ** ៖ ដូចជាទឹកជំនន់ វិបត្តិសេដ្ឋកិច្ច ការប្រមូលផលមិនបាន សង្គ្រាម ភាពអត់ការងារធ្វើ និងជំងឺធ្ងន់ផ្សេងៗ។

ខ. **សមត្ថភាព** ៖ សមត្ថភាពឆ្លើយតប និងសមត្ថភាពសម្របខ្លួននៅពេលដែលជួបគ្រោះមហន្តរាយ។

**សញ្ញាណខ្លះៗនៃការកើនឡើងនូវភាពតានតឹងផ្លូវចិត្ត ៖**

- ប្រើប្រាស់គ្រឿងស្រវឹង និងថ្នាំញៀន
- ខឹង (ឆាប់ផ្ទុះកំហឹង)
- នៅដាច់ឆ្ងាយពីសង្គម
- មានការថប់អារម្មណ៍ និងបាក់ទឹកចិត្ត
- សម្ព័ន្ធភាពប្រេះឆា
- ខ្វះការយកចិត្តទុកដាក់លើការរៀនសូត្រ ការងារ និងលទ្ធផលការងារធ្លាក់ចុះ
- មានជំងឺរ៉ាំរ៉ៃ រោគសញ្ញាមិនច្បាស់លាស់ ឬមូលហេតុមិនគ្រប់គ្រាន់។

## ២.៤. សហគមន៍ដែលរឹងមាំ

សហគមន៍រឹងមាំ គឺជាសមត្ថភាពនៃប្រព័ន្ធមួយ ដូចជាសហគមន៍ ឬសង្គមក្នុងការសម្របខ្លួនឲ្យត្រឡប់មកដំណើរការល្អឡើងវិញបន្ទាប់ពីជួបគ្រោះមហន្តរាយណាមួយ។ នេះមានន័យថាសហគមន៍នោះ អាចបង្កើនសមត្ថភាពរបស់ខ្លួនតាមរយៈគ្រោះមហន្តរាយពីអតីតកាល និងសម្រាប់ការការពារពេលអនាគត និងធ្វើឱ្យប្រសើរឡើងនូវវិធានការកាត់បន្ថយហានិភ័យ។

**សហគមន៍ខ្លះមានភាពរឹងមាំដោយសារ ៖**

- ស៊ាំទៅនឹងភាពតក់ស្លុតដែលកើតឡើង ហើយសហគមន៍នៅតែដំណើរការការងាររបស់ខ្លួនបានដដែល
- អាចរៀបចំចាត់ចែង និងដោះស្រាយបានដោយខ្លួនឯងនៅពេលដែលសហគមន៍ជួបវិបត្តិ
- មានជំនាញនិងធនធាន ដើម្បីសង្គ្រោះជីវិតដោយខ្លួនឯង។

**សហគមន៍ដែលរឹងមាំគឺជាសហគមន៍ដែល ៖**

- គាំទ្រ និងពង្រីកការប្រាស្រ័យទាក់ទង និងភាពសុខដុមក្នុងសង្គម
- ពង្រឹងការជួយគ្នាក្នុងសហគមន៍ និងអ្នកជិតខាង ឧទាហរណ៍ ក្រុមជួយខ្លួនឯង
- ពង្រឹងបន្ថែមលើចំណុចខ្លាំង មិនមែនចំណុចខ្សោយ
- លើកកម្ពស់ការចូលរួមរៀបចំខ្លួនឯង និងភាពជាម្ចាស់
- ប្រើប្រាស់ធនធាននៅក្នុងសហគមន៍ ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយ និងកាត់បន្ថយផលប៉ះពាល់នោះ។

## ២.៥. ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់

សហគមន៍មួយដែលរឹងមាំ គឺជាសហគមន៍ដែលធ្វើការរួមគ្នាយ៉ាងសស្រាក់សស្រាំ ដើម្បីរៀបចំនូវផែនការប្រតិបត្តិមួយ ដែលត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយ ដោយ៖

- កំណត់រកតំបន់ដែលងាយរងផលប៉ះពាល់ពីគ្រោះមហន្តរាយ។ ឧទាហរណ៍ តំបន់ទំនាបជិតស្ទឹងទន្លេ និងតំបន់ងាយរងគ្រោះដោយទឹកជំនន់
- កំណត់រកតំបន់គ្រោះថ្នាក់ (hotspot) ដែលអាចដាក់សញ្ញាគ្រោះថ្នាក់។ ឧទាហរណ៍ ចម្ការ មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- កំណត់រកការគំរាមកំហែង ឬស្ថានភាពធ្ងន់ធ្ងរណាមួយដែលគំរាមកំហែងដល់ស្ត្រី និងកុមារ (សិស្សមត្តេយ្យ និងសិស្សបឋមសិក្សាត្រឡប់មកផ្ទះវិញនៅពេលមានទឹកជំនន់ ស្ត្រីមានផ្ទៃពោះ ត្រូវសម្រាលនៅរដូវភ្លៀង)
- លើកកម្ពស់ឲ្យមានការពិភាក្សា និងការសម្រេចចិត្តអំពីកម្រិតនៃភាពចាំបាច់ និងកម្រិតអប្បបរមាចំពោះអ្វីដែលបានត្រៀម
- ធានាថាគ្រប់អ្នកពាក់ព័ន្ធទាំងអស់យល់ដឹងពីការងារចម្បង និងការទទួលខុសត្រូវរបស់ខ្លួនក្នុងពេលមានគ្រោះមហន្តរាយ (តើនរណានឹងទទួលខុសត្រូវលើការងារអ្វី?) ព្រមទាំងព្រមព្រៀងលើយន្តការសម្របសម្រួលដើម្បីធានាពីលំហូរនៃការប្រាស្រ័យទាក់ទង
- កំណត់តម្រូវការ និងកសាងសមត្ថភាពសមាជិក គ.ក.ន.ក និងអ្នកពាក់ព័ន្ធនានា។ ការធ្វើឲ្យរួចរាល់របៀបនេះ គឺធ្វើឲ្យពួកគាត់អាចជួយសហគមន៍បាននៅពេលដែលត្រូវធ្វើការសង្គ្រោះបន្ទាន់
- កំណត់អ្វីដែលត្រូវធ្វើក្នុងការរៀបចំសម្រាប់ការសង្គ្រោះបន្ទាន់ (ឧទាហរណ៍ ត្រៀមបម្រុងទីទួលសុវត្ថិភាពសម្រាប់ជម្លៀសប្រជាពលរដ្ឋ) និង
- កំណត់ថា តើអ្នកណាទទួលខុសត្រូវអ្វី ដែលត្រូវត្រៀមបម្រុង និងធ្វើនៅពេលណា?

## ២.៦. ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ (*តួនាទីរបស់ គ.ក.ន.ក*)



គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គ.ក.ន.ក) នៅឃុំអំពិល បានបង្កើតឡើងនៅឆ្នាំ២០១០។ ចាប់តាំងពីពេលនោះមកសមាជិក គ.ក.ន.ក បានដើរតួយ៉ាងសំខាន់រួមដៃគ្នាដោះស្រាយតម្រូវការស្ត្រី និងកុមារងាយរងគ្រោះបំផុត។ នៅក្នុងឆ្នាំ២០១១ មានទឹកជំនន់យ៉ាងធំមួយបានប៉ះពាល់ដល់ស្រុកជាច្រើននៅភាគពាយព្យនៃប្រទេសកម្ពុជា។

គ.ក.ន.ក ឃុំអំពិល បានទុកការងារប្រចាំថ្ងៃរបស់ពួកគាត់មួយអន្លើសិន ហើយចាប់ផ្តើមធ្វើការប៉ាន់ប្រមាណតម្រូវការបន្ទាន់របស់សហគមន៍ដែលរងគ្រោះដោយទឹកជំនន់ក្នុងរយៈពេល៤៨ម៉ោង ទៅ៧២ម៉ោងដំបូង។ តាមរយៈការប្រើប្រាស់បញ្ជីដែលរៀបចំរួចស្រេចនោះ ក្រុមការងារប្រមូលបានព័ត៌មានដ៏មានប្រយោជន៍ជាច្រើន ហើយ គ.ក.ន.ក បានប្រើប្រាស់ព័ត៌មានទាំងនោះ ដើម្បីកៀរគរ

ប្រជាពលរដ្ឋ និងធនធានផ្សេងៗ។ ឧទាហរណ៍ ក្រុមប្រឹក្សាឃុំបានរៀបចំកិច្ចប្រជុំជាមួយនគរបាលប្រចាំមូលដ្ឋាន និងក្រុមសហគមន៍នេសាទដើម្បីត្រៀមទប់ទល់ទៅនឹងគ្រោះទឹកជំនន់។ ពួកគាត់បានរៀបចំសម្ភារៈផ្គត់ផ្គង់ និងទូក ដើម្បីផ្តល់សម្ភារៈផ្គត់ផ្គង់ទាំងនោះទៅឱ្យគ្រួសារដែលជាប់គាំងដោយសារទឹកជំនន់។ ជារៀងរាល់ថ្ងៃ គ.ក.ន.ក ធ្វើការជាមួយនគរបាលដើម្បីត្រួតពិនិត្យស្ថានភាពតាមហេតុការណ៍។ គ.ក.ន.ក បានជិះទូកទៅសួរសុខទុក្ខប្រជាជននៅទីនោះ។ នៅពេលដែលពួកគាត់ឆ្លងកាត់ប្រទះឃើញគ្រួសារដែលទទួលរងការលិចផ្ទះសម្បែង ពួកគាត់បានជួយជម្លៀសគ្រួសារទាំងនោះមកកាន់ទីទួលសុវត្ថិភាព ថែមទាំងដឹកជញ្ជូនសត្វពាហនៈ និងចំបើងដែលជាចំណីវាផងដែរ។ មិនតែប៉ុណ្ណោះ គ.ក.ន.ក បានសហការជាមួយនគរបាលដើម្បីការពារទ្រព្យសម្បត្តិ និងផ្ទះសម្បែងរបស់ប្រជាពលរដ្ឋ ឲ្យមានសុវត្ថិភាពទៀតផង។ ពួកគាត់ក៏បានតាមដាននូវលំហូរព័ត៌មានរបស់សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងៗផងដែរ (តាមរយៈអាយកូម ការស្តាប់វិទ្យុ និងការមើលទូរទស្សន៍)។ ពួកគាត់បានរាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក និងខេត្ត ព្រមទាំងបុគ្គលិកមណ្ឌលសុខភាព អប់រំ និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀតដែលមានវត្តមាននៅក្នុងខេត្តនេះ។ ការកៀរគរនោះបានទទួលការឆ្លើយតបភ្លាមៗ នូវជំនួយផ្សេងៗដូចជា ស្បៀង ធុងទឹក ធុងចម្រោះទឹក សាប៊ូដុំ និងសម្ភារៈសម្រាប់សង់ជម្រកមួយចំនួនទៀត។ ក្រុមគ្រូពេទ្យបានរៀបចំសេវាគាំទ្រសុខភាពចល័តជួយប្រជាពលរដ្ឋដែលត្រូវការជំនួយចាំបាច់ (ការរក្សាសុខភាព ឬថ្នាំសង្កូវ ផ្សេងៗ)។ លើសពីនេះទៀត ពួកគាត់បានផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើស្ត្រីមានផ្ទៃពោះ កុមារតូច ជនពិការ និងជនចាស់ជរា។ ក្រុមគ្រូពេទ្យក៏បានធ្វើការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់ដោយពស់ចឹក ពីវិធានការការពារប្រឆាំងនឹងគ្រោះថ្នាក់មួយចំនួន ដូចជា ជំងឺរាករូស រាកមួល គ្រុនចាញ់ និងគ្រុនឈាមផងដែរ។ ការផ្តល់ដំបូន្មានដ៏មានតម្លៃទាក់ទងទៅនឹងសារៈសំខាន់នៃការទទួលបានទឹកស្អាត (ដោយការដាំទឹកឲ្យពុះ ចម្រោះទឹក និងដាក់ថ្នាំក្លរ៉ាមីន) ការប្រើប្រាស់បង្គន់អនាម័យ និងការលាងដៃនឹងសាប៊ូនៅមុនពេលទទួលទានអាហារ មុនពេលរៀបចំអាហារ បន្ទាប់ពីចេញពីបង្គន់ ប៉ះសត្វ និងលាងគូថឲ្យកុមារ។ល។ ការងារទាំងនេះបានទទួលជោគជ័យជាស្ថាពរ ក្រោមកិច្ចសហការជាមួយស្ថាប័ន និងអង្គការផ្សេងៗមួយចំនួន (រួមទាំងអង្គការជនពិការផងដែរ)។



ចំណុចសំខាន់មួយទៀតនោះគឺ បន្ទាប់ពីទឹកជំនន់បានស្រកចុះទៅវិញ សមាជិក គ.ក.ន.ក បានធ្វើការឆ្លុះបញ្ចាំងទៅលើបទពិសោធន៍ និងអ្វីដែលពួកគាត់បានរៀនសូត្រពីបទពិសោធន៍នោះ។ បន្ទាប់មកពួកគាត់បានរៀបចំផែនការត្រៀមបម្រុងដើម្បីឆ្លើយតបទៅនឹងគ្រោះអាសន្នក្នុងការជួយឲ្យការងារពួកគាត់កាន់តែមានប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ក្នុងករណីវាកើតឡើងម្តងទៀត។ ផែនការរបស់ពួកគាត់រួមមាន សកម្មភាពមួយចំនួនដែលត្រូវធ្វើក្នុងករណីដែលកើតមានគ្រោះទឹកជំនន់ម្តងទៀត ឬក្នុងករណីមានគ្រោះរាំងស្ងួតធ្ងន់ធ្ងរ។

# ៣. តួនាទី និងភារកិច្ចរបស់ គ.ក.ន.ក

## ៣.១. តួនាទី និងភារកិច្ចរបស់ គ.ក.ន.ក

តួនាទី និងភារកិច្ចចម្បងរបស់ គ.ក.ន.ក មានដូចខាងក្រោម ៖

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការប្រមូល វិភាគព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងបញ្ហា និងតម្រូវការរបស់នារី និងកុមារដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ ក.គ.ន.ក ដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ អនុម័ត
- ផ្តល់ប្រឹក្សាយោបល់ និងជួយក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ចំពោះការងារពាក់ព័ន្ធកិច្ចការនារី និងកុមារនៅឃុំ សង្កាត់
- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យយល់ដឹងអំពីច្បាប់ គោលនយោបាយនានារបស់រដ្ឋពាក់ព័ន្ធនឹងសិទ្ធិនារី និងកុមារនៅឃុំ សង្កាត់ និងបំផុសចលនាសហគមន៍ ការចុះបញ្ជីអត្រានុកូលដ្ឋាន កិច្ចការពារ សុខភាព អាហារូបត្ថម្ភ ការអប់រំ ការអនុវត្តអនាម័យ ដូចជា ការលាងដៃនឹងសាប៊ូ និងការប្រើប្រាស់បង្គន់អនាម័យ និងការទទួលបានទឹកសុវត្ថិភាព
- ទាក់ទាញការគាំទ្រដើម្បីឲ្យនារីបានចូលរួមធ្វើសេចក្តីសម្រេចលើការអភិវឌ្ឍនៅមូលដ្ឋានឃុំ សង្កាត់
- បង្កើន និងពង្រឹងនូវការប្រាស្រ័យទាក់ទងកិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកផ្តល់សេវាកម្ម និងអ្នកភូមិដែលធ្វើសកម្មភាពជួយស្ត្រី និងកុមារនៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ចូលរួមអនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពឃុំ សង្កាត់ ពាក់ព័ន្ធស្ថានភាពស្ត្រី និងកុមារ
- តាមដានស្ថានភាពស្ត្រី និងកុមារក្នុងឃុំ សង្កាត់ និងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងដាក់បញ្ចូលក្នុងរបាយការណ៍ឃុំ សង្កាត់។

បន្ថែមលើកិច្ចការងារខាងលើ គ.ក.ន.ក មានតួនាទីផងដែរក្នុងការ ៖

- លើកកម្ពស់ការយល់ដឹង និងសេវាកម្មសុខភាពបន្តពូជ ការពន្យារកំណើត ការថែទាំសុខភាពមុន និងក្រោយសម្រាល ការសម្រាលនៅមណ្ឌលសុខភាព ការឆ្លងមេរោគអេដស៍ ការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងបញ្ហារបស់ជនចាស់ជរា។

## ៣.២. ការចុះបញ្ជីអត្រានុកូលដ្ឋាន

តួនាទីមួយដ៏សំខាន់របស់ គ.ក.ន.ក គឺការលើកកម្ពស់ការចុះបញ្ជីអត្រានុកូលដ្ឋាន (ដូចជាការចុះបញ្ជីកំណើត ការចុះបញ្ជីអាពាហ៍ពិពាហ៍ និងការចុះបញ្ជីមរណភាព)។ ការចុះបញ្ជីអត្រានុកូលដ្ឋាននេះបានផ្តល់ផលប្រយោជន៍ដល់បុគ្គលម្នាក់ៗ និងក្រុមគ្រួសារ ដូចជា ៖

- ប្រយោជន៍ទីមួយ ៖ ការចុះបញ្ជីអត្រានុកូលដ្ឋាន ជាវិធីមួយនៅក្នុងការបង្កើត និងការការពារអត្តសញ្ញាណ សញ្ជាតិ និងសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិស្របច្បាប់។ ឯកសារច្បាប់ដែលបញ្ជាក់ពី

អត្តសញ្ញាណ និងសញ្ជាតិអាចជួយឲ្យលោកអ្នកទទួលបាននូវសេវាសាធារណៈ និងសិទ្ធិផ្សេងៗ។ ឯកសារទាំងនេះអាចជួយការពារលោកអ្នកឲ្យចាកផុតពីការកេងប្រវ័ញ្ចកម្លាំងពលកម្មគ្រប់រូបភាពផងដែរ។

- ប្រយោជន៍ទីពីរ ៖ ឯកសារខាងលើនេះ (និងឯកសារដែលបង្ហាញពីស្ថានភាពអាពាហ៍ពិពាហ៍របស់លោកអ្នក) គឺជាសម្បត្តិដ៏សំខាន់បំផុត។ ឯកសារច្បាប់ និងសំបុត្របញ្ជាក់ផ្សេងៗទៀតក៏សំខាន់ផងដែរសម្រាប់ការទទួលកេរ្តិ៍មរតកស្របច្បាប់។ ប្រសិនបើស្ត្រីម្នាក់មិនអាចបង្ហាញពីទំនាក់ទំនងស្របច្បាប់របស់ខ្លួនជាមួយប្តី ឬជាមួយឪពុកដែលបានស្លាប់ទៅទេនោះ មានន័យថាស្ត្រី និងកុមារដែលជាញាតិសន្តានស្ត្រីនោះមិនអាចទទួលបានកេរ្តិ៍មរតកបានទេ។
- ប្រយោជន៍ទីបី ៖ ការចុះបញ្ជីអត្រានុកូលដ្ឋានគឺជាឧបករណ៍មួយនៃកិច្ចការពារសង្គម ទប់ទល់រាល់ទម្រង់នៃការរំលោភបំពានផ្សេងៗ (ឧទាហរណ៍ ពីការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ និងការជួញដូរមនុស្ស) ឬទប់ទល់នឹងភាពលំបាកនានាដែលបណ្តាលមកពីជម្លោះដ៏យូរអង្វែង ឬគ្រោះមហន្តរាយដ៏ស្មុគស្មាញ។

ការចុះបញ្ជីអត្រានុកូលដ្ឋានផ្តល់ប្រយោជន៍ដល់សង្គមទាំងមូលផងដែរ ៖

- ការចុះសំបុត្រកំណើត ៖ សិទ្ធិទទួលបានអត្តសញ្ញាណត្រូវបានមើលឃើញថាជាសិទ្ធិដ៏សំខាន់ដែលមានឥទ្ធិពលគ្របដណ្តប់លើគ្រប់វិស័យទាំងអស់។ ជាការចាំបាច់ក្នុងការធានាថា ព័ត៌មានរបស់កុមារត្រូវបានគេកត់ត្រាជាផ្លូវការពីអាយុ ទីកន្លែងកំណើត ឈ្មោះ និងទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេ។ ការកត់ត្រានេះធានាឲ្យកុមារទទួលបាននូវសិទ្ធិជាពលរដ្ឋ និងសិទ្ធិក្នុងការទទួលបាននូវសេវាសុខភាពអប់រំ ការការពារ និងសេវាសង្គមផ្សេងៗទៀតពេញមួយជីវិតរបស់ពួកគេ។
- ព័ត៌មានអំពីកំណើត មរណភាព និងមូលហេតុនៃមរណភាព ជារឿងសំខាន់ក្នុងការរៀបចំសេវាកម្មសម្រាប់របាយប្រជាសាស្ត្រ។ ឧទាហរណ៍ បញ្ជីកំណើតនឹងប្រាប់ឲ្យយើងដឹងថាតើនឹងមានក្មេងប៉ុន្មាននាក់ដែលត្រូវចុះឈ្មោះចូលរៀន? តើសាលារៀននីមួយៗគួរស្នើសុំសៀវភៅសិក្សាចំនួនប៉ុន្មានក្បាល? តុប៉ុន្មាន? កៅអីប៉ុន្មាន? ថ្នាក់រៀនប៉ុន្មាន? គ្រូប៉ុន្មាននាក់? អ្នកអប់រំប៉ុន្មាន? និងបង្គន់អនាម័យប៉ុន្មាន? (ជាអនុសាសន៍ កុមារចំនួន២០នាក់គួរប្រើបង្គន់អនាម័យមួយ) និងកន្លែងលាងដៃដែលត្រូវការជាចាំបាច់ដើម្បីធានាថា កុមារទទួលបានគុណភាពនៃការអប់រំ។
- ការចុះបញ្ជីកំណើតនេះក៏ជាទិន្នន័យបង្ហាញទៅដល់មណ្ឌលសុខភាពផងដែរ ថាតើមណ្ឌលសុខភាពនីមួយៗគួរស្នើសុំថ្នាំវ៉ាក់សាំងសម្រាប់កុមារចំនួនប៉ុន្មានក្នុងមួយឆ្នាំៗ?
- ទិន្នន័យពីមរណភាព ជាពិសេសទាក់ទងនឹងមូលហេតុនៃមរណភាពចាំបាច់ត្រូវចាត់ទុកជារឿងអាទិភាពបង្កើតជាគោលនយោបាយ និងធ្វើការតាមដាន និងប៉ាន់ប្រមាណ នូវគោលនយោបាយនេះទាំងនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

# ៤. ការប្រើប្រាស់ទិន្នន័យដើម្បីបង្កើនសមត្ថភាពកសាងផែនការ និងការចាត់អាទិភាព

## ៤.១. ឧបករណ៍កសាងផែនការ និងការធ្វើសេចក្តីសម្រេចចិត្ត

តួនាទីដ៏សំខាន់របស់មេឃុំ ចៅសង្កាត់ និង គ.ក.ន.ក គឺការប្រើប្រាស់ឧបករណ៍នានា ដូចជា ផែនទីសេវាសង្គម តារាងពិន្ទុគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំ ប្រព័ន្ធ ព័ត៌មានសុខភាព សៀវភៅទិន្នន័យភូមិ ឃុំ សង្កាត់ ដើម្បីកសាងផែនការសកម្មភាពជួយដល់ស្ត្រី និងកុមារងាយរងគ្រោះ ផែនការសកម្មភាពប្រចាំឆ្នាំ (ទម្រង់ទី១) និងផែនការថវិកាប្រចាំឆ្នាំ (ទម្រង់ទី២)។

នៅពេលដែល គ.ក.ន.ក បានកសាងផែនការសកម្មភាព និងផែនការថវិកានេះ តាមដំណើរការតាមបែបការចូលរួមដើម្បីជំរុញឲ្យមានភាពជាម្ចាស់ និងមានការគាំទ្ររួចហើយ គណៈកម្មាធិការត្រូវដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័ត។ គ.ក.ន.ក គួរតែផ្សព្វផ្សាយជាប្រចាំ និងឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់អំពីផែនការអាទិភាព និងរាយការណ៍ជូនពួកគាត់អំពីការរីកចម្រើន និងអំពីបច្ចុប្បន្នភាពនៃការរីកចម្រើន។

នៅដើមត្រីមាសនីមួយៗ គ.ក.ន.ក ត្រូវរៀបចំផែនការសកម្មភាពប្រចាំត្រីមាសរបស់ខ្លួន (ទម្រង់ទី៣)។

**ឧម្រង់ទី១**

រាជធានី ខេត្ត ..........................................

ក្រុង ស្រុក ខណ្ឌ .....................................

ឃុំ សង្កាត់...............................................

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ផែនការសកម្មភាពប្រចាំឆ្នាំ.............**

**ស្តីពីការអភិវឌ្ឍផ្នែកសង្គមប្រកបដោយសមធម៌**

| ល.រ | សកម្មភាពនិងលទ្ធផល | លទ្ធផលគ្រោង | | ទីតាំង | អ្នកទទួលខុសត្រូវ | អ្នកទទួលផលផ្ទាល់ | | ខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | | សរុប | ស្រី | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១ | ធានាការចុះអត្រានុកូលដ្ឋានឲ្យមានប្រសិទ្ធភាព | | | | | | | | | | | | | | | | | | |
| ២ | អប់រំអំពីសុខភាពបន្តពូជ ការពន្យារកំណើត ការថែទាំសុខភាពមុន និងក្រោយពេលសម្រាលកូន និងការសម្រាលនៅមណ្ឌលសុខភាព | | | | | | | | | | | | | | | | | | |
| ៣ | ការពារ និងការឆ្លើយតបចំពោះភាពពាក់ព័ន្ធនឹងកិច្ចការពារកុមារក្នុងចំណោមកុមារ និងគ្រួសារងាយរងគ្រោះបំផុត | | | | | | | | | | | | | | | | | | |
| ៤ | អប់រំអំពីការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ | | | | | | | | | | | | | | | | | | |
| ៥ | ធានាឲ្យមានសេវាសុខភាព និងអាហារូបត្ថម្ភនៅមូលដ្ឋាន និងទទួលបានសេវាកម្មសុខភាព និងអាហារូបត្ថម្ភមានគុណភាព និងបានទាន់ពេលវេលា | | | | | | | | | | | | | | | | | | |
| ៦ | អប់រំយុវជនយុវនារី អំពីសុខភាពបន្តពូជ ការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន | | | | | | | | | | | | | | | | | | |
| ៧ | វិនិយោគទៅក្នុងសាលាមត្តេយ្យសិក្សាសហគមន៍ | | | | | | | | | | | | | | | | | | |
| ៨ | អប់រំលើកទឹកចិត្តដល់មនុស្សចាស់ឲ្យមានការចូលរួមអភិវឌ្ឍសង្គម និងលើកកម្ពស់ការថែទាំសុខភាព | | | | | | | | | | | | | | | | | | |
| ៩ | បង្កើនគុណភាព អនាម័យ ទឹកស្អាត និងរស់នៅស្អាតក្នុងសហគមន៍ | | | | | | | | | | | | | | | | | | |
| ១០ | ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការឆ្លើយតប | | | | | | | | | | | | | | | | | | |
| ១១ | ការប្រជុំ និងតាមដានរបស់ គ.ក.ន.ក | | | | | | | | | | | | | | | | | | |

*ថ្ងៃទី.................ខែ................ឆ្នាំ..........*

**មេឃុំ ចៅសង្កាត់**

*ថ្ងៃទី.................ខែ................ឆ្នាំ..........*

**អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**

**ឧបសម្ព័ន្ធទី២**

រាជធានី ខេត្ត ......................

ក្រុង ស្រុក ខណ្ឌ..................

ឃុំ សង្កាត់ .........................

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

## ផែនការថវិកាប្រចាំឆ្នាំ......................
## សម្រាប់ការអភិវឌ្ឍផ្នែកសង្គមប្រកបដោយសមធម៌

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃឯកតា | សរុប |
|---|---|---|---|---|---|
| ១ | ធានាការចុះអត្រានុកូលដ្ឋានឲ្យមានប្រសិទ្ធភាព | | | | |
| ២ | អប់រំអំពីសុខភាពបន្តពូជ ការពន្យារកំណើត ការថែទាំសុខភាព មុន និងក្រោយសម្រាលកូន និងការសម្រាលនៅមណ្ឌលសុខភាព | | | | |
| | **សរុប** | | | | |
| ៣ | ការពារ និងការឆ្លើយតបចំពោះភាពពាក់ព័ន្ធនឹងកិច្ចការពារកុមារក្នុងចំណោមកុមារ និងគ្រួសារងាយរងគ្រោះបំផុត | | | | |
| ៤ | អប់រំអំពីការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ | | | | |
| | **សរុប** | | | | |
| ៥ | ធានាឲ្យមានការផ្តល់ និងទទួលបាននូវសេវាសុខភាពនៅតាមមូលដ្ឋានទាន់ពេលវេលា និងប្រកបដោយគុណភាព | | | | |
| ៦ | អប់រំយុវជនយុវនារីអំពីសុខភាពបន្តពូជ ការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន | | | | |
| | **សរុប** | | | | |
| ៧ | វិនិយោគទៅក្នុងសាលាមត្តេយ្យសិក្សាសហគមន៍ | | | | |
| ៨ | អប់រំលើកទឹកចិត្តដល់មនុស្សចាស់ឲ្យមានការចូលរួមអភិវឌ្ឍសង្គម និងលើកកម្ពស់ការថែទាំសុខភាព | | | | |
| | **សរុប** | | | | |
| ៩ | បង្កើនគុណភាពអនាម័យ ទឹកស្អាត និងរស់នៅស្អាតក្នុងសហគមន៍ | | | | |
| | **សរុប** | | | | |
| ១០ | ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការឆ្លើយតប | | | | |
| | **សរុប** | | | | |
| ១១ | ការប្រជុំ និងតាមដានរបស់ គ.ក.ន.ក | | | | |
| | **សរុប** | | | | |
| | សរុបរួម | | | | |

*ថ្ងៃទី.......ខែ........ឆ្នាំ..........*

**មេឃុំ ចៅសង្កាត់**

*ថ្ងៃទី.......ខែ........ឆ្នាំ..........*

**ស្មៀនឃុំ សង្កាត់**

**ទម្រង់ទី៣**

រាជធានី ខេត្ត ......................................

ក្រុង ស្រុក ខណ្ឌ .................................

ឃុំ សង្កាត់ .........................................

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ផែនការសកម្មភាពប្រចាំត្រីមាស......ឆ្នាំ..........**

**ស្តីពីការអភិវឌ្ឍផ្នែកសង្គមប្រកបដោយសមធម៌**

| ល.រ | សកម្មភាពនិងលទ្ធផល | លទ្ធផលគ្រោង | | ទីតាំង | អ្នកទទួលខុសត្រូវ | អ្នកទទួលផលផ្ទាល់ | | ខែ............ | | | | ខែ............ | | | | ខែ............ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | | សរុប | ស្រី | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | ធានាការចុះអត្រានុកូលដ្ឋានឲ្យមានប្រសិទ្ធភាព | | | | | | | | | | | | | | | | | | |
| ២ | អប់រំអំពីសុខភាពបន្តពូជ ការពន្យារកំណើតការថែទាំសុខភាពមុន និងក្រោយសម្រាលកូន ការសម្រាលនៅមណ្ឌលសុខភាព | | | | | | | | | | | | | | | | | | |
| ៣ | ការពារ និងការឆ្លើយតបចំពោះភាពពាក់ព័ន្ធនឹងកិច្ចការពារកុមារក្នុងចំណោមកុមារ និងគ្រួសារងាយរងគ្រោះបំផុត | | | | | | | | | | | | | | | | | | |
| ៤ | អប់រំអំពីការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ | | | | | | | | | | | | | | | | | | |
| ៥ | ធានាឲ្យមានសេវាសុខភាព និងអាហារូបត្ថម្ភនៅមូលដ្ឋាន និងទទួលបានសេវាកម្មសុខភាព និងអាហារូបត្ថម្ភមានគុណភាព និងបានទាន់ពេលវេលា | | | | | | | | | | | | | | | | | | |
| ៦ | អប់រំយុវជន យុវនារី អំពីសុខភាពបន្តពូជ ការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន | | | | | | | | | | | | | | | | | | |
| ៧ | វិនិយោគទៅក្នុងសាលាមត្តេយ្យសិក្សាសហគមន៍ | | | | | | | | | | | | | | | | | | |
| ៨ | អប់រំលើកទឹកចិត្តដល់មនុស្សចាស់ឲ្យមានការចូលរួមអភិវឌ្ឍសង្គម និងលើកកម្ពស់ការថែទាំសុខភាព | | | | | | | | | | | | | | | | | | |
| ៩ | បង្កើនគុណភាពអនាម័យ ទឹកស្អាត និងរស់នៅស្អាតក្នុងសហគមន៍ | | | | | | | | | | | | | | | | | | |
| ១០ | ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការឆ្លើយតប | | | | | | | | | | | | | | | | | | |
| ១១ | ការប្រជុំ និងតាមដានរបស់ គ.ក.ន.ក | | | | | | | | | | | | | | | | | | |

*ថ្ងៃទី.................ខែ.................ឆ្នាំ...........*

**មេឃុំ ចៅសង្កាត់**

*ថ្ងៃទី.................ខែ.................ឆ្នាំ...........*

**អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**

## ៤.២. ការរៀបចំ និងការចាត់ចែងកិច្ចប្រជុំឲ្យមានប្រសិទ្ធភាព

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវអនុវត្តរបៀបរបបប្រជុំការងាររបស់ខ្លួនដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រង់ជំពូក៩ ដែលចែងអំពីគណៈកម្មាធិការជំនួយការរបស់ឃុំ សង្កាត់។ ជាការសំខាន់ណាស់ដែល គ.ក.ន.ក ធ្វើកាលវិភាគប្រជុំឲ្យបានពេញមួយឆ្នាំ។ កាលវិភាគនេះអាចត្រូវរៀបចំធ្វើប្រចាំឆ្នាំ ឬក៏ប្រចាំត្រីមាស។ ការធ្វើរបៀបនេះជួយឲ្យ គ.ក.ន.ក រៀបចំកាលវិភាគរបស់គាត់បានត្រឹមត្រូវ ដោយមិនជាន់ជាមួយព្រឹត្តិការណ៍សំខាន់ផ្សេងៗ ដូចជាការសម្រាកបុណ្យជាតិ។ ក្រៅពីការប្រជុំជាទៀងទាត់ គណៈកម្មាធិការក៏អាចរៀបចំប្រជុំវិសាមញ្ញទៅតាមស្ថានភាពជាក់ស្តែងផងដែរ។ ឧទាហរណ៍ ការឆ្លើយតបនឹងទឹកជំនន់ជាដើម។

៤.២.១. ការប្រជុំប្រចាំខែ (ការប្រជុំនេះមិនគួរបញ្ចូលជាមួយការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ឡើយ)

**ក). គោលបំណងនៃការប្រជុំ** ៖ គ.ក.ន.ក ត្រូវរៀបចំប្រជុំប្រចាំខែរបស់ខ្លួនដើម្បីពិនិត្យអំពីភាពរីកចម្រើន និងដំណោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងនារី និងកុមារនៅក្នុងឃុំ សង្កាត់។

**ខ). អ្នកចូលរួម** ៖ សមាជិកគណៈកម្មាធិការដែលត្រូវអញ្ជើញចូលរួមប្រជុំប្រចាំខែរួមមាន ៖

- ប្រធានគណៈកម្មាធិការ
- អនុប្រធានគណៈកម្មាធិការ
- សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការ
- ស្មៀនឃុំ សង្កាត់
- នាយ ឬនាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់០១រូប
- នាយកសាលារៀន ឬតំណាង០១រូបមកពីគ្រប់សាលារៀនក្នុងឃុំ សង្កាត់
- ប្រធានមណ្ឌលសុខភាព ឬតំណាង០១រូបមកពីគ្រប់មណ្ឌលសុខភាពដែលពាក់ព័ន្ធ។

បើអាចធ្វើបានប្រធានគណៈកម្មាធិការអាចអញ្ជើញមេភូមិ អនុប្រធាន ឬជំនួយការភូមិ ដែលជាសមាជិកគណៈកម្មាធិការពីគ្រប់ភូមិដើម្បីចូលរួមប្រជុំប្រចាំខែ។

**គ). ប្រធានអង្គប្រជុំ** ៖ ប្រធាន ឬប្រធានស្តីទីរបស់គណៈកម្មាធិការ

**ឃ). អ្នកកត់ត្រា** ៖ ស្មៀនឃុំ សង្កាត់ ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

**ង). រយៈពេល** ៖ មួយព្រឹក ឬមួយល្ងាច (កន្លះថ្ងៃ)

**ច). របៀបវារៈ** ៖ រាល់ការប្រជុំប្រចាំខែរបស់គណៈកម្មាធិការ ត្រូវផ្តោតលើ របៀបវារៈមួយចំនួនដូចខាង ក្រោម ៖

១. ពិនិត្យលើរបាយការណ៍ប្រជុំខែមុន និងពិភាក្សាអំពីសកម្មភាពដែលបានកំណត់
២. រាយការណ៍ និងពិភាក្សាអំពីស្ថានភាពនៃស្ត្រី និងកុមារដែលងាយរងគ្រោះបំផុត និងផ្តល់នូវបច្ចុប្បន្នភាពអំពីសកម្មភាព ឬព្រឹត្តិការណ៍សំខាន់ៗរបស់សហគមន៍
៣. រាយការណ៍ និងពិភាក្សាអំពីសេវាកម្មសុខភាព និងអាហារូបត្ថម្ភ
៤. រាយការណ៍ និងពិភាក្សាអំពីផ្នែកអប់រំ
៥. រាយការណ៍ និងពិភាក្សាអំពីការចុះបញ្ជីអត្រានុកូលដ្ឋាន

៦. រាយការណ៍ និងពិភាក្សាពីការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការឆ្លើយតប
៧. រាយការណ៍ និងពិភាក្សាអំពីបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់
៨. រាយការណ៍អំពីការប្រើប្រាស់ថវិការបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
៩. ផ្សេងៗ។

<u>ដំណើរការប្រជុំ</u>

ការប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវយកចិត្តទុកដាក់លើសូចនាករនៃសេវាសង្គមនានា ដូចមាននៅក្នុងទម្រង់ទី៥ នៅក្នុងមេរៀនទី៦ អំពីការត្រួតពិនិត្យ ការវាយតម្លៃ និងរបាយការណ៍។

ការប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ អាចដំណើរការដូចខាងក្រោម ៖

- **មេឃុំ ចៅសង្កាត់ដែលជាប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវ ៖**
  - មានមតិបើកកិច្ចប្រជុំប្រចាំខែ
  - រាយការណ៍អំពីបញ្ហា ឬផែនការសកម្មភាពដែលឯកភាពកាលពីប្រជុំលើកមុន និងពិនិត្យមើលអំពីភាពរីកចម្រើន
  - បញ្ជាក់អំពីបញ្ហាដែលមិនទាន់បានដោះស្រាយ និងឯកភាពលើផែនការសកម្មភាពបន្ត។

ផ្អែកទៅលើព័ត៌មានដែលបានមកពីមេភូមិ អនុប្រធានភូមិ សមាជិកភូមិ និងក្រុមទ្រទ្រង់សុខភាពភូមិ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់នឹងរាយការណ៍អំពីស្ថានភាពរបស់ស្ត្រី និងកុមារដែលងាយរងគ្រោះបំផុត និងផ្តល់នូវបច្ចុប្បន្នភាពអំពីព្រឹត្តិការណ៍ និងសកម្មភាពសំខាន់ៗរបស់សហគមន៍ដូចជា ៖

- ចំនួនស្ត្រីមានផ្ទៃពោះ (យកចិត្តទុកដាក់ពិសេសចំពោះស្ត្រីមានផ្ទៃពោះដែលងាយរងគ្រោះបំផុត និងធានាថាពួកគាត់ទៅទទួលយកសេវាកម្មសុខភាពសម្រាប់ពិនិត្យផ្ទៃពោះយ៉ាងហោចណាស់ពីរដង សម្រាលកូនដោយសុវត្ថិភាពដោយឆ្មបជំនាញ ហើយមាតានិងទារកទៅពិនិត្យសុខភាពក្រោយពីសម្រាលកូនរួច)
- ចំនួនស្ត្រីមានផ្ទៃពោះសម្រាលកូនដោយឆ្មបជំនាញនៅតាមផ្ទះ
- ចំនួនស្ត្រីមានផ្ទៃពោះសម្រាលកូនដោយឆ្មបបុរាណនៅតាមផ្ទះ
- ចំនួនស្ត្រីមានផ្ទៃពោះស្លាប់ពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយសម្រាលកូន កាលពីខែមុន
- ចំនួនទារកដែលទើបកើតនៅក្នុងខែនេះ
- ចំនួនកុមារអាយុក្រោម០១ឆ្នាំទាំងអស់ (យកចិត្តទុកដាក់ជាពិសេសដល់កុមារដែលងាយរងគ្រោះបំផុត) បានទទួលការចាក់ថ្នាំបង្ការគ្រប់ចំនួន ដូចជា វ៉ាក់សាំង BCG ចំនួន០១ដូស (វ៉ាក់សាំងប្រឆាំងនឹងជំងឺរបេង) វ៉ាក់សាំង OPV ចំនួន០៣ដូស (វ៉ាក់សាំងប្រឆាំងនឹងជំងឺគ្រុនស្វិតដៃជើង) វ៉ាក់សាំង DPT-HepB-Hib ចំនួន០៣ដូស (វ៉ាក់សាំងប្រឆាំងនឹងជំងឺខាន់ស្លាក់

តេតាណូស ក្អកមាន់ ថ្លើមប្រភេទបេ និងរលាកស្អួត រលាកស្រោមខួរធ្ងន់ធ្ងរ ។ល។) និងវ៉ាក់សាំងកញ្រ្ជឹលចំនួន០១ដូស តាមរយៈដំណើរការកសាងផែនការខ្នាតតូចរវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងឃុំ សង្កាត់)

- ចំនួនកុមារបានទទួលការពិនិត្យដោយបានញុំាទឹកអូរ៉ាលីត និងថ្នាំគ្រាប់ជាតិស័ង្កសីនៅតាមភូមិ
- ចំនួនកុមារបានទទួលការពិនិត្យ ឬការចាក់ថ្នាំបង្ការជំងឺរលាកផ្លូវដង្ហើមទាន់ពេលវេលា
- ចំនួនកុមារអាយុពី០៣ ទៅ០៥ឆ្នាំ បានចុះឈ្មោះចូលរៀននៅសាលាមត្តេយ្យសិក្សាសហគមន៍
- ចំនួនកុមារអាយុ០៦-១១ឆ្នាំ បែងចែកតាមភេទ សញ្ជាតិ និងពិការភាព
- ចំនួនវគ្គបណ្តុះបណ្តាល
- ការពិភាក្សាក្នុងសហគមន៍ និងវេទិកាផ្សេងៗ
- ធ្វើបច្ចុប្បន្នភាពសាលាមត្តេយ្យសិក្សាសហគមន៍ (គ្រូមត្តេយ្យសិក្សាសហគមន៍ សម្ភារៈបង្រៀន ថ្នាក់រៀន វត្តមានសិស្ស និងតម្រូវការផ្សេងៗ)
- ធ្វើបច្ចុប្បន្នភាពអំពីការត្រៀមបម្រុងនិងការឆ្លើយតបសម្រាប់ការសង្គ្រោះបន្ទាន់
- ធ្វើបច្ចុប្បន្នភាពអំពីកុមារ និងគ្រួសារដែលងាយរងគ្រោះបំផុត
- ធ្វើបច្ចុប្បន្នភាពអំពីការងាររបស់អ្នកស្ម័គ្រចិត្តក្នុងភូមិ ឃុំ សង្កាត់។

ប្រធាន ឬតំណាងមណ្ឌលសុខភាព ប៉ុស្តិ៍សុខភាពដែលជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ រាយការណ៍អំពីព័ត៌មានខាងក្រោមនេះ ផ្អែកតាមរបាយការណ៍ប្រចាំខែរបស់មណ្ឌលសុខភាព ៖

- ចំនួនស្ត្រីមានផ្ទៃពោះបានទទួលការពិនិត្យផ្ទៃពោះ
- ចំនួនស្ត្រីមានផ្ទៃពោះសម្រាលកូនសរុបនៅក្នុងឃុំ សង្កាត់
- ចំនួនស្ត្រីដែលបានបំបៅកូនដោយទឹកដោះម្តាយក្រោយពីសម្រាលកូនភ្លាមៗ បន្ទាប់ពីបានសម្រាលកូននៅមណ្ឌលសុខភាពនៅក្នុងខែមុន
- ចំនួនស្ត្រីដែលបានស្លាប់អំឡុងពេលមានគភ៌ ក្នុងពេលសម្រាលកូន ឬក្រោយពេលសម្រាលកូនកាលពីខែមុន
- ចំនួនអ្នកឆ្លងមេរោគអេដស៍ កំពុងផ្ទុកមេរោគអេដស៍ និងស្លាប់ដោយសារជំងឺអេដស៍
- ចំនួនទារកអាយុក្រោម០១ខែ ដែលបានស្លាប់នៅមណ្ឌលសុខភាពកាលពីខែមុន
- ចំនួនទារកអាយុក្រោម០១ឆ្នាំ ដែលបានស្លាប់នៅមណ្ឌលសុខភាពកាលពីខែមុន
- ចំនួនទារកអាយុក្រោម០៥ឆ្នាំ ដែលបានស្លាប់នៅមណ្ឌលសុខភាពកាលពីខែមុន
- ចំនួនក្មេងគ្រោះថ្នាក់ដែលបានទទួលការព្យាបាលនៅមណ្ឌលសុខភាព (បែងចែកតាមភេទ អាយុ និងប្រភេទនៃគ្រោះថ្នាក់ ដូចជា ធ្លាក់ ពុល ពស់ចឹក លង់ទឹក របួសដោយបញ្ហាផ្សេងៗ អំពើហិង្សា និងគ្រោះថ្នាក់ចរាចរណ៍)
- ចំនួនកុមារអាយុក្រោម០១ឆ្នាំទាំងអស់ (យកចិត្តទុកដាក់ជាពិសេសដល់កុមារដែលងាយរងគ្រោះបំផុត) បានទទួលការចាក់ថ្នាំបង្ការគ្រប់ចំនួន ដូចជា វ៉ាក់សាំង BCG ចំនួន០១ដូស

(វ៉ាក់សាំងប្រឆាំងនឹងជំងឺរបេង) វ៉ាក់សាំង OPV ចំនួន០៣ដូស (វ៉ាក់សាំងប្រឆាំងនឹងជំងឺគ្រុនស្វិតដៃជើង) ដូស(វ៉ាក់សាំងប្រឆាំងនឹងជំងឺខាន់ស្លាក់ តេតាណូស ក្អកមាន់ ថ្លើមប្រភេទបេ និងរលាកសួត រលាកស្រោមខួរធ្ងន់ធ្ងរ។ល។) និងវ៉ាក់សាំងកញ្ជ្រឹលចំនួន០១ដូស ព្រមទាំងទទួលបានអាហារូបត្ថម្ភបន្ថែមបន្ទាប់ពីអាយុ០៦ខែ និងការព្យាបាលទាន់ពេលវេលានៃជំងឺរលាកផ្លូវដង្ហើមធ្ងន់)

- ក្នុងខែឧសភា និងខែធ្នូ ចំនួនក្មេងអាយុក្រោម០៥ឆ្នាំ បានទទួលជីវជាតិអាបន្ថែម និងថ្នាំទម្លាក់ព្រូន
- ចំនួនក្មេងខ្វះអាហារូបត្ថម្ភដែលបាននាំទៅ ឬបានពិនិត្យសុខភាពនៅមណ្ឌលសុខភាព
- ចំនួនផែនការសកម្មភាពតូចៗដែលបានធ្វើនៅមូលដ្ឋាន និងបានរៀបចំដោយបុគ្គលិកមណ្ឌលសុខភាព ដើម្បីធានាថាក្មេងបានទទួលបានការចាក់ថ្នាំបង្ការគ្រប់ចំនួន ការទម្លាក់ព្រូន និងការផ្តល់អាហារូបត្ថម្ភបន្ថែម
- ចំនួនករណីរាករូស ទទួលបានការពិនិត្យនៅមណ្ឌលសុខភាព ឬតាមភូមិទាន់ពេលវេលា
- ចំនួនជំងឺតាមផ្លូវដង្ហើម ទទួលបានការពិនិត្យនៅមណ្ឌលសុខភាពទាន់ពេលវេលា
- ចំនួនការប្រើប្រាស់ និងការថែទាំបង្គន់អនាម័យ កន្លែងលាងដៃដោយសាប៊ូ និងការប្រើប្រាស់ទឹកស្អាតសម្រាប់អ្នកជំងឺ និងបុគ្គលិកមណ្ឌលសុខភាព។

▪ **នាយកសាលារៀន ឬតំណាងនាយកសាលារៀនទាំងអស់ រាយការណ៍អំពីព័ត៌មានប្រចាំខែដូចខាងក្រោម ៖**
  - ចំនួនកុមារអាយុ០៦-១១ឆ្នាំ (បែងចែកតាមភេទ) ដែលបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា
  - ចំនួនកុមារអាយុ០៦-១១ឆ្នាំ (បែងចែកតាមភេទ) អវត្តមានជាប់ៗគ្នាពីសាលារៀន លើសពី ១៥ថ្ងៃ
  - ចំនួនកុមារអាយុ០៦-១១ឆ្នាំ (បែងចែកតាមភេទ) នៅសាលាបឋមសិក្សាបានទទួលថ្នាំទម្លាក់ព្រូនក្នុងអំឡុងកម្មវិធីសុខភាពចុះទៅដល់មូលដ្ឋាន (ពីរដងក្នុង១ឆ្នាំ ដែលរៀបចំដោយមណ្ឌលសុខភាពបានសហការជាមួយសាលារៀន)
  - ចំនួនការប្រើប្រាស់ និងថែទាំបង្គន់អនាម័យ កន្លែងលាងដៃនឹងសាប៊ូ និងប្រើប្រាស់ទឹកស្អាតសម្រាប់ទាំងសិស្ស និងទាំងបុគ្គលិកនៅក្នុងសាលា។

▪ **ស្មៀនឃុំ សង្កាត់នឹងរាយការណ៍ប្រចាំខែអំពីការចុះឈ្មោះប្រជាពលរដ្ឋ និងការអនុវត្តផែនការថវិការបស់ គ.ក.ន.ក ៖**
  - ចំនួនទារកដែលបានចុះបញ្ជីកំណើត (៣០ថ្ងៃបន្ទាប់ពីកើត)
  - ចំនួនអ្នកបានចុះសំបុត្រអាពាហ៍ពិពាហ៍
  - ចំនួនអ្នកបានចុះសំបុត្រមរណភាព (និងមូលហេតុ)
  - ការប្រើប្រាស់ថវិកា និងសមតុល្យ។

▪ **នាយនគរបាលប៉ុស្តិ៍ ឬតំណាងដែលជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ**

**និងរាយការណ៍ប្រចាំខែ អំពីបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់ដូចជា ៖**

- ចំនួនក្មេងទទួលបានការពិនិត្យគ្រោះថ្នាក់ (បែងចែកតាមអាយុ និងប្រភេទ ដូចជា ធ្លាក់ ពុល ពស់ចឹក លង់ទឹក របួសដោយបញ្ហាផ្សេងៗ អំពើហិង្សា គ្រោះថ្នាក់ចរាចរ) និងសកម្មភាពនានាដែលបង្កគ្រោះថ្នាក់បណ្តាលឲ្យមានរបួសស្នាមផ្សេងៗ
- ករណីចោរកម្ម
- សកម្មភាពក្រុមក្មេងទំនើង
- ចំនួនជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ (បែងចែកតាមភេទ)
- ចំនួនអ្នកស្លាប់ដោយសារអំពើហិង្សាក្នុងគ្រួសារ (បែងចែកតាមភេទ)
- ល្បែងស៊ីសង។

<u>ការសង្ខេប និងការបិទអង្គប្រជុំ</u>

បន្ទាប់ពីផ្នែកពាក់ព័ន្ធនីមួយៗបានរាយការណ៍ និងពិភាក្សាចប់សព្វគ្រប់ ប្រធានអង្គប្រជុំត្រូវផ្តល់ឱកាសឲ្យអ្នកចូលរួមទាំងអស់លើកឡើងអំពីបញ្ហាផ្សេងៗ បន្ទាប់មកប្រធានអង្គប្រជុំធ្វើការបូកសរុបលទ្ធផលនៃកិច្ចប្រជុំ និងបញ្ជាក់ឡើងវិញអំពីសកម្មភាពដែលត្រូវអនុវត្តបន្ត មុនពេលប្រកាសបិទអង្គប្រជុំ។

៤.២.២. ការប្រជុំប្រចាំឆមាស និងប្រចាំឆ្នាំ

**ក). គោលបំណង** ៖ គោលបំណងនៃកិច្ចប្រជុំប្រចាំឆ្នាំ ឬប្រចាំឆមាសត្រូវបានធ្វើឡើងដើម្បីពិនិត្យឡើងវិញអំពី ៖

- ការអនុវត្តមុខងារ និងភារកិច្ចរបស់សមាជិកគណៈកម្មាធិការ
- សកម្មភាពទាំងនេះវាមានផលប៉ះពាល់យ៉ាងដូចម្តេចទៅដល់ស្ត្រី និងកុមារដែលងាយរងគ្រោះបំផុត
- ការប្រើប្រាស់មូលនិធិគាំទ្រ។

**ខ). អ្នកចូលរួម** ៖ សមាជិកគណៈកម្មាធិការទាំងអស់ត្រូវចូលរួមប្រជុំប្រចាំឆមាស និងប្រចាំឆ្នាំរបស់គណៈកម្មាធិការ

**គ). ប្រធានអង្គប្រជុំ** ៖ ប្រធាន ឬប្រធានស្តីទីរបស់គណៈកម្មាធិការ

**ឃ).អ្នកកត់ត្រា** ៖ ស្មៀនឃុំ សង្កាត់ ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

**ង). រយៈពេល** ៖ មួយព្រឹក ឬមួយល្ងាច (កន្លះថ្ងៃ)

**ច). របៀបវារៈ** ៖ ការប្រជុំប្រចាំឆមាស និងប្រចាំឆ្នាំរបស់គណៈកម្មាធិការត្រូវផ្តោតលើរបៀបវារៈមួយចំនួនដូចខាងក្រោម ៖

- បញ្ជាក់អំពីដំណោះស្រាយនានា អាចឆ្លើយតបទៅនឹងបញ្ហាដែលជះឥទ្ធិពលដល់ស្ត្រី និងកុមារងាយរងគ្រោះបំផុត
- ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាព

- បូកសរុបលទ្ធផល និងការរីកចម្រើននៃការអនុវត្តផែនការសកម្មភាពរបស់ គ.ក.ន.ក ដោយផ្ទៀបជាមួយសូចនាករដែលបានកំណត់
- រាយការណ៍អំពីការចំណាយ និងការអនុវត្តផែនការថវិកា។

៤.២.៣. ការប្រជុំវិសាមញ្ញ

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់អាចរៀបចំប្រជុំវិសាមញ្ញនៅពេលណាក៏បានតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មាធិការ។ ចំពោះសមាជិកដែលត្រូវអញ្ជើញចូលរួមប្រជុំអាស្រ័យទៅលើការសម្រេចរបស់ប្រធាន។

# ៥. ការកសាងផែនការថវិកាផ្តោតលើសមធម៌ និងការកៀរគរធនធាន

## ៥.១. សេចក្តីណែនាំស្តីពីការកសាងផែនការថវិកាផ្តោតលើសមធម៌

ការកសាងផែនការថវិកាដោយផ្តោតលើសមធម៌មានន័យថា គឺជាផែនការថវិកាដែលធនធានត្រូវបានយកទៅប្រើប្រាស់ក្នុងវិធីមួយដែលឆ្លើយតបទៅនឹងតម្រូវការ ជាពិសេសតម្រូវការរបស់ក្រុមជនដែលងាយរងគ្រោះបំផុត។

ការកសាងផែនការថវិកាដោយផ្តោតលើសមធម៌ គឺប្រើប្រាស់ធនធានដើម្បីធានាថា កុមារទាំងអស់ទទួលបានការចាក់ថ្នាំបង្ការ និងទទួលបានការផ្តល់អាហារូបត្ថម្ភគ្រប់គ្រាន់ និងសេវាសុខភាពត្រឹមត្រូវ។ កុមារដែលរស់នៅក្នុងតំបន់ដាច់ស្រយាល អាចនឹងបោះបង់ការសិក្សាច្រើនជាងកុមារដែលរស់នៅជិតសាលារៀន។ ផែនការថវិកាផ្តោតលើសមធម៌ នឹងប្រើប្រាស់ធនធានក្នុងការជួយកុមារដែលនៅតំបន់ដាច់ស្រយាលទាំងនោះឲ្យទៅសាលារៀនបាន។

ដូចបានលើកឡើងក្នុងការកសាងផែនការសកម្មភាពប្រចាំឆ្នាំ និងប្រចាំត្រីមាស (ក្នុងផ្នែកទី៣.១) មេឃុំ ចៅសង្កាត់ ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារស្មៀនឃុំ សង្កាត់ និង គ.ក.ន.ក ត្រូវរៀបចំផែនការថវិកា (ទម្រង់ទី២ ផែនការថវិកាប្រចាំឆ្នាំ និងទម្រង់ទី៤ ផែនការថវិកាប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆមាស) ឲ្យសមស្របទៅនឹងផែនការសកម្មភាពទាំងនោះ ដើម្បីធានាថាផែនការសកម្មភាពមានថវិកាគាំទ្រគ្រប់គ្រាន់។ (សូមមើលករណីសិក្សាខាងក្រោមនៅឃុំអំពិល និងករណីសិក្សាដែលមាននៅក្នុងឯកសារដែលបង្ហាញពីផែនទីសេវាសង្គម)។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដាក់បញ្ចូលផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំរបស់ គ.ក.ន.ក ទៅក្នុងផែនការសកម្មភាព និងថវិការបស់ខ្លួន ដើម្បីធានាថាការអនុវត្តមុខងាររបស់ គ.ក.ន.ក មានថវិកាគាំទ្រក្នុងការដោះស្រាយបញ្ហាប្រកបដោយសមធម៌ និងផ្តល់អាទិភាពខ្ពស់ទៅលើបញ្ហាស្ត្រី និងកុមារ ។

ក្នុងករណីខ្លះ ដូចជាការលេចឡើងនូវបញ្ហាថ្មី ឬក៏ស្ថានភាពដែលមិនបានគ្រោងទុក គ.ក.ន.ក អាចធ្វើការកែសម្រួលផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួនបាន។ ផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំដែលបានកែសម្រួលរួច ត្រូវដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងសម្រេចដោយយោងតាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ក. ករណីសិក្សានៅឃុំអំពិល

យោងតាមសូចនាករនៃសេវាសង្គមប្រកបដោយសមធម៌នៅឃុំអំពិល (ក្នុងផ្នែកទី៦) សមាជិក គ.ក.ន.ក នៅឃុំអំពិលបានរៀបចំថវិកាដូចខាងក្រោម ដើម្បីដោះស្រាយតម្រូវការសេវាសង្គមសម្រាប់ជនដែលងាយរងគ្រោះបំផុត។

ឃុំអំពិលមាន០៥ភូមិ មានប្រជាពលរដ្ឋសរុបចំនួន១០.០០០នាក់។

ឧទាហរណ៍ ៖ កិច្ចអនរាគមន៍របស់ឃុំ ដើម្បីពង្រឹងការផ្តល់សេវាសង្គម

តាមការសាកសួរសហគមន៍ពីការចុះបញ្ជីកំណើត ចុះបញ្ជីអាពាហ៍ពិពាហ៍ និងការចុះបញ្ជីមរណភាពកាលពីឆ្នាំមុន ពួកគាត់បានឆ្លើយថា ក្នុងចំណោមទារកកើតចំនួន១០០នាក់ មានចំនួនតែ៥៥នាក់ប៉ុណ្ណោះដែលបានចុះបញ្ជីកំណើត ក្នុងចំណោមអាពាហ៍ពិពាហ៍ចំនួន២០គូ មានតែគូស្រករ០២គូប៉ុណ្ណោះដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍ និងក្នុងចំណោមមរណភាពចំនួន១៥ មានតែមរណភាពចំនួន០៣ប៉ុណ្ណោះដែលបានចុះបញ្ជីមរណភាព។ ពួកគាត់បានកត់សម្គាល់ថា ប្រជាពលរដ្ឋចំនួន០៤គ្រួសារមានកុមាររងគ្រោះដោយសារបាត់បង់ឪពុក ឬម្តាយ។ កុមារទាំងនោះត្រូវការឧបត្ថម្ភគាំទ្រពីឃុំ។ ក្រុមប្រឹក្សាឃុំគិតថា មានសកម្មភាពជាច្រើនត្រូវបំពេញដើម្បីធ្វើការកែលម្អការចុះបញ្ជីនៃព្រឹត្តិការណ៍សំខាន់ៗនេះ។

១. ធានាការចុះបញ្ជីអត្រានុកូលដ្ឋានឲ្យមានប្រសិទ្ធភាព

| ល.រ | សកម្មភាពដែលអាចអនុវត្តបាន | ឯកតា | បរិមាណ | តម្លៃឯកតា (រៀល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|
| វគ្គលើកកម្ពស់ការយល់ដឹងស្តីពីសារៈសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន (កំណើត អាពាហ៍ពិពាហ៍ មរណភាព) ដល់បុគ្គលិកមណ្ឌលសុខភាព ព្រះសង្ឃ អាចារ្យ និងអ្នកភូមិ | | | | | |
| ១ | ថ្លៃធ្វើដំណើររបស់សមាជិក គ.ក.ន.ក ០២នាក់ដើម្បីលើកកម្ពស់ការយល់ដឹងស្តីពីសារៈសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាននៅភូមិដាច់ស្រយាល | នាក់ | ៤០ | ៨.០០០ | ៣២០.០០០ |
| ២ | អាហារសម្រន់សម្រាប់វគ្គលើកកម្ពស់ការយល់ដឹងស្តីពីសារៈសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន (១០ភូមិ) | ភូមិ | ១០ | ១២.០០០ | ១២០.០០០ |
| ៣ | សម្ភារៈវគ្គផ្សព្វផ្សាយសម្រាប់១០ភូមិ (រួមមាន ក្រដាស ហ្វឺតប៊ិច) | ភូមិ | ១០ | ៨.០០០ | ៨០.០០០ |
| ៤ | ឧបត្ថម្ភជំនួយការដើម្បីចុះបញ្ជីអត្រានុកូលដ្ឋាន (០១នាក់ X ១០ខែ ) | នាក់ | ១០ | ២៨.០០០ | ២៨០.០០០ |
| **សរុប** | | | | | **៨០០.០០០** |

២. កិច្ចការពារកុមារ និងការឆ្លើយតបចំពោះកុមារងាយរងគ្រោះ និងក្រុមគ្រួសារងាយរងគ្រោះបំផុត

យោងទៅតាមបទដ្ឋាន និងសេចក្តីណែនាំសម្រាប់ការថែទាំ ការគាំទ្រ និងកិច្ចការពារកុមារកំព្រា និងកុមារងាយរងគ្រោះ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០១១ បានកំណត់ថាកុមារកំព្រា និងកុមារងាយរងគ្រោះ រួមមាន កុមារកំព្រា កុមាររស់នៅជាមួយឪពុកម្តាយ ឬអ្នកថែទាំមានជំងឺរ៉ាំរ៉ៃ កុមាររងផលប៉ះពាល់ពីមេរោគអេដស៍ ឬជំងឺអេដស៍ កុមាររស់នៅក្រៅការថែទាំរបស់គ្រួសារ (ដូចជាកុមារនៅតាមមណ្ឌលកុមារកំព្រា និងកុមារអនាថា) កុមាររស់នៅក្នុងគ្រួសារក្រីក្រ កុមារត្រូវគេរំលោភ និងកេងប្រវ័ញ្ច កុមារដែលមានទំនាស់ជាមួយនឹងច្បាប់ (ដូចជាកុមារត្រូវគេចោទប្រកាន់ពីការប្រព្រឹត្តិបទល្មើស កុមារញៀនថ្នាំញៀន និងកុមារប្រើប្រាស់ថ្នាំញៀនខុសច្បាប់) និងកុមារពិការ។

សមាជិក គ.ក.ន.ក នៅឃុំអំពិលបានកត់សម្គាល់ថា រាល់កិច្ចអន្តរាគមន៍ទាំងឡាយដែលពាក់ព័ន្ធនឹង

កិច្ចការពារកុមារ ចាំបាច់ត្រូវមានភាពបត់បែនក្នុងការរៀបចំផែនការសកម្មភាព និងថវិកាដើម្បីជួយដល់កុមារងាយរងគ្រោះឲ្យកាន់តែប្រសើរឡើង។ គ.ក.ន.ក បានកត់សម្គាល់ថា កាលពីឆ្នាំមុនមានកុមារ០៥នាក់គ្មានឪពុក ឬគ្មានម្តាយ ឬគ្មានឪពុកម្តាយ។ ក្នុងឃុំមានកុមារកំព្រាសរុបចំនួន៥០នាក់ ហើយពួកគេទាំងអស់មិនបានចូលរៀនទេ។ មានកុមារអាយុ០៦-១១ឆ្នាំចំនួន៦៥៩នាក់មិនបានចូលរៀន ក្នុងនោះមានកុមារចំនួន៧០នាក់ជាកុមារងាយរងគ្រោះ។ អនុវត្តតាមដំណើរការនៃអត្តសញ្ញាណកម្ម សមាជិក គ.ក.ន.ក ០២នាក់បានកំណត់ថា ៖

- កុមារចំនួន២៣នាក់ត្រូវការមធ្យោបាយបញ្ជូនទៅរកសេវាជំនាញ
- កុមារចំនួន៧០នាក់ និងអ្នកថែទាំ ត្រូវការការគាំទ្រថ្លៃធ្វើដំណើរ និងអាហារក្នុងពេលបញ្ជូនកុមារងាយរងគ្រោះទៅពិនិត្យសុខភាព
- ក្នុងចំណោមកុមារចំនួន៦៥៩នាក់ មានកុមារចំនួន៣៥៩នាក់ ត្រូវការការគាំទ្រសម្ភារៈសិក្សា និងឯកសណ្ឋានសិស្ស
- កុមារចំនួន៧០នាក់ ត្រូវការជំនួយម្ហូបអាហារ។

| ល.រ | សកម្មភាពដែលអាចអនុវត្តបាន | ឯកតា | បរិមាណ | តម្លៃឯកតា (រៀល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|
| ការកំណត់រកកុមារងាយរងគ្រោះ និងក្រុមគ្រួសាររងគ្រោះ ដោយប្រើប្រាស់ក្រុមការងារពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ ផែនទីសេវាសង្គម អត្តសញ្ញាណប័ណ្ណសម្គាល់ភាពក្រីក្រ ប្រព័ន្ធទិន្នន័យឃុំ ឬការបញ្ជូនពីទីភ្នាក់ងារជំនាញ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ | | | | | |
| ១ | សម្រាប់កិច្ចប្រជុំតាមភូមិ ដើម្បីកំណត់រកកុមារងាយរងគ្រោះ ផ្អែកលើក្រុមការងារពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ ផែនទីសេវាសង្គម អត្តសញ្ញាណប័ណ្ណសម្គាល់ភាពក្រីក្រ ប្រព័ន្ធទិន្នន័យឃុំ ឬបញ្ជូនពីទីភ្នាក់ងារជំនាញ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ (០៥ភូមិ) | ភូមិ | ៥ | ២០.០០០ | ១០០.០០០ |
| ២ | ថ្លៃធ្វើដំណើររបស់សមាជិក គ.ក.ន.ក ០២នាក់សម្រាប់ប្រជុំតាមភូមិ ដើម្បីកំណត់រកកុមារងាយរងគ្រោះ (ប្រជុំ ០២ដង ក្នុងភូមិទាំង០៥) | នាក់ | ២០ | ៨.០០០ | ១៦០.០០០ |
| ៣ | សម្ភារៈប្រជុំសម្រាប់០៥ភូមិ (រួមមាន ក្រដាសកាត ហ្វឺតប៊ិច) | ភូមិ | ៥ | ៨.០០០ | ៤០.០០០ |
| ៤ | មធ្យោបាយធ្វើដំណើររបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំចុះសួរសុខទុក្ខតាមគ្រួសារ ៖<br>១). រៀបចំគ្រួសារ និងសហគមន៍ ក្នុងបំណងធ្វើការបង្រួបបង្រួមកុមារ និងសមាហរណកម្មកុមារដែលបានបែកចេញពីគ្រួសារ (រាប់ទាំងកុមារដែលមកពីមណ្ឌលកុមារកំព្រា មណ្ឌលកែប្រែ កុមាររងគ្រោះ និងកុមារដែលមានទំនាស់នឹងច្បាប់) ដោយសហការជាមួយការិយាល័យ និងមន្ទីរសង្គមកិច្ច អតីត | នាក់ | ២០ | ៨.០០០ | ១៦០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | យុទ្ធជន និងយុវនីតិសម្បទា ស្រុក ខេត្ត។<br>២). ចុះតាមដានកុមារងាយរងគ្រោះដែលបានកំណត់រកឃើញ (ករណីតម្រូវការតាមដានជាចាំបាច់) តាមភូមិ រាប់ទាំងកុមារដែលបានបញ្ជូនមកពីទីភ្នាក់ងារដ៏ទៃទៀត អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍។<br>៣). ចុះតាមដានកុមារដែលបានបង្រួបបង្រួម និងធ្វើសមាហរណកម្មជាមួយក្រុមគ្រួសារ និងសហគមន៍រួចហើយ (រាប់ទាំងកុមារដែលមកពីមណ្ឌលកុមារកំព្រា និងកុមារដែលមានទំនាស់នឹងច្បាប់)។ | | | | |
| ឧបត្ថម្ភដល់កុមារងាយរងគ្រោះ និងក្រុមគ្រួសារងាយរងគ្រោះដែលបានកំណត់រកឃើញដោយប្រើប្រាស់ក្រុមការងារពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ ផែនទីសេវាសង្គម អត្តសញ្ញាណប័ណ្ណសម្គាល់ជនក្រីក្រ ប្រព័ន្ធទិន្នន័យឃុំ ឬការបញ្ជូនពីទីភ្នាក់ងារជំនាញ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ | | | | | |
| ១ | គាំទ្រមធ្យោបាយបញ្ជូនទៅរកសេវាជំនាញ ដូចជា ជំនួយផ្នែកច្បាប់ ស្តារនីតិសម្បទា ការព្យាបាលជំងឺអេដស៍ ការថែទាំជំនួសជាបណ្តោះអាសន្ន និងការគាំទ្រផ្នែកផ្លូវចិត្ត (រាប់បញ្ចូលការធ្វើដំណើរ តម្លៃសេវា។ល។ និងការសង្គ្រោះបន្ទាន់) | កុមារ និងអ្នកថែទាំ | ២៣ | ២៤.០០០ | ៥៥២.០០០ |
| ២ | គាំទ្រថ្លៃធ្វើដំណើរ និងអាហារក្នុងពេលបញ្ជូនកុមារងាយរងគ្រោះទៅពិនិត្យសុខភាព | កុមារ និងអ្នកថែទាំ | ៧០ | ៨.០០០ | ៥៦០.០០០ |
| ៣ | គាំទ្រសម្ភារៈសិក្សា និងឯកសណ្ឋានសិស្សដល់កុមារងាយរងគ្រោះ | កុមារ | ៣៥៩ | ២០.០០០ | ៧.១៨០.០០០ |
| ៤ | គាំទ្រអាហារដល់កុមារងាយរងគ្រោះ ឬស្ត្រីមានផ្ទៃពោះ (អង្ករ អំបិលអ៊ីយ៉ូដ ទឹកស៊ីអ៊ីវ ទឹកត្រី ប្រេងឆា ត្រីសណ្តែក ស្ករ ។ល។) | កុមារ | ៧០ | ៦០.០០០ | ៤.២០០.០០០ |
| ៥ | ចេញថ្លៃឲ្យគ្រួសារងាយរងគ្រោះរៀនមុខវិជ្ជាជីវៈ និងផ្តល់ថវិកាបង្កើត ឬពង្រីកមុខរបររកប្រាក់ចំណូលខ្នាតតូចដើម្បីថែទាំកុមារនៅក្នុងគ្រួសារតាមផែនការសេវាកម្ម | គ្រួសារ | ២ | ១៤០.០០០ | ២៨០.០០០ |
| ៦ | គាំទ្រការជួបជុំគ្រួសារវិញ និងការធ្វើសមាហរណកម្មកុមារ (រាប់ទាំងការឧបត្ថម្ភថ្លៃធ្វើដំណើរ) ទៅក្នុងគ្រួសារ និងសហគមន៍វិញ រាប់ទាំងកុមារដែលមកពីមណ្ឌលកុមារកំព្រា និងកុមារដែលមានទំនាស់នឹងច្បាប់) | កុមារ | ១៤ | ២០.០០០ | ២៨០.០០០ |
| **សរុបតម្រូវការ** | | | | | **១៣.៥១២.០០០** |
| **សរុបជាក់ស្តែង** | | | | | **២.០០០.០០០** |
| **សរុបសំណើក្នុងពេលប្រជុំកៀរគរធនធាន** | | | | | **១១.៥១២.០០០** |

៣. ធានាឱ្យមានការផ្តល់ និងទទួលបាននូវសេវាសុខភាពនៅតាមមូលដ្ឋានទាន់ពេលវេលា និងប្រកបដោយគុណភាព

គ.ក.ន.ក បានកំណត់ទារកដែលទើបនឹងកើត ស្ត្រីមានផ្ទៃពោះ និងស្ត្រីជាម្តាយសរុបចំនួន២៥០នាក់

ដែលត្រូវការគាំទ្រការថែទាំសុខភាព (បន្ថែមពីលើកុមារចំនួន៧០នាក់ដែលបានកំណត់នៅក្នុងផ្នែកទី២)។

គ.ក.ន.ក បានកត់សម្គាល់ថា ផែនការខ្នាតតូចសម្រាប់កម្មវិធីតាមមូលដ្ឋាន ត្រូវការពង្រឹងបន្ថែមទៀត នៅក្នុងឃុំ សង្កាត់ ដោយសារមានកុមារតែ២ ឬ៣នាក់ប៉ុណ្ណោះដែលបានទទួលការចាក់ថ្នាំបង្ការ ការទម្លាក់ព្រូន និងការផ្តល់ជីវជាតិអាបន្ថែម។ វាគ្រាន់តែជាការបំពេញបន្ថែមប៉ុណ្ណោះ មិនមែនគ្រប់កុមារដែលខ្វះអាហារូបត្ថម្ភសុទ្ធតែទទួលបានការព្យាបាលនោះទេ។

| ល.រ | សកម្មភាពដែលអាចអនុវត្តបាន | ឯកតា | បរិមាណ | តម្លៃឯកតា (រៀល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|
| ការលើកកម្ពស់ការយល់ដឹងស្តីពីសុខភាពមាតាទារកកុមារ និងអាហារូបត្ថម្ភ | | | | | |
| ១ | ថ្លៃធ្វើដំណើររបស់សមាជិក គ.ក.ន.ក ០២នាក់ ចុះអប់រំផែនការខ្នាតតូចសម្រាប់កម្មវិធីតាមមូលដ្ឋាន ជាមួយគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព (ការចាក់ថ្នាំបង្ការ ការទម្លាក់ព្រូន ការរៀបចំប្រជុំផ្សព្វផ្សាយស្តីពីសុខភាពមាតាទារក និងកុមារ និងអាហារូបត្ថម្ភ) (០៥ភូមិ) | នាក់ | ១០ | ៨.០០០ | ៨០.០០០ |
| ២ | ថ្លៃធ្វើដំណើររបស់សមាជិក គ.ក.ន.ក ០២នាក់រៀបចំប្រជុំផ្សព្វផ្សាយ ឬត្រួតពិនិត្យការផ្តល់សេវាកម្មស្តីពីសុខភាពមាតាទារក និងកុមារ និងអាហារូបត្ថម្ភ | នាក់ | ១០ | ៨.០០០ | ៨០.០០០ |
| ៣ | គាំទ្រប្រតិបត្តិការប្រចាំខែ (០៥ភូមិ) ដល់ក្រុមអ្នកស្ម័គ្រចិត្តទ្រទ្រង់សុខភាពភូមិដើម្បី ៖<br>- កំណត់ និងព្យាបាលជំងឺរាករូសកុមារជាមួយនឹងទឹកអំបិលអូរ៉ាលីត និងថ្នាំគ្រាប់ស័ង្កសី<br>- ផ្តល់បន្ថែមអាហារូបត្ថម្ភបន្ទាប់បន្សំសម្រាប់កុមារ និងស្ត្រី រក្សាទុកការចុះឈ្មោះកុមារ និងស្ត្រីគាំទ្រមណ្ឌលសុខភាពចុះតាមមូលដ្ឋាន រួមមាន ការផ្តល់ជីវជាតិអាបន្ថែម និងថ្នាំទម្លាក់ព្រូន<br>- ចុះសួរសុខទុក្ខដល់ផ្ទះស្ត្រីមានផ្ទៃពោះ ស្ត្រីសម្រាលកូនហើយ និងកុមារក្រោមអាយុ០៦ឆ្នាំ | នាក់ | ១០ | ២៤.០០០ | ២៤០.០០០ |
| ៤ | អ្នកភូមិចូលរួមវគ្គលើកកម្ពស់ការយល់ដឹងពីសុខ ភាពមាតាទារក និងកុមារ និងអាហារូបត្ថម្ភ (០៥ភូមិ) | ភូមិ | ៥ | ២០.០០០ | ១០០.០០០ |
| គាំទ្រស្ត្រីមានផ្ទៃពោះងាយរងគ្រោះ ដើម្បីលើកកម្ពស់ការមានផ្ទៃពោះដោយសុវត្ថិភាព ការសម្រាលកូន និងចុះតាមដានស្ត្រីសម្រាលកូន ទារក និងកុមារនៅមណ្ឌលសុខភាព | | | | | |
| ១ | ថ្លៃធ្វើដំណើររបស់ស្ត្រីមានផ្ទៃពោះងាយរងគ្រោះទៅពិនិត្យសុខភាពមុនពេលសម្រាលកូន ការសម្រាលកូនដោយសុវត្ថិភាព ចុះសួរសុខទុក្ខតាមដានស្ត្រីសម្រាលកូន ការពិនិត្យសុខភាពក្រោយសម្រាលកូន ពិគ្រោះយោបល់ពីទារក និងកុមារនៅមណ្ឌលសុខភាព (រួមទាំងការចុះសួរសុខទុក្ខដើម្បីនាំទារក ឬកុមារមកព្យាបាលជំងឺរាករូស ជំងឺរលាកផ្លូវដង្ហើមធ្ងន់ និងការចាក់ថ្នាំបង្ការ។ល។ | ស្ត្រី កុមារ | ២០ | ៨.០០០ | ១៦០.០០០ |
| ២ | ថ្លៃម្ហូបអាហាររបស់ស្ត្រីមានផ្ទៃពោះងាយរងគ្រោះ ពេល | ស្ត្រី | ២០ | ៨.០០០ | ១៦០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | សម្រាលកូននៅមណ្ឌលសុខភាព | | | | |
| ៣ | គាំទ្រមណ្ឌលសុខភាពឲ្យបើកទ្វារបម្រើសេវា២៤ម៉ោង (ដើម្បីធានាការផ្តល់សេវាជាប្រចាំ) តាមរយៈ ៖<br>- ការផ្តល់គ្រែបន្ថែមនៅមណ្ឌលសុខភាព<br>- គាំទ្រការចំណាយថ្លៃអគ្គិសនី<br>- ឧបត្ថម្ភអ្នកប្រចាំការដើម្បីធានាឲ្យមណ្ឌលសុខភាពបើកទ្វារបម្រើសេវា២៤ម៉ោង<br>- គាំទ្រការប្រាស្រ័យទាក់ទង (បុគ្គលិកសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និង គ.ក.ន.ក) | មណ្ឌលសុខភាព | ១ | ១៤០.០០០ | ១៤០.០០០ |
| ៤ | គាំទ្រការប្រាស្រ័យទាក់ទង (ក្រុមទ្រទ្រង់សុខភាពភូមិ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និងសមាជិក គ.ក.ន.ក ធ្វើទំនាក់ទំនងទៅបុគ្គលិកសុខភាព) | នាក់ កាតទូរស័ព្ទ | ៤ | ២០.០០០ | ៨០.០០០ |
| **សរុប** | | | | | **៨០០.០០០** |

៤- រៀបចំឱ្យកុមារត្រៀមខ្លួនចូលសាលាបឋមសិក្សា

ក្នុងចំណោមកុមារដែលមានអាយុចាប់ពី០៣ ដល់០៥ឆ្នាំចំនួន៦៥២នាក់ មានកុមារតែ២៥នាក់ប៉ុណ្ណោះដែលបានចូលរៀនក្នុងមត្តេយ្យសិក្សាសហគមន៍ក្នុងឃុំអំពិល។ គ.ក.ន.ក បានសម្រេចកៀរគរធនធានដើម្បីធានាថាកុមារចំនួន៦២៧នាក់ទៀត ចូលរៀនបានក្នុងមត្តេយ្យសិក្សាសហគមន៍។ មត្តេយ្យសិក្សាសហគមន៍ថ្មីចំនួន២៥ថ្នាក់ គួរតែត្រូវបានបង្កើតឡើងដោយក្នុងមួយភូមិមានមត្តេយ្យសិក្សាសហគមន៍ថ្មីចំនួន៤ ។

| ល.រ | សកម្មភាពដែលអាចអនុវត្តបាន | ឯកតា | បរិមាណ | តម្លៃឯកតា (រៀល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|
| សម្រាប់មត្តេយ្យសិក្សាសហគមន៍មានស្រាប់ | | | | | |
| ១ | គ្រូជាប់កិច្ចសន្យាមត្តេយ្យសិក្សាសហគមន៍រយៈពេល៩ខែ | នាក់ | ៥ x ៩ | ៤៨.០០០ | ២.១៦០.០០០ |
| ២ | មធ្យោបាយធ្វើដំណើរសម្រាប់សមាជិកម្នាក់នៃ គ.ក.ន.ក ចុះពិនិត្យតាមដានមត្តេយ្យសិក្សាសហគមន៍រយៈពេល៩ខែ | នាក់ | ៩ | ៨.០០០ | ៧២.០០០ |
| ៣ | មធ្យោបាយធ្វើដំណើរសម្រាប់សមាជិកម្នាក់នៃ គ.ក.ន.ក ចុះរៀបចំកិច្ចប្រជុំប្រចាំត្រីមាសពាក់ព័ន្ធមត្តេយ្យសិក្សាសហគមន៍ (៥ភូមិ) | នាក់ | ៥ x ៣ | ៨.០០០ | ១២០.០០០ |
| ៤ | មធ្យោបាយធ្វើដំណើរសម្រាប់សមាជិកម្នាក់ៗនៃ គ.ក.ន.ក ចុះរៀបចំកិច្ចប្រជុំជាមួយអាណាព្យាបាលកុមារតូច ដើម្បីជំរុញឲ្យកុមារមករៀនទៀងទាត់នៅមត្តេយ្យសិក្សាសហគមន៍ (៥ភូមិ) | នាក់ | ៥ x ២ | ៨.០០០ | ៨០.០០០ |
| ៥ | អាហារសម្រន់សម្រាប់អ្នកចូលរួមប្រជុំមត្តេយ្យសិក្សាសហគមន៍ជាមួយអាណាព្យាបាល (៥ភូមិ) | ប្រជុំ | ៥ x ២ | ១០.០០០ | ១០០.០០០ |
| ៦ | មធ្យោបាយធ្វើដំណើរសម្រាប់សមាជិកម្នាក់នៃ គ.ក.ន.ក ចូលរួមប្រជុំប្រចាំត្រីមាស និងប្រចាំឆ្នាំនៅថ្នាក់ស្រុក | នាក់ | ៤ | ៨.០០០ | ៣២.០០០ |
| ៧ | លទ្ធកម្ម (ចំណាយទិញឧបករណ៍ និងសម្ភារៈនានា ដូចជា | មត្តេយ្យសិក្សា | ៥ | ២០០.០០០ | ១.០០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | (១).ទិញសម្ភារៈអប់រំ (២).ទិញសម្ភារៈសម្រាប់កែលម្អទឹកស្អាត និងលើកកម្ពស់អនាម័យ រួមមានអាងស្តុកទឹក ពាងធុងចម្រោះទឹក កំសៀវទឹក ថ្នាំគ្រាប់ក្លរ៉ាមីន ប៊ីដុងទឹក ធុងដបទឹក បង្គន់ ទីតាំងចានលាងសំអាតដៃ និងសាប៊ូដុំ សម្រាប់មណ្ឌលសិក្សាសហគមន៍) | សហគមន៍ | | | |
| ៨ | លុយបម្រុងសម្រាប់មត្តេយ្យសិក្សាសហគមន៍ | មត្តេយ្យសិក្សាសហគមន៍ | ៥ | ៤០០.០០០ | ២.០០០.០០០ |
| **សរុបតម្រូវការ** | | | | | **៥.៥៦៤.០០០** |
| **សរុបមានជាក់ស្តែង** | | | | | **២.០០០.០០០** |
| **សរុបសំណើក្នុងពេលប្រជុំកៀរគរធនធាន** | | | | | **៣.៥៦៤.០០០** |

**កំណត់សម្គាល់** ៖ ឃុំ សង្កាត់ត្រូវបានលើកទឹកចិត្តធ្វើទំនាក់ទំនង និងចរចារកធនធានបន្ថែមទៀតពីមន្ទីរសុខាភិបាលខេត្ត និងស្រុកប្រតិបត្តិ ដើម្បីធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល។

### ៥- កែលម្អស្ថានភាពទឹកស្អាត និងលើកកម្ពស់អនាម័យក្នុងសហគមន៍

តាមសេចក្តីរាយការណ៍បានឲ្យដឹងថា កាលពីឆ្នាំមុន ករណីរាករូសចំនួន២០០ករណីត្រូវបានទទួលការព្យាបាលនៅក្នុងមណ្ឌលសុខភាព។ ដោយឃើញតួលេខខ្ពស់បែបនេះ គ.ក.ន.ក បានសម្រេចចិត្តជ្រើសរើសយកវិធានការមួយចំនួនដើម្បីកែប្រែស្ថានភាពលាងសម្អាតក្នុងឃុំអំពិលឲ្យប្រសើរជាងមុន។

| **ល.រ** | **សកម្មភាពដែលអាចអនុវត្តបាន** | **ឯកតា** | **បរិមាណ** | **តម្លៃឯកតា (រៀល)** | **តម្លៃសរុប (រៀល)** |
|---|---|---|---|---|---|
| ប្រារព្ធទិវាទឹកពិភពលោក ថ្ងៃទី២២ ខែមីនា ទិវាលាងសម្អាតដៃ ថ្ងៃទី១៥ ខែតុលា និងទិវាអនាម័យ ថ្ងៃទី១៣ ខែវិច្ឆិកា និងគំនិតផ្តួចផ្តើមឲ្យមានការយល់ដឹងផ្សេងៗទៀត | | | | | |
| ១ | មធ្យោបាយធ្វើដំណើរសម្រាប់សមាជិក គ.ក.ន.ក ពីរនាក់(រួមមាន អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ) សម្រាប់ដឹកនាំការប្រារព្ធទិវាលើកកម្ពស់ការយល់ដឹង (៣ដង x ៥ភូមិ) និងគាំទ្រការចុះពិនិត្យតាមដាន ប្រចាំខែ (១០ដង x ៥ភូមិ) | នាក់ | ៦៥ | ៨.០០០ | ៥២០.០០០ |
| ២ | អាហារសម្រន់សម្រាប់អ្នកភូមិក្នុងការប្រារព្ធទិវាលើកកម្ពស់ការយល់ដឹងនៅថ្នាក់ភូមិ សម្រាប់០៣ដង (៥ភូមិ) | ភូមិ | ១៥ | ១២.០០០ | ១៨០.០០០ |
| កែលម្អស្ថានភាពទឹកស្អាត និងលើកកម្ពស់អនាម័យតាមគ្រួសារដែលងាយរងគ្រោះ (កំណត់រកឃើញតាមរយៈអូរ៉ីស៊ី ផែនទីសេវាសង្គម ឬប័ណ្ណសម្គាល់ជនក្រីក្រ) មណ្ឌលសុខភាព មត្តេយ្យសិក្សា និងតាមសាលារៀននានា | | | | | |
| ១ | ចុះកិច្ចសន្យាជាមួយអង្គការសង្គមស៊ីវិលដើម្បីគាំទ្រការចលនាសហគមន៍ ដើម្បីកែលម្អទឹកស្អាតតាមផ្ទះជនងាយរងគ្រោះបំផុត (៥ភូមិ) | អង្គការសង្គមស៊ីវិល | ៥ | ៤៣៦.០០០ | ២.១៨០.០០០ |
| ២ | គាំទ្រដល់ប្រតិបត្តិការ ការថែរក្សា ជួសជុល និងការងារលទ្ធកម្មផ្សេងៗ ដើម្បីកែលម្អទឹកស្អាត និងលើកកម្ពស់អនាម័យ រួមមាន (ក).ការជួសជុល អណ្តូងទឹក អាង ស្តុកទឹក ពាងធុងចម្រោះទឹក បង្គន់អនាម័យ និងទីតាំងចានលាងសំអាតដៃ (ខ).ការផ្តល់អាងស្តុកទឹក ពាងធុង ចម្រោះទឹក កំសៀវទឹក ថ្នាំគ្រាប់ក្លរ៉ាមីន ប៊ីដុងទឹក ធុង ដបទឹក បង្គន់អនាម័យ ទីតាំងចានលាងសំអាតដៃ សាប៊ូដុំ នៅតាមមត្តេយ្យសហគមន៍ ឬ | ថ្នាក់មត្តេយ្យ ឬ សាលារៀន | ៣ | ១.៤០០.០០០ | ៤.២០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | សាលារៀនចំនួន០៣កន្លែង | | | | |
| ៣ | គាំទ្រដល់ប្រតិបត្តិការ ការថែរក្សាជួសជុល និងការងារលទ្ធកម្មផ្សេងៗ ដើម្បីកែលម្អទឹកស្អាត និងលើកកម្ពស់អនាម័យនៅតាមមណ្ឌលសុខភាព រួមមាន (ក).ការជួសជុលអណ្តូងទឹក អាងស្តុកទឹក ពាងទឹក ធុងចម្រោះទឹក បង្គន់អនាម័យ និងទីតាំងចានលាងសំអាតដៃ (ខ).ការផ្តល់អាងស្តុកទឹក ពាងទឹក ធុងចម្រោះទឹក កំសៀវទឹក ថ្នាំគ្រាប់ក្លរ៉ាមីន ប៊ីដុងទឹក ដបទឹក បង្គន់អាម័យ ទីតាំងចានលាងសំអាតដៃ សាប៊ូដុំ | មណ្ឌលសុខភាព | ១ | ៨០០.000 | ៨០០.000 |
| **សរុបតម្រូវការ** | | | | | **៧.៨៨០.000** |
| **សរុបជាក់ស្តែង** | | | | | **៨០០.000** |
| **សរុបសំណើក្នុងពេលប្រជុំកៀរគរធនធាន** | | | | | **៧.០៨០.000** |

## ទម្រង់ទី៥

រាជធានី ខេត្ត...................................
ក្រុង ស្រុក ខណ្ឌ ...............................
ឃុំ សង្កាត់ ......................................

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

### ផែនការថវិកាសម្រាប់ខែ....... ឆ្នាំ២០១២
### ដើម្បីលើកកម្ពស់ការអភិវឌ្ឍសង្គមប្រកបដោយសមធម៌

| ល.រ | ចំណាយ | ឯកតា | បរិមាណ | តម្លៃឯកតា(រៀល) | សរុប(រៀល) |
|---|---|---|---|---|---|
| ១ | ធានាថាមានការចុះបញ្ជីអត្រានុកូលដ្ឋានបានត្រឹមត្រូវ | | | | |
| ១.១ | អាហារសម្រន់ | ភូមិ | ២ | ១២.០០០ | ២៤.០០០ |
| ១.២ | សម្ភារៈ | ភូមិ | ២ | ៨.០០០ | ១៦.០០០ |
| **សរុបរង** | | | | | **៤០.០០០** |
| ២ | ការបង្ការ និងការឆ្លើយតបការព្រួយបារម្ភកិច្ចការពារកុមារ ក្នុងចំណោមកុមារដែលងាយរងគ្រោះជាងគេបំផុត និងគ្រួសាររបស់គេ | | | | |
| ២.១ | ផ្គត់ផ្គង់សម្ភារៈសិក្សា | ក្មេង | ២ | ៤០.០០០ | ៨០.០០០ |
| ២.២ | ផ្តល់ការគាំទ្រដល់អ្នកពាក់ព័ន្ធ | ក្មេង | ៣ | ២៤.០០០ | ៧២.០០០ |
| **សរុបរង** | | | | | **១៥២.០០០** |
| ៣ | ធានាថាគុណភាពសេវាកម្មសុខភាព និងអាហារូបត្ថម្ភបានទៅដល់ជនងាយរងគ្រោះបានទាន់ពេលវេលា | | | | |
| ៣.១ | អាហារសម្រាប់ស្ត្រីមានផ្ទៃពោះ | ស្ត្រី | ៣ | ៨.០០០ | ២៤.០០០ |
| ៣.២ | ថ្លៃធ្វើដំណើរសម្រាប់ការពិនិត្យសុខភាពមុនពេលសម្រាលកូន ការសម្រាលកូនដោយសុវត្ថិភាព ចុះពិនិត្យស្ថានភាព និងសួរសុខទុក្ខស្ត្រីដែលទើបសម្រាលកូន | ស្ត្រី | ៣ | ៨.០០០ | ២៤.០០០ |
| **សរុបរង** | | | | | ៤៨.០០០ |
| ៤ | ការវិនិយោគនៅមត្តេយ្យសិក្សាសហគមន៍ | | | | |
| ៤.១ | ផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូ | នាក់ | ១ | ៤៨.០០០ | ៤៨.០០០ |
| ៤.២ | ការប្រជុំរវាងមាតាបិតា និងមត្តេយ្យសិក្សាសហគមន៍ | ប្រជុំ | ១ | ១០.០០០ | ១០.០០០ |
| **សរុបរង** | | | | | **៥៨.០០០** |
| ៥ | កែលម្អនូវស្ថានភាពអនាម័យទឹកស្អាតនៅក្នុងសហគមន៍ | | | | |
| ៥.១ | បង្គន់អនាម័យក្នុងសាលារៀន | បង្គន់ | ១ | ១២៨.០០០ | ១២៨.០០០ |
| **សរុបរង** | | | | | **១២៨.០០០** |
| ៦ | ផ្សព្វផ្សាយអប់រំ និងលើកកម្ពស់ការយល់ដឹងអំពីសមភាពយេនឌ័រ និងហិង្សាក្នុងគ្រួសារ | | | | |
| ៦.១ | ប្រាក់ឧបត្ថម្ភសម្រាប់ គ.ក.ន.ក | ប្រជុំ | ១ | ១០.០០០ | ១០.០០០ |

| | | | | | |
|---|---|---|---|---|---|
| ៦.២ | ថ្លៃធ្វើដំណើរ | ប្រជុំ | ៣ | ៨.០០០ | ២៤.០០០ |
| ៦.៣ | អាហារសម្រន់អ្នកចូលរួម | ប្រជុំ | ១ | ៨.០០០ | ១៧៦.០០០ |
| ៦.៤ | សម្ភារៈផ្សព្វផ្សាយ | ប្រជុំ | ១ | ២០.០០០ | ២០.០០០ |
| **សរុបរង** | | | | | **២៥០.០០០** |
| ៧ | ផ្សព្វផ្សាយលើកកម្ពស់ចំណេះដឹងពីសុខភាពបន្តពូជ | | | | |
| ៧.១ | ប្រាក់ឧបត្ថម្ភសម្រាប់ គ.ក.ន.ក | ប្រជុំ | ១ | ១០.០០០ | ៣០.០០០ |
| ៧.២ | ថ្លៃធ្វើដំណើរ | ប្រជុំ | ១ | ៨.០០០ | ២៤.០០០ |
| ៧.៣ | អាហារសម្រន់អ្នកចូលរួម | ប្រជុំ | ១ | ៨.០០០ | ១៧៦.០០០ |
| ៧.៤ | សម្ភារៈផ្សព្វផ្សាយ | ប្រជុំ | ១ | ២០.០០០ | ២០.០០០ |
| **សរុបរង** | | | | | **២៥០.០០០** |
| ៨ | ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការឆ្លើយតប | | | | |
| ៨.១ | សម្ភារៈ | ប្រជុំ | ១ | ៥.០០០ | ៥.០០០ |
| **សរុបរង** | | | | | **៥.០០០** |
| ៩ | ចុះត្រួតពិនិត្យសកម្មភាពប្រតិបត្តិ | | | | |
| ៩.១ | ការធ្វើដំណើរ | នាក់ | ៤ | ២០.០០០ | ៨០.០០០ |
| **សរុបរង** | | | | | **៨០.០០០** |
| ១០ | កិច្ចប្រជុំ គ.ក.ន.ក សម្រាប់ខែឧសភា | | | | |
| ១០.១ | អាហារសម្រន់ | ប្រជុំ | ១ | ១០.០០០ | ១០.០០០ |
| ១០.២ | សម្ភារៈ | ប្រជុំ | ១ | ៨.០០០ | ៨.០០០ |
| **សរុបរង** | | | | | ១៨.០០០ |
| **សរុប** | | | | | **១.០២៩.០០០** |

*ថ្ងៃទី.......ខែ.......ឆ្នាំ..........* *ថ្ងៃទី.......ខែ.......ឆ្នាំ..........*

**មេឃុំ សង្កាត់** **អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**

**<u>កំណត់សម្គាល់</u>** ៖ សូមមើលសេចក្តីណែនាំលេខ២២០ ស.ជ.ណ គ.ជ.អ.ប ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ ស្តីអំពីក្របខ័ណ្ឌសកម្មភាពសេវាសង្គមដែលមានភ្ជាប់នៅឧបសម្ព័ន្ធ។

## ៦. ការរៀបចំ និងការដោះស្រាយគ្រោះអាសន្ន

ឃុំអំពិលចង់ពង្រឹងភាពធន់សម្រាប់សហគមន៍របស់គេ ក្នុងការត្រៀមបង្ការ និងដោះស្រាយទៅនឹងគ្រោះអាសន្ន ជាពិសេសក្នុងករណីមានគ្រោះទឹកជំនន់កើតឡើង។ សមាជិក គ.ក.ន.ក បានកំណត់ទីទួលសុវត្ថិភាពដូចជា វត្តអារាម ប៉ុន្តែវត្តអារាមនោះត្រូវការត្រៀមរៀបចំសម្ភារៈមួយចំនួន ដូចជា ការសាងសង់បង្គន់អនាម័យថ្មី ការជួសជុលបង្គន់អនាម័យ ទៅតាមកម្រិតស្តង់ដាបង្គន់០១សម្រាប់មនុស្ស២៥នាក់។

| ល.រ | សកម្មភាពដែលអាចអនុវត្តបាន | ឯកតា | បរិមាណ | តម្លៃឯកតា | តម្លៃសរុប |
|---|---|---|---|---|---|
| ការរៀបចំសហគមន៍សម្រាប់គ្រោះអាសន្ន | | | | | |
| ១ | លើកកម្ពស់ការយល់ដឹងពីការយកចិត្តទុកដាក់ជាពិសេសដល់ជនងាយរងគ្រោះបំផុត ពីការរៀបចំកញ្ចប់ស្បៀងអាហារសង្គ្រោះបន្ទាន់ ការរក្សាទុកដាក់ឯកសារសំខាន់ៗឱ្យបានគង់វង្ស ទីកន្លែងដែលត្រូវទៅស្នាក់នៅបណ្តោះអាសន្ន និងនរណាដែលត្រូវទាក់ទងករណីមានគ្រោះអាសន្ន។ល។ | នាក់ | ០៥ | ៨.០០០ | ៤០.០០០ |
| ២ | អាហារសម្រន់សម្រាប់វគ្គផ្សព្វផ្សាយនៅថ្នាក់ភូមិ (៥ភូមិ) | ភូមិ | ០៥ | ១២.០០០ | ៦០.០០០ |
| ៣ | ប៉ាន់ប្រមាណចំនួនស្ត្រីមានផ្ទៃពោះ យុវវ័យដែលត្រូវការសេវាសុខភាព (ការពិនិត្យផ្ទៃពោះមុនសម្រាល ការសម្រាលកូនដោយសុវត្ថិភាព ការពិនិត្យសុខភាពក្រោយសម្រាល និងការតាមដានសុខភាព) ការកំណត់ចំណុចគ្រោះថ្នាក់សំខាន់ៗ និងស្វែងរកវិធីកាត់បន្ថយហានិភ័យ ការប៉ាន់ប្រមានកម្រិតកម្ពស់ទឹក ការចុះវាយតម្លៃកម្រិតត្រៀមបម្រុងតាមគ្រួសារ តាមមត្តេយ្យសាលា សាលារៀន មណ្ឌលសុខភាព និងតាមវត្តអារាម។ល។ | ភូមិ | ០៥ | ១២.០០០ | ៦០.០០០ |
| ៤ | រៀបចំការជម្លៀស ទីសុវត្ថិភាព (វត្ត) ដូចជា ៖<br>- រៀបចំទុកដាក់ជាមុននូវសាប៊ូ ធុងចម្រោះទឹក តង់ ធុងទឹក សម្ភារៈរៀនសូត្រ សម្ភារៈលេងកំសាន្ត ចំណីសត្វ។ល។<br>- ជួសជុលអាងស្តុកទឹកនៅក្នុងវត្ត (ទីទួលសុវត្ថិភាព)<br>- ជួសជុលបង្គន់អនាម័យនៅក្នុងវត្ត (ទីទួលសុវត្ថិភាព)<br>- សាងសង់បង្គន់អនាម័យថ្មីចំនួន០៣ (ធ្វើតាមស្តង់ដា) | វត្ត | ០៥ | ១.៤០០.០០០ | ១.៤០០.០០០ |
| ការប៉ាន់ប្រមាណស្ថានការណ៍ដែលមានផលប៉ះពាល់ទៅលើប្រជាពលរដ្ឋ | | | | | |
| ១ | ធ្វើការប៉ាន់ប្រមាណពីស្ថានការណ៍ដែលមានផលប៉ះពាល់ទៅលើប្រជាជននៅក្នុងរយៈពេល៧២ម៉ោងដំបូង | នាក់ | ០៥ | ១២.០០០ | ៦០.០០០ |
| ការឆ្លើយតបគ្រោះអាសន្នដែលមានផលប៉ះពាល់ទៅលើប្រជាជន | | | | | |
| ១ | រៀបចំក្រុមគ្រូពេទ្យចល័តដោយសហការជាមួយមណ្ឌលសុខភាព | នាក់ | ០៥ | ៣៦.០០០ | ១៨០.០០០ |
| ២ | បែងចែកសម្ភារៈសំខាន់ចាំបាច់នានា | នាក់ | ២០ | ២០០.០០០ | ៤.០០០.០០០ |
| ៣ | ដឹកជញ្ជូនប្រជាជនដែលរងផលប៉ះពាល់ទៅកាន់ទីទួលសុវត្ថិភាព | ទូក | ០១ | ២០.០០០ | ២០.០០០ |
| **សរុប** | | | | | ៥.៧៦០.០០០ |
| **សរុបដែលមាន** | | | | | ៨០០.០០០ |
| **សរុបសំណើក្នុងប្រជុំកៀរគរធនធាន** | | | | | ៤.៩៦០.០០០ |

## ខ. សកម្មភាពសេវាសង្គមផ្សេងទៀត

ក្រៅពីសកម្មភាពសេវាសង្គមដែលបានលើកឡើងនៅក្នុងករណីសិក្សានៅឃុំអំពិលខាងលើនេះ ក្នុងការរៀបចំផែនការសកម្មភាព និងផែនការថវិការបស់ខ្លួន គ.ក.ន.ក គួរយកចិត្តទុកដាក់ផងដែរទៅលើការលើកកម្ពស់ការប្រើប្រាស់សេវាសុខភាពបន្តពូជ ការពន្យារកំណើត ការទប់ស្កាត់ការឆ្លងរីករាលដាលមេរោគអេដស៍ ការធ្វើចំណាកស្រុក ការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ និងការឆ្លើយតបនឹងបញ្ហារបស់យុវវ័យ និងមនុស្សចាស់ ជាដើម។

ឧទាហរណ៍ ករណី គ.ក.ន.ក កត់សម្គាល់ឃើញថា ចំនួនអ្នកមកទទួលសេវាពន្យារកំណើតមានការធ្លាក់ចុះ ឬមានការឆ្លងមេរោគអេដស៍ថ្មីៗកើតឡើង ឬមានការកើនឡើងនូវអំពើហិង្សាក្នុងគ្រួសារ ឬបញ្ហាយុវវ័យទាក់ទងនឹងការប្រើប្រាស់គ្រឿងញៀន សុខភាពបន្តពូជ ការធ្វើចំណាកស្រុកទាំងក្នុង និងក្រៅប្រទេស នៅក្នុងមូលដ្ឋានរបស់ខ្លួន គ.ក.ន.ក ត្រូវសហការជាមួយអ្នកពាក់ព័ន្ធដើម្បីអប់រំសហគមន៍តាមរយៈការរៀបចំផែនការសកម្មភាព និងផែនការថវិកា ដូចខាងក្រោម ៖

| ល.រ | សកម្មភាពដែលអាចអនុវត្តបាន | ឯកតា | បរិមាណ | តម្លៃឯកតា (រៀល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|
| *សកម្មភាពទី១* ៖ ផ្សព្វផ្សាយអប់រំ និងលើកកម្ពស់ចំណេះដឹងពីសមភាពយេនឌ័រ អំពើហិង្សាក្នុងគ្រួសារ | | | | | |
| ១ | ប្រាក់ឧបត្ថម្ភសម្រាប់ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ក្រុមប្រឹក្សាឃុំ ធ្វើការចុះផ្សព្វផ្សាយ និងអប់រំអំពី ៖<br>- ការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ<br>- ការលើកកម្ពស់សមភាពយេនឌ័រ ការចូលរួមរបស់ស្ត្រី | ម្នាក់/០១ដង | ០៣នាក់ | ១០.០០០ | ៣០.០០០ |
| ២ | ថ្លៃមធ្យោបាយធ្វើដំណើរសម្រាប់ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និងក្រុមប្រឹក្សាឃុំ | ម្នាក់/០១ដង | ០៣នាក់ | ៨.០០០ | ២៤.០០០ |
| ៣ | អាហារសម្រន់សម្រាប់អ្នកចូលរួម | ០១ដង | ៤៤នាក់ | ៤.០០០ | ១៧៦.០០០ |
| ៤ | សម្ភារៈសម្រាប់ការផ្សព្វផ្សាយ (ផ្ទាំងក្រដាស ហ្វឺត និងសម្ភារៈផ្សេងៗទៀតដែលចាំបាច់) | ០១ដង | ០១ដង | ២០.០០០ | ២០.០០០ |
| **សរុបរង** | | | | | **២៥០.០០០** |
| *សកម្មភាពទី២* ៖ ផ្សព្វផ្សាយលើកកម្ពស់ចំណេះដឹងពីសុខភាពបន្តពូជ | | | | | |
| ១ | ប្រាក់ឧបត្ថម្ភសម្រាប់ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និងក្រុមប្រឹក្សាឃុំ ដើម្បីចុះផ្សព្វផ្សាយ និងអប់រំអំពី ៖<br>- ការថែរក្សាសុខភាពមុន និងក្រោយសម្រាល និងការសម្រាលនៅមណ្ឌលសុខភាព<br>- ការពន្យារកំណើត និងការប្រើប្រាស់មធ្យោបាយពន្យារកំណើត | ម្នាក់/០១ដង | ០៣នាក់ | ១០.០០០ | ៣០.០០០ |
| ២ | ថ្លៃមធ្យោបាយធ្វើដំណើរសម្រាប់ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និងក្រុមប្រឹក្សាឃុំ | ម្នាក់/០១ដង | ០៣នាក់ | ៨.០០០ | ២៤.០០០ |
| ៣ | អាហារសម្រន់សម្រាប់អ្នកចូលរួម | ០១ដង | ៤៤នាក់ | ៤.០០០ | ១៧៦.០០០ |
| ៤ | សម្ភារៈសម្រាប់ការផ្សព្វផ្សាយ (ផ្ទាំងក្រដាស ហ្វឺត និងសម្ភារៈផ្សេងៗទៀតដែលចាំបាច់) | ០១ដង | ០១ដង | ២០.០០០ | ២០.០០០ |

| | | | | | |
|---|---|---|---|---|---|
| **សរុបរង** | | | | | **២៥០ ០០០** |
| *សកម្មភាពទី៣* ៖ ផ្សព្វផ្សាយលើកកម្ពស់ចំណេះដឹងពីការទប់ស្កាត់ការឆ្លង និងការរីករាលដាលមេរោគអេដស៍ | | | | | |
| ១ | ប្រាក់ឧបត្ថម្ភសម្រាប់ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និងក្រុមប្រឹក្សាឃុំ ដើម្បីចុះផ្សព្វផ្សាយ និងអប់រំអំពី ៖<br>- ការថែទាំសុខភាពដល់អ្នកផ្ទុកមេរោគអេដស៍<br>- ការទប់ស្កាត់ការឆ្លងមេរោគអេដស៍<br>- ការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ | ម្នាក់/០១ដង | ០៣នាក់ | ១០.០០០ | ៣០.០០០ |
| ២ | ថ្លៃមធ្យោបាយធ្វើដំណើរសម្រាប់ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និងក្រុមប្រឹក្សាឃុំ | ម្នាក់/០១ដង | ០៣នាក់ | ៨.០០០ | ២៤.០០០ |
| ៣ | អាហារសម្រន់សម្រាប់អ្នកចូលរួម | ០១ដង | ៤៤នាក់ | ៤.០០០ | ១៧៦.០០០ |
| ៤ | សម្ភារៈសម្រាប់ការផ្សព្វផ្សាយ (ផ្ទាំងក្រដាស ហ្វឺត និងសម្ភារៈផ្សេងៗទៀតដែលចាំបាច់) | ០១ដង | ០១ដង | ២០.០០០ | ២០.០០០ |
| **សរុបរង** | | | | | **២៥០.០០០** |
| *សកម្មភាពទី៤* ៖ ផ្សព្វផ្សាយលើកកម្ពស់ចំណេះដឹងពីបញ្ហារបស់យុវជន | | | | | |
| ១ | ប្រាក់ឧបត្ថម្ភសម្រាប់ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និងក្រុមប្រឹក្សាឃុំ ដើម្បីចុះផ្សព្វផ្សាយ និងអប់រំអំពី ៖<br>- ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការស្វែងរកការងារធ្វើ<br>- សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ<br>- ការប្រើប្រាស់ថ្នាំញៀន និងគ្រឿងស្រវឹង<br>- ក្រុមក្មេងទំនើង | ម្នាក់/០១ដង | ០៣នាក់ | ១០.០០០ | ៣០.០០០ |
| ២ | ថ្លៃមធ្យោបាយធ្វើដំណើរសម្រាប់ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និងក្រុមប្រឹក្សាឃុំ | ម្នាក់/០១ដង | ០៣នាក់ | ៨.០០០ | ២៤.០០០ |
| ៣ | អាហារសម្រន់សម្រាប់អ្នកចូលរួម | ម្នាក់/០១ដង | ៤៤នាក់ | ៤.០០០ | ១៧៦.០០០ |
| ៤ | សម្ភារៈសម្រាប់ការផ្សព្វផ្សាយ (ផ្ទាំងក្រដាស ហ្វឺត និងសម្ភារៈផ្សេងៗទៀតដែលចាំបាច់) | ០១ដង | ០១ដង | ២០.០០០ | ២០.០០០ |
| **សរុបរង** | | | | | **២៥០ ០០០** |
| **សរុប** | | | | | **១.០០០.០០០** |

| | | | | | |
|---|---|---|---|---|---|
| *សេវាសង្គ្រោះបន្ទាន់ និងការផ្តល់សេវាសង្គមផ្សេងៗទៀតដើម្បីជួយដល់ស្ត្រីដែលងាយរងគ្រោះ* | | | | | |
| ១ | ចេញថ្លៃធ្វើដំណើរបន្ទាន់ជូនស្ត្រីក្រីក្រមានផ្ទៃពោះ ទៅសម្រាលនៅមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព | ០១ដង | ០១នាក់ | ៨០.០០០ | ៨០.០០០ |
| ២ | គាំទ្រអាហារសម្រាប់ស្ត្រីក្រីក្រឆ្លងទន្លេសម្រាកនៅមណ្ឌលសុខភាព (ប្រសិនបើគ្មានប័ណ្ណក្រីក្រ) | ០៥ថ្ងៃ | ០១ថ្ងៃ | ១.២០០០ | ៦០.០០០ |
| ៣ | គាំទ្រសម្ភារៈសម្រាលសម្រាប់ស្ត្រីក្រីក្រឆ្លងទន្លេ និងសម្រាកនៅមណ្ឌលសុខភាព (ប្រសិនបើគ្មានប័ណ្ណក្រីក្រ) | ០១ដង | ០១ដង | ២០.០០០ | ២០.០០០ |
| ៤ | ចេញថ្លៃធ្វើដំណើរដល់ស្ត្រី និងកុមារដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ដើម្បីទទួលបានសេវាសុខភាព និងអន្តរាគមន៍នានាពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ | ០១ដង | ០១នាក់ | ៨០.០០០ | ៨០.០០០ |
| **សរុប** | | | | | **២៤០ ០០០** |

## ៥.២. ការកៀរគរធនធាន

ការកៀរគរធនធានជាកិច្ចការសំខាន់មួយរបស់ គ.ក.ន.ក។ សមាជិក គ.ក.ន.ក ម្នាក់ៗចាំបាច់ត្រូវកៀរគរធនធាន (បច្ចេកទេស ហិរញ្ញវត្ថុ និងមនុស្ស) ដើម្បីគាំទ្រការអនុវត្តឲ្យបានពេញលេញនូវផែនការសកម្មភាពក្នុងគោលបំណងឲ្យទទួលបាននូវលទ្ធផលប្រសើរបំផុតដល់ជនដែលងាយរងគ្រោះ។

ការកៀរគរធនធានរួមមាន ការចែកព័ត៌មានពីស្ថានភាពរបស់ជនដែលងាយរងគ្រោះបំផុត ទៅដល់ដៃគូអភិវឌ្ឍន៍ដែលធ្វើការនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងធ្វើសំណើសុំមូលនិធិបន្ថែមដើម្បីគាំទ្របញ្ហាដែលបានកំណត់រួច។ ឧទាហរណ៍ ការកៀរគរអាចមានទាំងការអញ្ជើញអង្គការនានាដែលធ្វើការលើផ្នែកទឹក និងអនាម័យ ដើម្បីជួយធ្វើការកែលម្អការអនុវត្តអនាម័យ ដូចជា ការលាងដៃនឹងសាប៊ូ និងការប្រើប្រាស់បង្គន់អនាម័យ ការទទួលបានទឹកស្អាត។ គ.ក.ន.ក អាចកៀរគរធនធានពីប្រភពផ្សេងៗក្រៅពីមូលនិធិឃុំ សង្កាត់ដូចជា ៖

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់ក្រុង ស្រុក ខណ្ឌ
- ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលមាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- អង្គការជាតិ និងអង្គការអន្តរជាតិ
- ធនធានក្នុងសហគមន៍
- សប្បុរសជន។

ការបង្កើត និងការកសាងទំនាក់ទំនង គឺជាកិច្ចការសំខាន់ក្នុងការទាក់ទាញស្ថាប័នទាំងនោះឲ្យជួយផ្ដល់ការគាំទ្រទាំងធនធាន ថវិកា សម្ភារៈ ធនធានមនុស្ស និងធនធានដទៃផ្សេងទៀត។

គ.ក.ន.ក ត្រូវចងក្រងទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធដល់បញ្ហាស្ត្រី និងកុមារ និងជនងាយរងគ្រោះព្រមទាំងការសង្ខេបពីបញ្ហា និងមូលហេតុពាក់ព័ន្ធ និងការបង្ហាញពីបញ្ហាទាំងនោះឲ្យបានជាក់លាក់ មុនពេលដែល គ.ក.ន.ក ទៅរកអង្គការនានាឲ្យជួយគាំទ្រ។

# ៦. ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងរបាយការណ៍

## ៦.១. ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃជាកិច្ចការមួយយ៉ាងសំខាន់របស់ គ.ក.ន.ក ក្នុងការជួយក្រុមប្រឹក្សាដើម្បីធានាថា រាល់តម្រូវការជនងាយរងគ្រោះបំផុតត្រូវបានឆ្លើយតប ហើយដោះស្រាយបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព និងសមធម៌។

គោលបំណងនៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃរបស់ គ.ក.ន.ក គឺ ៖

- ធានាបាននូវការផ្តល់សេវាសង្គមប្រកបដោយគុណភាព និងសមធម៌
- វាស់វែងអំពីលទ្ធផលរីកចម្រើន និងប្រសិទ្ធភាពនៃការអនុវត្តមុខងាររបស់ គ.ក.ន.ក
- ជួយឲ្យ គ.ក.ន.ក រាយការណ៍អំពីការរីកចម្រើនដល់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន និងអ្នកពាក់ព័ន្ធដទៃទៀត

មន្ត្រីបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវជួយមេឃុំ ចៅសង្កាត់ និង គ.ក.ន.ក ក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃដំណើរការអនុវត្តសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គមដែលទាក់ទងនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ លទ្ធភាពទទួលបាននូវអនាម័យដែលរួមមានការលើកកម្ពស់ការលាងដៃនឹងសាប៊ូ និងទឹកស្អាត សមភាពយេនឌ័រ ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការឆ្លើយតបនឹងស្ថានភាពអាសន្នដូចដែលបានចែងក្នុងផែនការសកម្មភាពប្រចាំឆ្នាំ។

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃអាចធ្វើឡើងតាមរយៈសកម្មភាពដូចខាងក្រោម ៖

- តាមដានត្រួតពិនិត្យលើសូចនាករ
- តាមដានត្រួតពិនិត្យសកម្មភាព និងលទ្ធផលការងារ
- រៀបចំរបាយការណ៍ប្រចាំខែ (ទម្រង់របាយការណ៍ផ្សេងៗដែលពាក់ព័ន្ធនឹងសេវាសង្គម) និងរបាយការណ៍រីកចម្រើនស្តីពីការអនុវត្តសកម្មភាព (ទម្រង់ទី៦) និងរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ (ទម្រង់ទី៧)
- រាយការណ៍អំពីភាពរីកចម្រើនស្តីពីការអនុវត្តថវិកាជូន គ.ក.ន.ក និងក្រុមប្រឹក្សាឃុំ សង្កាត់ និងលើកសំណើដល់ គ.ក.ន.ក និងក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្តសកម្មភាពជាក់លាក់ក្នុងការដោះស្រាយបញ្ហានានាឲ្យមានប្រសិទ្ធភាព
- សហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការវាយតម្លៃផលប៉ះពាល់នៃការអភិវឌ្ឍផ្នែកសង្គមប្រកបដោយសមធម៌។

ដើម្បីជួយឲ្យ គ.ក.ន.ក អនុវត្តសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព គ.ក.ន.ក ចាំបាច់ត្រូវពិនិត្យអំពីការប្រើប្រាស់ថវិកា និងសកម្មភាពដែលបានអនុវត្តរួមទាំងវិភាគអំពីនិន្នាការនានាដែលទាក់ទងនឹងសូចនាករសង្គម (សូមមើលទម្រង់ទី៥ អំពីសូចនាករដើម្បីកែលម្អសេវាសង្គមប្រកបដោយសមធម៌)។

## ទម្រង់ទី៥

# តារាងសូចនាករអំពីសេវាសង្គមប្រកបដោយសមធម៌

*"អ្វីដែលយើងចង់វាស់វែង យើងត្រូវគ្រប់គ្រងវាឲ្យបាន"*

| អ្វីដែលយើងចង់ធ្វើឱ្យសម្រេចបាន | ធានាការចុះបញ្ជីអត្រានុកូលដ្ឋានឱ្យមានប្រសិទ្ធភាព |
|---|---|
| **សូចនាករ** | **សកម្មភាព** |
| - ចំនួនប្រជាពលរដ្ឋសរុបបែងចែកតាមភេទ<br>- ចំនួនមនុស្សពេញវ័យសរុបបែងចែកតាមភេទ និងអាយុ<br>- ចំនួនកុមារសរុបបែងចែកតាមភេទ និងអាយុ<br>- ចំនួនទារកទើបនឹងកើតដែលបានចុះបញ្ជីកំណើតនៅក្នុងរយៈពេល៣០ថ្ងៃ<br>- ចំនួនអាពាហ៍ពិពាហ៍ដែលបានចុះបញ្ជី (នៅឆ្នាំថ្មីៗនេះ)<br>- ចំនួនមរណភាពនៃទារកដែលបានចុះបញ្ជីមរណភាព (អាយុតិចជាង១ខែ)<br>- ចំនួនមរណភាពនៃកុមារដែលបានចុះបញ្ជីមរណភាព (អាយុតិចជាង១ឆ្នាំ)<br>- ចំនួនមរណភាពនៃកុមារដែលបានចុះបញ្ជីមរណភាព (អាយុតិចជាង៥ឆ្នាំ)<br>- ចំនួនមរណភាពនៃកុមារដែលបានចុះបញ្ជីមរណភាព (អាយុតិចជាង១៨ឆ្នាំ)<br>- ចំនួនមរណភាពនៃមាតានៅពេលមានផ្ទៃពោះ ឫសម្រាលកូនរួចបានចុះបញ្ជីមរណភាព<br>- ចំនួនមរណភាពនៃឪពុកដែលបានចុះបញ្ជីមរណភាព | ក. លើកកម្ពស់ការយល់ដឹងស្តីអំពីសារៈសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន រួមមាន ៖<br>- សិទ្ធិទទួលបានអត្តសញ្ញាណជាតិ (ចុះបញ្ជីកំណើត)<br>- សិទ្ធិត្រឹមត្រូវស្របច្បាប់<br>- សិទ្ធិទទួលបានការការពារ<br>- ការកសាងផែនការក្នុងការផ្តល់សេវាកម្ម<br>ខ. គាំទ្រកុមារ និងគ្រួសារដែលងាយរងគ្រោះបំផុត<br>- (សូមមើលតារាងខាងក្រោម) |

| អ្វីដែលយើងចង់ធ្វើឱ្យសម្រេចបាន | កិច្ចការពារ និងឆ្លើយតបចំពោះកុមាររងគ្រោះ និងកុមារងាយរងគ្រោះ និងគ្រួសារដែលងាយរងគ្រោះបំផុត |
|---|---|
| **សូចនាករ** | **សកម្មភាព** |
| - ចំនួនកុមារងាយរងគ្រោះដែលទទួលបានផលប្រយោជន៍តាមរយៈវិធានការការពារ (ផ្តល់អាហារ មធ្យោបាយធ្វើដំណើរ សម្លៀកបំពាក់ ឯកសណ្ឋានសាលា សម្ភារៈសិក្សា)<br>- ចំនួនស្ត្រី និងកុមារដែលធ្លាប់រងគ្រោះដោយអំពើហិង្សាបានបញ្ជូនទៅរកសេវាសមស្រប<br>- ចំនួនគ្រួសារដែលរងការប៉ះពាល់ដោយសារគ្រោះមហន្តរាយ និងទទួលបានជំនួយពីឃុំ សង្កាត់ | គាំទ្រកុមារ និងគ្រួសារដែលងាយរងគ្រោះបំផុត រួមមាន ៖<br>- ស្រង់បញ្ជីកុមារ និងគ្រួសារដែលងាយរងគ្រោះបំផុត (រួមទាំងគ្រួសារដែលរងការប៉ះពាល់ដោយគ្រោះមហន្តរាយ)<br>- រៀបចំសកម្មភាពគាំទ្រពីឃុំ សង្កាត់ ដល់គ្រួសារដែលងាយរងគ្រោះ (ទម្រង់ទី៤)<br>- ជូនដំណឹងដល់គ្រួសារអំពីសេចក្តីសម្រេចចិត្ត និងសកម្មភាពដែលបានស្នើសុំ<br>- រាយការណ៍អំពីសកម្មភាពដែលបានគាំទ្រក្នុងអំឡុងពេលកិច្ចប្រជុំគ.ក.ន.ក។ |

| **អ្វីដែលយើងចង់ធ្វើឲ្យសម្រេចបាន** | **ធានាឲ្យមានការផ្តល់ និងទទួលបាននូវសេវាសុខភាពនៅតាមមូលដ្ឋានទាន់ពេលវេលា និងប្រកបដោយគុណភាព** |
|---|---|
| **សូចនាករ** | **សកម្មភាព** |
| - ចំនួនស្ត្រីងាយរងគ្រោះដោយមានផ្ទៃពោះ ដែលឃុំ សង្កាត់គាំទ្រឲ្យទៅពិនិត្យសុខភាពមុនពេលសម្រាលនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ យ៉ាងហោចណាស់ចំនួន០២ដង<br>- ចំនួនស្ត្រីងាយរងគ្រោះដោយមានផ្ទៃពោះ ដែលឃុំ សង្កាត់គាំទ្រឲ្យទៅសម្រាលកូននៅមណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋ ឬឯកជន<br>- ចំនួនមាតាងាយរងគ្រោះមានកូនដំបូង និងទារកទើបនឹងកើត ដែលឃុំ សង្កាត់គាំទ្រឲ្យទៅពិនិត្យសុខភាពក្រោយពេលសម្រាលនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ យ៉ាងហោចណាស់ចំនួន០១ដង<br>- ចំនួនទារកដែលបានចាក់ថ្នាំបង្ការគ្រប់មុខ តាមរយៈដំណើរការកសាងផែនការខ្នាតតូច រវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមប្រឹក្សាឃុំ សង្កាត់<br>- ចំនួនមាតាដែលបំបៅកូនដោយទឹកដោះម្តាយភ្លាមៗបន្ទាប់ពីសម្រាលកូននៅមណ្ឌលសុខភាព<br>- ចំនួនទារកទើបនឹងកើតខ្វះទម្ងន់ ដែលគ្រួសារទទួលបានការគាំទ្រពីឃុំ សង្កាត់<br>- ចំនួនកុមារខ្វះអាហារូបត្ថម្ភដែលគ្រួសារទទួលបានជំនួយពីឃុំ សង្កាត់<br>- ចំនួនប្រជាពលរដ្ឋដែលមានជំងឺរ៉ាំរ៉ៃទទួលបានជំនួយពីឃុំ សង្កាត់<br>- ចំនួនកុមារមានអាយុក្រោម០៥ឆ្នាំ ទទួលថ្នាំទម្លាក់ព្រូនក្នុងរយៈពេល៦ខែចុងក្រោយ តាមរយៈដំណើរការកសាងផែនការខ្នាតតូច រវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមប្រឹក្សាឃុំ សង្កាត់<br>- ចំនួនកុមារមានអាយុក្រោម០៥ឆ្នាំ ទទួលបានជីវជាតិអាបន្ថែម ក្នុងរយៈពេល៦ខែចុងក្រោយ តាមរយៈដំណើរការកសាងផែនការខ្នាតតូច រវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមប្រឹក្សាឃុំ សង្កាត់<br>- ចំនួនករណីជំងឺរាកដែលបានរកឃើញ និងបានព្យាបាលទាន់ពេលដោយទឹកអូរ៉ាលីត និងគ្រាប់ថ្នាំជាតិដែក តាមរយៈការសម្របសម្រួលរវាងក្រុមគាំទ្រសុខភាពភូមិ និងបុគ្គលិកមណ្ឌលសុខភាព<br>- ចំនួនករណីជំងឺរលាកផ្លូវដង្ហើមធ្ងន់ដែលបានរកឃើញ និងបានព្យាបាលទាន់ពេលតាមរយៈកម្លាំងសម្របសម្រួលរវាងក្រុមគាំទ្រសុខភាពភូមិ និងបុគ្គលិកមណ្ឌលសុខភាព<br>- ចំនួនមណ្ឌលសុខភាពដែលឃុំ សង្កាត់បានផ្តល់គ្រែ ថ្លៃទឹក ថ្លៃអគ្គិសនី។ល។ | **ក. ពង្រឹងក្រុមគាំទ្រសុខភាពភូមិ រួមមាន ៖**<br>- ជំរុញក្រុមគាំទ្រសុខភាពភូមិក្នុងការប្រមូលព័ត៌មានចាំបាច់នានាពាក់ព័ន្ធនឹងបញ្ហាសុខភាពមាតា និងទារក<br>- លើកបញ្ហាពាក់ព័ន្ធនឹងសុខភាពមាតា និងទារក អាហារូបត្ថម្ភ ជូនគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងគ.ក.ន.ក<br>- រៀបចំកិច្ចប្រជុំជាមួយក្រុមគាំទ្រសុខភាពភូមិ ដើម្បីកំណត់ស្ត្រីមានផ្ទៃពោះដែលជាជនងាយរងគ្រោះបំផុត ដើម្បីទទួលបាននូវសេវាពិនិត្យផ្ទៃពោះមុនពេលសម្រាលកូននៅមណ្ឌលសុខភាព ការសម្រាលកូនប្រកបដោយសុវត្ថិភាព និងសេវាសុខភាពក្រោយពេលសម្រាលកូន សម្រាប់ម្តាយដែលទើបមានកូនជាលើកដំបូង<br>- ជំរុញ និងលើកទឹកចិត្តក្រុមគាំទ្រសុខភាពភូមិក្នុងការកៀរគរប្រជាពលរដ្ឋឲ្យបញ្ជូនកូនមកចាក់វ៉ាក់សាំងការពារឲ្យបានគ្រប់គ្រាន់ និងមកទទួលសេវាពិនិត្យផ្ទៃពោះមុនសម្រាលកូន និងពិនិត្យសុខភាពក្រោយពេលសម្រាលកូននៅមណ្ឌលសុខភាព<br>**ខ. លើកកម្ពស់ការយល់ដឹងអំពីសុខភាពមាតា និងទារក និងអាហារូបត្ថម្ភ រួមមាន ៖**<br>- សារៈសំខាន់នៃផែនការគ្រួសារ ការពន្យារកំណើត និងការប្រើប្រាស់មធ្យោបាយពន្យារកំណើត<br>- សារៈសំខាន់នៃការតាមដានការពិនិត្យផ្ទៃពោះមុន និងក្រោយសម្រាល<br>- ការព្យាបាលជំងឺរាក និងជំងឺរលាកផ្លូវដង្ហើមធ្ងន់ បានទាន់ពេលវេលា<br>- សារៈសំខាន់នៃការចាក់វ៉ាក់សាំងការពារជំងឺបានគ្រប់គ្រាន់<br>- ការបង្ហាញអំពីរបៀបចម្អិនម្ហូបអាហារ<br>**គ. គាំទ្រមធ្យោបាយធ្វើដំណើរ និងអាហារ រួមមាន ៖**<br>- ស្រង់បញ្ជីស្ត្រីមានផ្ទៃពោះ និងកំណត់អ្នកដែលងាយរងគ្រោះបំផុត<br>- រៀបចំការគាំទ្រពីឃុំ សង្កាត់ដោយមានសំណើជាលាយល័ក្ខអក្សរ (ទម្រង់ទី៤)<br>- ជូនដំណឹងដល់ពួកគេអំពីសេចក្តីសម្រេចចិត្ត និងសកម្មភាពដែលបានស្នើសុំ<br>- រៀបចំចាត់ចែងអ្នកផ្តល់សេវាដឹកជញ្ជូន ដើម្បីដឹកស្ត្រីដែលមានផ្ទៃពោះ ទៅកាន់មណ្ឌលសុខភាពសម្រាប់ការពិនិត្យផ្ទៃពោះមុនពេលសម្រាលកូនដោយសុវត្ថិភាព និងការពិនិត្យសុខភាពក្រោយពេលសម្រាល |

| | |
|---|---|
| - ចំនួនមណ្ឌលសុខភាពដែលឃុំ សង្កាត់ បានជួយផ្នែកអនាម័យ ដូចជា បង្គន់អនាម័យ សាប៊ូអាងលាងដៃ។ល។<br>- ចំនួនមណ្ឌលសុខភាពដែលឃុំ សង្កាត់ បានជួយផ្តល់ទឹកស្អាត | - ជំរុញលើកទឹកចិត្តអ្នកតំណាងពីមណ្ឌលសុខភាព ឲ្យចូលរួមប្រជុំជាមួយនឹង គ.ក.ន.ក<br>- រាយការណ៍អំពីករណីដែលបានគាំទ្រអំឡុងពេលប្រជុំ គ.ក.ន.ក<br>- ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ថ្លៃធ្វើដំណើរ ឬថ្លៃអាហារនិងផ្តល់ជាអាហារតែម្តង |

| **អ្វីដែលយើងចង់ធ្វើឲ្យសម្រេចបាន** | **គាំទ្រមត្តេយ្យសិក្សាសហគមន៍** |
|---|---|
| **សូចនាករ** | **សកម្មភាព** |
| - ចំនួនមត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការ (ប្តូរវេន២ម៉ោង ឬច្រើនម៉ោងជាង ក្នុងមួយសប្តាហ៍ ក្នុងអំឡុងពេល៩ខែ)<br>- ចំនួនអ្នកគ្រូមត្តេយ្យដែលបានចុះកិច្ចសន្យា<br>- ចំនួនលោកគ្រូមត្តេយ្យដែលបានចុះកិច្ចសន្យា<br>- ចំនួនមត្តេយ្យសិក្សាសហគមន៍ដែលឃុំគាំទ្រផ្នែអនាម័យ<br>- ចំនួនមត្តេយ្យសិក្សាសហគមន៍ដែលឃុំ សង្កាត់គាំទ្រឲ្យមានទឹកស្អាត<br>- ចំនួនសាលាមត្តេយ្យសិក្សាដែលមានការរៀបចំតាមបែបកុមារមេត្រី បានត្រឹមត្រូវ (ដូចជា មានបរិយាកាសស្អាត និងសុវត្ថិភាពល្អ និងមានសម្ភារៈសិក្សាគ្រប់គ្រាន់)<br>- ចំនួនកុមារ ពីអាយុ០៣ ទៅ០៤ឆ្នាំ បានចុះឈ្មោះចូលរៀនមត្តេយ្យសិក្សា បែងចែកតាមភេទ ជនជាតិដើមភាគតិច និងកុមារពិការ<br>- ចំនួនកុមារមានអាយុ០៥ឆ្នាំ បានចុះឈ្មោះចូលរៀននៅមត្តេយ្យសិក្សាសហគមន៍ បែងចែកតាមភេទ ជនជាតិដើមភាគតិច និងកុមារពិការ<br>- ចំនួនកុមារ អាយុពី០៣ ទៅ០៥ឆ្នាំ ដែលមិនបានចូលរួមក្នុងកម្មវិធីអប់រំកុមារតូច (មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សារដ្ឋ កម្មវិធីអប់រំតាមផ្ទះ)<br>- ចំនួនកុមារ អាយុពី០៣ ទៅ០៥ឆ្នាំ ដែលបានចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីអប់រំតាមផ្ទះ | **ក. លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃមត្តេយ្យសិក្សាសហគមន៍ រួមមាន ៖**<br>- យល់ដឹងអំពីតួអក្សរ និងលេខខ្មែរ<br>- ជំនាញទំនាក់ទំនងក្នុងសង្គម និងសមត្ថភាពបង្កើតទំនាក់ទំនងមិត្តភ័ក្រ្ត<br>- អភិវឌ្ឍន៍ជំនាញធ្វើចលនា (កាន់ប៊ិចគូររូបភាព)<br>- ស្គាល់ពណ៌ ចេះច្រៀង និងស្គាល់ពាក្យចុងជួន<br>- រៀបចំប្រជុំដើម្បីលើកទឹកចិត្តឳពុកម្តាយ បញ្ជូនកូនដែលមានអាយុពី០៣ ទៅ០៥ឆ្នាំ ឲ្យចូលរៀនមត្តេយ្យសិក្សាសហគមន៍<br>**ខ. គាំទ្រការបង្កើតមត្តេយ្យសិក្សាសហគមន៍ ឬគាំទ្រមត្តេយ្យសិក្សាសហគមន៍ដែលកំពុងដំណើរការ រួមមាន ៖**<br>- ស្រង់ទិន្នន័យកុមារដែលមានអាយុពី០៣ ទៅ០៥ឆ្នាំ ដើម្បីកំណត់តម្រូវការសម្រាប់មត្តេយ្យសិក្សាសហគមន៍ (រៀបចំការប្តូរវេនបង្រៀន ដើម្បីធានាថាកុមារទាំងអស់បានចូលរៀន<br>- រៀបចំការគាំទ្រពីឃុំ សង្កាត់បង្កើតមត្តេយ្យសិក្សាសហគមន៍ ដើម្បីធានាថាកុមារទាំងអស់បានចូលរៀន និងលើកសំណើជាលាយល័ក្ខអក្សរ (ទម្រង់ទី៤)<br>- ជូនដំណឹងអំពីសេចក្តីសម្រេចចិត្ត និងសកម្មភាពដែលបានស្នើសុំ និងលើកទឹកចិត្តគ្រូមត្តេយ្យសហគមន៍ឲ្យមកប្រជុំទៀងទាត់ជាមួយនឹងមាតាបិតាសិស្ស ដើម្បីជូនដំណឹងអំពីការរីកចម្រើន ឬជោគជ័យរបស់កូនៗពួកគេ<br>- រៀបចំកំណត់ទីតាំងសម្រាប់បង្កើតមត្តេយ្យសិក្សាសហគមន៍<br>- កំណត់គ្រូមត្តេយ្យសិក្សា ដោយផ្អែកតាមបទដ្ឋានទាបបំផុត។ សហការតាមដានជាមួយនឹងការិយាល័យអប់រំខេត្តដើម្បីរៀបចំវគ្គបណ្តុះបណ្តាលមុនពេលបង្រៀន និងវគ្គបំប៉នបំន្ថែម ម្រាប់គ្រូមត្តេយ្យសហគមន៍<br>- តាមដានកិច្ចសន្យាសម្រាប់គ្រូមត្តេយ្យសហគមន៍ ដោយធានាថាពួកគេទទួលបានប្រាក់បៀវត្សរ៍ប្រចាំខែ<br>- រាយការណ៍អំពីមត្តេយ្យសិក្សាសហគមន៍អំឡុងពេល |

| | |
|---|---|
| | ប្រជុំ គ.ក.ន.ក<br>- អ្នកទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ ចុះតាមដាន ត្រួតពិនិត្យឲ្យបានទៀងទាត់អំពីវត្តមានរបស់គ្រូមត្តេយ្យសិក្សាសហគមន៍ និងវត្តមានរបស់សិស្ស ការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍<br>- លើកទឹកចិត្តឲ្យឃុំផ្តល់អាហារសម្រន់ពេលព្រឹកដល់មត្តេយ្យសិក្សាសហគមន៍ដោយមានការសហការជាមួយនឹងអង្គការផ្សេងៗ ឬធនធានក្នុងមូលដ្ឋាន<br>- លើកទឹកចិត្តឲ្យឃុំសាងសង់កន្លែងក្មេងលេងសម្រាប់មត្តេយ្យសហគមន៍ដោយប្រើប្រាស់សម្ភារៈក្នុងមូលដ្ឋាន<br>- លើកទឹកចិត្តឲ្យមាតាបិតារៀបចំបង្កើតសម្ភារៈក្មេងលេងក្រៅពីសម្ភារៈដែលមានស្រាប់ក្នុងមត្តេយ្យសិក្សាសហគមន៍ |

| **អ្វីដែលយើងចង់ធ្វើឲ្យសម្រេចបាន** | **ធានាថាកុមារដែលមានអាយុពី៦ ដល់១១ឆ្នាំ បញ្ចប់បឋមសិក្សា** |
|---|---|
| **សូចនាករ** | **សកម្មភាព** |
| - ចំនួនសាលាបឋមសិក្សាដែលឃុំ សង្កាត់គាំទ្រឲ្យមានការកែលម្អអនាម័យ (ឧទាហរណ៍ បង្គន់មានសាប៊ូលាងដៃ និងកន្លែងលាងដៃ)<br>- ចំនួនសាលាបឋមសិក្សាដែលឃុំ សង្កាត់គាំទ្រឲ្យមានទឹកស្អាត<br>- ចំនួនកុមារនៅសាលាបឋមសិក្សាទទួលបានថ្នាំគ្រាប់ទម្លាក់សត្វល្អិត អំឡុងពេលផ្តល់សេវាសុខភាពដល់មូលដ្ឋាន (ចំនួន២ដងក្នុង១ឆ្នាំ ដែលរៀបចំដោយមណ្ឌលសុខភាព និងដោយមានការសហការជាមួយនឹងសាលារៀន)<br>- ចំនួនកុមារដែលមានអាយុ៦ឆ្នាំចុះឈ្មោះចូលរៀនថ្នាក់ទី១ បែងចែកតាមភេទ ជនជាតិដើមភាគតិច និងកុមារពិការ<br>- ចំនួនកុមារបោះបង់ចោលការសិក្សា ដែលឃុំ សង្កាត់គាំទ្រឲ្យបានចូលរៀនវិញ បែងចែកតាមភេទ ជនជាតិដើមភាគតិច និងកុមារពិការ<br>- អត្រាបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សា បែងចែកតាមភេទ ជនជាតិដើមភាគតិច និងកុមារពិការ | **ក. លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការអប់រំ ដូចជា ៖**<br>- រៀបចំកិច្ចប្រជុំដើម្បីលើកទឹកចិត្តមាតាបិតាសិស្ស ឲ្យបញ្ជូនកូនដែលមានអាយុពី៦ ដល់១១ឆ្នាំ ចូលរៀនបឋមសិក្សា<br>**ខ. គាំទ្រការបង្កើតសាលាបឋមសិក្សាថ្មី និងបឋមសិក្សាកំពុងដំណើរការ រួមមាន ៖**<br>- ពិភាក្សាជាមួយនឹងគណៈកម្មាធិការគ្រប់គ្រងសាលាដើម្បីកំណត់តម្រូវការសម្រាប់ការសាងសង់ ការជួសជុល និងការថែទាំដើម្បីធានាឲ្យមានការកែលម្អនូវអនាម័យ កន្លែងលាងដៃនឹងសាប៊ូ និងទឹកស្អាតក្នុងសាលារៀន<br>- ស្រង់ទិន្នន័យកុមារដែលមានអាយុពី៦ ដល់១១ឆ្នាំ ដែលមិនបានចូលរៀន<br>- រៀបចំការគាំទ្រពីឃុំ សង្កាត់ដល់គ្រួសារដែលមានកូនអាយុពី៦ ដល់១១ឆ្នាំមិនបានចូលរៀន<br>- លើកសំណើជាលាយលក្ខណ៍អក្សរ (ទម្រង់ ទី៤)<br>- ជូនដំណឹងអំពីសេចក្តីសម្រេចចិត្ត និងសកម្មភាពដែលបានស្នើសុំ<br>- ជំរុញលើកទឹកចិត្តតំណាងសាលារៀនឲ្យចូលរួមក្នុងកិច្ចប្រជុំ គ.ក.ន.ក និងជំរុញលើកទឹកចិត្ត តំណាង គ.ក.ន.ក ឲ្យចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការទ្រទ្រង់សាលារៀន<br>- រាយការណ៍អំពីសកម្មភាពដែលបានគាំទ្រអំឡុងពេលកិច្ចប្រជុំ គ.ក.ន.ក<br>- លើកទឹកចិត្តសមាជិក គ.ក.ន.ក តាមដានត្រួតពិនិត្យអំពីសៀវភៅបោះពុម្ពដែលត្រូវមានក្នុងសាលារៀន<br>- លើកទឹកចិត្តសមាជិក គ.ក.ន.ក រៀបចំចាត់ចែងអាហារ |

| | |
|---|---|
| | សម្រាប់ពេលព្រឹកក្នុងសាលារៀន ដោយធ្វើការជាដៃគូនឹងអង្គការផ្សេងៗ<br>- ប្រសិនបើមានមត្តេយ្យសិក្សាសហគមន៍ (ជាពិសេសនៅក្នុងតំបន់ជនជាតិដើមភាគតិចដែលដាច់ស្រយាលបំផុត ឃុំ សង្កាត់ត្រូវលើកទឹកចិត្ត គ.ក.ន.ក ផ្តល់ការគាំទ្រដល់សាលារៀន រួមមាន ការលើកទឹកចិត្តដល់គ្រូមត្តេយ្យ ការសាងសង់ និងផ្តល់សម្ភារៈសិក្សា។ |

| **អ្វីដែលយើងចង់ធ្វើឲ្យសម្រេចបាន** | **កែលម្អសុវត្ថិភាពសហគមន៍** |
|---|---|
| **សូចនាករ** | **សកម្មភាព** |
| - ចំនួនកុមាររបួស (បែងចែកតាមអាយុ ភេទ ប្រភេទរបួស ដូចជា ដោយគ្រាប់មីន គ្រាប់មិនទាន់ផ្ទុះ ថ្នាំពុល ពស់ចឹក លង់ទឹក អំពើហិង្សា គ្រោះថ្នាក់ចរាចរ) ដែលឃុំ សង្កាត់បានស៊ើបអង្កេត ចាត់វិធានការការពារករណីទាំងនោះទៅអនាគត<br>- ចំនួនករណីចោរកម្មដែលនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់បានស៊ើបអង្កេត<br>- ចំនួនករណីអំពើហិង្សាក្នុងគ្រួសារដែលនគរបាលប៉ុស្តិ៍រដ្ឋបាលបានស៊ើបអង្កេត<br>- ចំនួនករណីរំលោភផ្លូវភេទដែលនគរបាលប៉ុស្តិ៍រដ្ឋបាលបានស៊ើបអង្កេត | **ក. លើកកម្ពស់ការយល់ដឹងអំពីសកម្មភាពនានា ដូចជា ៖**<br>- រៀបចំកិច្ចប្រជុំដើម្បីជំរុញកិច្ចការពារគ្រោះថ្នាក់ និងប្រការនានាដែលនាំឲ្យមានរបួសស្នាម<br>- រៀបចំកិច្ចប្រជុំដើម្បីជំរុញសហគមន៍ត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់<br>**ខ. គាំទ្រកិច្ចអន្តរាគមន៍ដើម្បីកែលម្អសុវត្ថិភាពភូមិ ឃុំ សង្កាត់ ដូចជា ៖**<br>- ស្រង់ទិន្នន័យជនរងគ្រោះដែលកើតឡើងក្នុងឃុំ សង្កាត់<br>- រៀបចំការគាំទ្រពីឃុំ សង្កាត់ដើម្បីទប់ស្កាត់ប្រការនានាដែលនាំឲ្យមានគ្រោះថ្នាក់ នៅពេលអនាគត (ដូចជា ធ្វើរបងព័ទ្ធជុំវិញស្រះទឹកដើម្បីបង្ការការលង់ទឹកស្លាប់) ឬលើកសំណើជាលាយល័ក្ខអក្សរនានា (ទម្រង់ទី៤)<br>- ជូនដំណឹងជាប្រចាំដល់គ្រប់ក្រុមគ្រួសារទាំងអស់ អំពីសេចក្តីសម្រេចចិត្ត និងសកម្មភាពដែលត្រូវអនុវត្ត |

# ឧទាហរណ៍ពីឃុំអំពិល

## ទម្រង់ទី៥ ៖ សូចនាករនៃសេវាសង្គមប្រកបដោយសមធម៌

| **អ្វីដែលយើងចង់ឲ្យសម្រេច ៖ ធានាការចុះបញ្ជីអត្រានុកូលដ្ឋានឲ្យមានប្រសិទ្ធភាព** | |
|---|---|
| **សូចនាករ** | |
| - ចំនួនប្រជាពលរដ្ឋសរុប បែងចែកតាមភេទ និងអាយុ | ១០.០០០នាក់ |
| - ចំនួនមនុស្សពេញវ័យសរុប បែងចែកតាមភេទ និងអាយុ | ៦.០០០នាក់ (ប្រុស៣.០០០នាក់ ស្រី៣.០០០នាក់) |
| - ចំនួនកុមារសរុប បែងចែកតាមភេទ និងអាយុ | ៤.០០០នាក់ (ប្រុស២.០០០នាក់ ស្រី២.០០០នាក់) |
| - ចំនួនទារកទើបកើតដែលបានចុះបញ្ជីកំណើតក្នុងរយៈពេល៣០ថ្ងៃ | ៥៥នាក់ ក្នុងចំណោម ១០០នាក់ |
| - ចំនួនអាពាហ៍ពិពាហ៍ដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍ (នៅឆ្នាំថ្មីនេះ) | ២គូ ក្នុងចំណោម២០គូ |
| - ចំនួនមរណភាពនៃទារកដែលបានចុះបញ្ជីមរណភាព (អាយុតិចជាង១ខែ) | ១នាក់ |

| | |
|---|---|
| - ចំនួនមរណភាពនៃកុមារដែលបានចុះបញ្ជីមរណភាព (អាយុតិចជាង១ឆ្នាំ) | ២នាក់ |
| - ចំនួនមរណភាពនៃកុមារដែលបានចុះបញ្ជីមរណភាព (អាយុតិចជាង៥ឆ្នាំ | ១នាក់ |
| - ចំនួនមរណភាពនៃកុមារដែលបានចុះបញ្ជីមរណភាព (អាយុតិចជាង១៨ឆ្នាំ) | ១នាក់ |
| - ចំនួនមរណភាពនៃមាតានៅពេលមានផ្ទៃពោះ ឬសម្រាលកូនរួច បានចុះបញ្ជីមរណភាព | ៣នាក់ |
| - ចំនួនមរណភាពនៃឪពុកដែលមានកូន បានចុះបញ្ជីមរណភាព | ២នាក់ |

| **អ្វីដែលយើងចង់ឲ្យសម្រេច ៖ កិច្ចការពារ និងការឆ្លើយតបចំពោះកុមាររងគ្រោះ កុមារងាយរងគ្រោះ និងក្រុមគ្រួសារងាយរងគ្រោះបំផុត** | |
|---|---|
| **សូចនាករ** | |
| - ចំនួនកុមារងាយរងគ្រោះដែលទទួលបានផលប្រយោជន៍ តាមរយៈវិធានការការពារ (ផ្តល់អាហារ មធ្យោបាយធ្វើដំណើរ សម្លៀកបំពាក់ ឯកសណ្ឋានសិស្ស សម្ភារៈសិក្សា) | ៤៣នាក់ ក្នុងចំណោម៧០នាក់ |
| - ចំនួនស្ត្រី និងកុមារដែលធ្លាប់រងគ្រោះដោយអំពីហិង្សា បានបញ្ជូនទៅរកសេវាសមស្រប | ១នាក់ |
| - ចំនួនគ្រួសារដែលត្រូវសង្គ្រោះបន្ទាន់ បានទទួលជំនួយពីឃុំ | ២០នាក់ |

| **អ្វីដែលយើងចង់ឲ្យសម្រេច ៖ ធានាឱ្យមានការផ្តល់ និងទទួលបាននូវសេវាសុខភាពនៅតាមមូលដ្ឋាន ទាន់ពេលវេលា និងប្រកបដោយគុណភាព** | |
|---|---|
| **សូចនាករ** | |
| - ចំនួនស្ត្រីងាយរងគ្រោះមានផ្ទៃពោះដែលឃុំគាំទ្រឲ្យទៅពិនិត្យសុខភាព មុនពេលសម្រាល នៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ យ៉ាងហោចណាស់០២ដង | ២០នាក់ ក្នុងចំណោម៥០នាក់ |
| - ចំនួនស្ត្រីដែលប្រើប្រាស់មធ្យោបាយពន្យារកំណើតតាមបែបទំនើប | ២០នាក់ ក្នុងចំណោម៥០នាក់ |
| - ចំនួនស្ត្រីងាយរងគ្រោះមានផ្ទៃពោះដែលឃុំគាំទ្រឲ្យទៅសម្រាលកូននៅមណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋ ឬឯកជន | ២០នាក់ ក្នុងចំណោម៥០នាក់ |
| - ចំនួនមាតាងាយរងគ្រោះមានកូនដំបូង និងទារកទើបកើតដែលឃុំគាំទ្រឲ្យទៅពិនិត្យសុខភាព ក្រោយពេលសម្រាល នៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ យ៉ាងហោចណាស់០១ដង | ២០នាក់ ក្នុងចំណោម៥០នាក់ |
| - ចំនួនប្រជាពលរដ្ឋដែលមានផ្ទុកមេរោគអេដស៍ ទទួលបានសេវាថែទាំ (បែងចែកតាមភេទ) | - ២នាក់ ក្នុងចំណោម១០នាក់ (ស្ត្រី)<br>- ៣នាក់ ក្នុងចំណោម៨នាក់ (បុរស) |
| - ចំនួនទារកដែលបានចាក់ថ្នាំបង្ការគ្រប់មុខ តាមរយៈដំណើរការកសាងផែនការខ្នាតតូច រវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមប្រឹក្សាឃុំ | ៥៥នាក់ ក្នុងចំណោម១០០នាក់ |
| - ចំនួនទារកទើបកើតខ្វះទម្ងន់ ដែលគ្រួសារទទួលបានការគាំទ្រពីឃុំ | ២០នាក់ ក្នុងចំណោម១០០នាក់ |
| - ចំនួនកុមារខ្វះអាហារូបត្ថម្ភ ដែលគ្រួសារទទួលបានជំនួយពីឃុំ | ៣០នាក់ ក្នុងចំណោម១០០នាក់ |

| | |
|---|---|
| - ចំនួនប្រជាពលរដ្ឋដែលមានជំងឺរ៉ាំរ៉ៃ ទទួលបានជំនួយពីឃុំ | ៥នាក់ |
| - ចំនួនកុមារមានអាយុក្រោម០៥ឆ្នាំ ទទួលបានថ្នាំទម្លាក់ព្រូនក្នុងរយៈពេល០៦ខែ ចុងក្រោយ តាមរយៈដំណើរការកសាងផែនការខ្នាតតូចរវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមប្រឹក្សាឃុំ | ២០០នាក់ ក្នុងចំណោម ១.០៤២នាក់ |
| - ចំនួនកុមារមានអាយុក្រោម០៥ឆ្នាំ ទទួលបានជីវជាតិអាបន្ថែមក្នុងរយៈពេល០៦ខែ ចុងក្រោយ តាមរយៈដំណើរការកសាងផែនការខ្នាតតូច រវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមប្រឹក្សាឃុំ | ២០០នាក់ ក្នុងចំណោម ១.០៤២នាក់ |
| - ចំនួនករណីជំងឺរាគរូសដែលបានរកឃើញ និងព្យាបាលបានទាន់ពេលវេលា តាមរយៈដំណើរការកសាងផែនការខ្នាតតូច រវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមប្រឹក្សាឃុំ | ២០០នាក់ |
| - ចំនួនមណ្ឌលសុខភាពដែលឃុំគាំទ្រឲ្យមានសម្ភារៈប្រសើរឡើង (ឧទាហរណ៍ គ្រែ ទឹកស្អាត អគ្គិសនី) | ១កន្លែង |
| - ចំនួនមណ្ឌលសុខភាពដែលឃុំគាំទ្រឲ្យអនាម័យប្រសើរឡើង (ឧទាហរណ៍ បង្គន់អនាម័យ មានសាប៊ូ និងកន្លែងលាងដៃ) | ១កន្លែង |
| - ចំនួនមណ្ឌលសុខភាពដែលឃុំបានជួយផ្តល់ទឹកស្អាត | ១កន្លែង |

| **អ្វីដែលយើងចង់ឲ្យសម្រេច ៖ គាំទ្រមត្តេយ្យសិក្សាសហគមន៍** | |
|---|---|
| **សូចនាករ** | |
| - ចំនួនមត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការ (ប្តូរវេន០២ម៉ោង ឬច្រើនម៉ោង ក្នុងមួយសប្តាហ៍ក្នុងអំឡុងពេល៩ខែ) | ១កន្លែង |
| - ចំនួនគ្រូមត្តេយ្យសិក្សាសហគមន៍ដែលបានចុះកិច្ចសន្យារួច | ១នាក់ |
| - ចំនួនគ្រូមត្តេយ្យសិក្សាសហគមន៍ជាប់កិច្ចសន្យាដែលឧបត្ថម្ភដោយឃុំ ដើម្បីលើកកម្ពស់អនាម័យ | ០នាក់ |
| - ចំនួនមត្តេយ្យសិក្សាសហគមន៍ដែលឧបត្ថម្ភដោយឃុំ ដើម្បីលើកកម្ពស់អនាម័យ | ១នាក់ |
| - ចំនួនមត្តេយ្យសហគមន៍ដែលឃុំគាំទ្រឲ្យមានទឹកស្អាត | ១កន្លែង |
| - ចំនួនកុមារមានអាយុ០៣ ទៅ០៤ឆ្នាំ ចុះឈ្មោះចូលរៀននៅមត្តេយ្យសាលា បែងចែកតាមភេទ ជនជាតិដើមភាគតិច និងកុមារពិការ | កុមារា៧នាក់ កុមារី៩នាក់ |
| - ចំនួនកុមារមានអាយុ០៥ឆ្នាំ ចុះឈ្មោះចូលរៀននៅមត្តេយ្យសាលា បែងចែកតាមភេទ ជនជាតិដើមភាគតិច និងកុមារពិការ | កុមារា៤នាក់ កុមារី៤នាក់ |
| - ចំនួនកុមារអាយុពី ០៣ ទៅ០៥ឆ្នាំ ដែលមិនបានចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីអប់រំកុមារតូច (មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សារដ្ឋ កម្មវិធីអប់រំតាមផ្ទះ) | ៦២៧នាក់ |

| **អ្វីដែលយើងចង់ឲ្យសម្រេច ៖ ធានាថាកុមារដែលមានអាយុពី០៦ ដល់១១ឆ្នាំបានបញ្ចប់បឋមសិក្សា** | |
|---|---|
| **សូចនាករ** | |
| - ចំនួនសាលាបឋមសិក្សាដែលឃុំឧបត្ថម្ភ ដើម្បីលើកកម្ពស់អនាម័យ (ឧទាហរណ៍ បង្គន់អនាម័យមានសាប៊ូលាងដៃ និងអាងលាងដៃ) | ១កន្លែង |

| | |
|---|---|
| - ចំនួនសាលាបឋមសិក្សាដែលឃុំគាំទ្រឲ្យមានទឹកស្អាត | ១កន្លែង |
| - ចំនួនកុមារនៅសាលាបឋមសិក្សាទទួលបានថ្នាំទម្លាក់ព្រូន អំឡុងពេលការផ្តល់សេវាសុខភាពដល់មូលដ្ឋាន (ចំនួន២ដង ក្នុង១ឆ្នាំដែលរៀបចំដោយមណ្ឌលសុខភាព និងដោយមានការសហការជាមួយសាលារៀន) | ៩០០នាក់ ក្នុងចំណោម ១.៤៥៩នាក់ |
| - ចំនួនកុមារមានអាយុ០៦ឆ្នាំ ចុះឈ្មោះចូលរៀននៅថ្នាក់ទី១ បែងចែកតាមភេទ ជនជាតិដើមភាគតិច និងកុមារពិការ | -កុមារា៦៧នាក់ ក្នុងចំណោម១១៦នាក់<br>-កុមារី៧០នាក់ ក្នុងចំណោម១១៨នាក់ |
| - ចំនួនកុមារបោះបង់ចោលការសិក្សាដែលឃុំគាំទ្រឲ្យបានចូលរៀនវិញ បែងចែកតាមភេទ ជនជាតិដើមភាគតិច និងកុមារពិការ | កុមារា២៨៦នាក់<br>កុមារី២៧៥នាក់ |
| - អត្រាបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សា បែងចែកតាមភេទ ជនជាតិដើមភាគតិច និងកុមារពិការ | ៦០% |

| **អ្វីដែលយើងចង់ឲ្យសម្រេច៖ កែលម្អសុវត្ថិភាពសហគមន៍** | |
|---|---|
| **សូចនាករ** | |
| - ចំនួនកុមាររងរបួស (បែងចែកតាមភេទ អាយុ ប្រភេទរបួសដោយគ្រាប់មីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ធ្លាក់ ថ្នាំពុល ពស់ចឹក លង់ទឹក អំពើហិង្សា គ្រោះថ្នាក់ចរាចរណ៍) ដែលឃុំបានស៊ើបអង្កេត ចាត់វិធានការការពារករណីទាំងនោះសម្រាប់អនាគត | ១៥នាក់ |
| - ចំនួនករណីចោរកម្មដែលនគរបាលប៉ុស្តិ៍រដ្ឋបាលបានស៊ើបអង្កេត | ១ករណី |
| - ចំនួនករណីហិង្សាក្នុងគ្រួសារដែលនគរបាលប៉ុស្តិ៍រដ្ឋបាលបានស៊ើបអង្កេត | ១ករណី |
| - ចំនួនករណីរំលោភដែលនគរបាលប៉ុស្តិ៍រដ្ឋបាលបានស៊ើបអង្កេត | ០ករណី |

**ឧទ្រង់ទី៦**

រាជធានី ខេត្ត......................................
ក្រុង ស្រុក ខណ្ឌ .................................
ឃុំ សង្កាត់ .........................................

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

## របាយការណ៍រីកចម្រើនអំពីការអនុវត្តផែនការស្តីពីការអភិវឌ្ឍសង្គមប្រកបដោយសមធម៌
**ខែ ............ឆ្នាំ..............**

| ល.រ | សកម្មភាព និងលទ្ធផល | លទ្ធផលគ្រោង | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | ថ្ងៃអនុវត្ត | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | | |
| ១ | ធានាការចុះអត្រានុកូលដ្ឋានឲ្យមានប្រសិទ្ធភាព | | | | | | | |
| ១.១ | | | | | | | | |
| ២ | ការការពារ និងការឆ្លើយតបចំពោះភាពពាក់ព័ន្ធនឹងកិច្ចការពារកុមារ ក្នុងចំណោមកុមារ និងគ្រួសារងាយរងគ្រោះបំផុត | | | | | | | |
| ២.១ | | | | | | | | |
| ៣ | ធានាឲ្យមានសេវាសុខភាព និងអាហារូបត្ថម្ភនៅមូលដ្ឋាន និង ទទួលបានសេវាកម្មសុខភាព និងអាហារូបត្ថម្ភមានគុណភាព និងបានទាន់ពេលវេលា | | | | | | | |
| ៣.១ | | | | | | | | |
| ៤ | វិនិយោគទៅក្នុងសាលាមត្តេយ្យសហគមន៍ | | | | | | | |
| ៤.១ | | | | | | | | |
| ៥ | បង្កើនគុណភាពទឹកអនាម័យ និងការរស់នៅស្អាតក្នុងសហគមន៍ | | | | | | | |
| ៥.១ | | | | | | | | |
| ៦ | ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការឆ្លើយតប | | | | | | | |
| ៦.១ | | | | | | | | |
| ៧ | ប្រជុំ និងការតាមដានរបស់ គ.ក.ន.ក | | | | | | | |
| ៧.១ | | | | | | | | |

*ថ្ងៃទី.........ខែ.................ឆ្នាំ...........*
**មេឃុំ ចៅសង្កាត់**

*ថ្ងៃទី.............ខែ.................ឆ្នាំ...........*
**អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ**

**ឧបសម្ព័ន្ធទី៧**

រាជធានី ខេត្ត..........................
ក្រុង ស្រុក ខណ្ឌ .....................
ឃុំ សង្កាត់ .............................

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**របាយការណ៍ថវិកា**
**អំពី**
**ការអភិវឌ្ឍផ្នែកសង្គមប្រកបដោយសមធម៌**
ប្រចាំខែ...............ឆ្នាំ.................

| ល.រ | សកម្មភាព និងលទ្ធផល | ថវិកាគ្រោង | ការចំណាយ | | | សមតុល្យ |
|---|---|---|---|---|---|---|
| | | | កន្លងមក | ក្នុងខែ | បូកយោង | |
| ១ | **ធានាការចុះអត្រានុកូលដ្ឋានឲ្យមានប្រសិទ្ធភាព** | | | | | |
| ១.១ | វគ្គ លើកកម្ពស់ការយល់ដឹង | | | | | |
| | | | | | | |
| ២ | **ការការពារ និងការឆ្លើយតប ពាក់ព័ន្ធនឹងកិច្ចការពារកុមារ ក្នុងចំណោមកុមារ និងគ្រួសារងាយរងគ្រោះបំផុត** | | | | | |
| ២.១ | ការកំណត់រកកុមារ និងគ្រួសារងាយរងគ្រោះបំផុត | | | | | |
| ២.២ | ការគាំទ្រកុមារ និងគ្រួសារងាយរងគ្រោះបំផុត | | | | | |
| | | | | | | |
| ៣ | **ធានាឲ្យមានការផ្តល់ និងទទួលបាននូវសេវាសុខភាពនៅតាមមូលដ្ឋានទាន់ពេលវេលា និងប្រកបដោយគុណភាព** | | | | | |
| ៣.១ | វគ្គ លើកកម្ពស់ការយល់ដឹង | | | | | |
| ៣.២ | ការគាំទ្រស្ត្រីមានផ្ទៃពោះងាយរងគ្រោះ បានពិនិត្យសុខភាពមុនពេលសម្រាលកូន ការសម្រាលកូនមានសុវត្ថិភាព និងពិនិត្យសុខភាពក្រោយពេលសម្រាលនៅមណ្ឌលសុខភាព | | | | | |
| ៣.៣ | ផ្សព្វផ្សាយអប់រំ និងលើកកម្ពស់ចំណេះដឹងអំពីសមភាពយេនឌ័រ និងអំពើហិង្សាក្នុងគ្រួសារ | | | | | |
| ៣.៤ | ផ្សព្វផ្សាយលើកកម្ពស់ចំណេះដឹងពីសុខភាពបន្តពូជ | | | | | |
| ៣.៥ | ផ្សព្វផ្សាយលើកកម្ពស់ចំណេះដឹងពីការទប់ស្កាត់ការឆ្លង និងការរីករាលដាលមេរោគអេដស៍ | | | | | |
| ៣.៦ | ផ្សព្វផ្សាយលើកកម្ពស់ចំណេះដឹងពីបញ្ហារបស់យុវជន | | | | | |
| ៤ | **គាំទ្រមត្តេយ្យសហគមន៍** | | | | | |
| ៤.១ | ប្រជុំ និងចាត់ចែងមត្តេយ្យសាលាសហគមន៍ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៤.២ | ប្រតិបត្តិការមគ្គេយ្យសហគមន៍ | | | | | |
| | | | | | | |
| **៥** | **កែលម្អគុណភាពទឹក អនាម័យ និងរស់នៅស្អាតក្នុងសហគមន៍** | | | | | |
| ៥.១ | ការគាំទ្រឲ្យអនាម័យប្រសើរឡើង (បង្គន់មានសាប៊ូអាងលាងដៃ) | | | | | |
| | | | | | | |
| **៦** | **ការត្រៀមបង្ការសម្រាប់ការសង្គ្រោះបន្ទាន់ និងការឆ្លើយតប** | | | | | |
| | | | | | | |
| **៧** | **ប្រជុំ និងការតាមដានរបស់ គ.ក.ន.ក** | | | | | |
| ៧.១ | រៀបចំកិច្ចប្រជុំ (ឯកសារ និងអាហារសម្រន់) | | | | | |
| ៧.២ | សម្ភារៈការិយាល័យ | | | | | |
| ៧.៣ | ការតាមដាន ការចុះពិនិត្យផ្ទាល់របស់ គ.ក.ន.ក | | | | | |
| | | | | | | |
| **សរុប** | | | | | | |

*ថ្ងៃទី...........ខែ.............ឆ្នាំ..........*
**មេឃុំ ចៅសង្កាត់**

*ថ្ងៃទី.........ខែ...........ឆ្នាំ..........*
**ស្មៀនឃុំ សង្កាត់**

*<u>កំណត់សម្គាល់</u>* ៖

- លទ្ធផលនៃការត្រួតពិនិត្យ និងត្រូវបានបញ្ចូលទៅក្នុងរបៀបវារៈនៅរៀងរាល់ការប្រជុំត្រីមាស ឆមាស និងការប្រជុំប្រចាំឆ្នាំ ដើម្បីធ្វើការឆ្លុះបញ្ចាំងព្រមទាំងធ្វើឲ្យប្រសើរឡើងនូវសកម្មភាពអនុវត្តន៍របស់ គ.ក.ន.ក
- ព័ត៌មានពីការត្រួតពិនិត្យ និងវាយតម្លៃ គឺជាព័ត៌មានសំខាន់សម្រាប់រៀបចំរបាយការណ៍សកម្មភាពនានារបស់ គ.ក.ន.ក
- នៅរៀងរាល់ដើមឆ្នាំ គ.ក.ន.ក ត្រូវប្រមូលទិន្នន័យអំពីស្ថានភាពប្រជជនដែលងាយរងគ្រោះបំផុត ដើម្បីប្រើជាមូលដ្ឋានគ្រឹះសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃ។

## ៦.២. ទម្រង់របាយការណ៍ និងកំណត់ហេតុ

៦.២.១. របាយការណ៍អំពីសកម្មភាពសំខាន់ៗទាក់ទងនឹងស្ត្រី និងកុមារងាយរងគ្រោះបំផុត

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ គួរធ្វើការសម្របសម្រួលជាមួយមេឃុំ ចៅសង្កាត់ ស្មៀន មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីរាយការណ៍អំពីសូចនាករសំខាន់ៗ និងសកម្មភាពនានាមួយចំនួន រួមទាំងផ្តល់ព័ត៌មានថ្មីៗអំពីបញ្ហានានាដែលទាក់ទងនឹងស្ត្រី និងកុមារដែលងាយរងគ្រោះ។ (សូមមើលគំរូរបាយការណ៍ខាងក្រោម)

### ទម្រង់គំរូរបាយការណ៍

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត..............................
ក្រុង ស្រុក ខណ្ឌ ..........................
ឃុំ សង្កាត់ .................................

**របាយការណ៍**
**អំពី**
**សកម្មភាពទាក់ទងនឹងស្ត្រី និងកុមារនៅក្នុងឃុំ សង្កាត់**
**ខែ...........ឆ្នាំ..............**

| ល.រ | សូចនាករ | ចំនួន | បញ្ហាផ្សេងៗ |
|---|---|---|---|
| ១ | ចំនួនស្ត្រីមានផ្ទៃពោះ (ដោយត្រូវយកចិត្តទុកដាក់ជាពិសេសដល់ស្ត្រីដែលមានផ្ទៃពោះងាយរងគ្រោះបំផុត ធ្វើយ៉ាងណាឲ្យពួកគេបានទៅពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាពមុនពេលសម្រាលយ៉ាងហោចណាស់ឲ្យបាន០២ដង ការសម្រាលកូនដោយគ្រូពេទ្យជំនាញប្រកបដោយសុវត្ថិភាព ហើយម្តាយ និងទារកដែលទើបកើតត្រូវមានការតាមដានបន្តក្រោយពេលសម្រាល) | | |
| ២ | ចំនួនស្ត្រីដែលបានសម្រាលកូននៅមណ្ឌលសុខភាព | | |
| ៣ | ចំនួនស្ត្រីដែលទទួលរងអំពើហិង្សាក្នុងគ្រួសារ | | |
| ៤ | ចំនួនមរណភាពរបស់ស្ត្រីក្នុងខណៈពេលមានផ្ទៃពោះ ពេលសម្រាលកូន ឬបន្ទាប់ពីពេលសម្រាលរួច កាលពីខែមុន | | |
| ៥ | ចំនួនទារកទើបកើតនៅក្នុងខែនេះ | | |
| ៦ | ចំនួនកុមារអាយុក្រោម០១ឆ្នាំទាំងអស់ (យកចិត្តទុកដាក់ជាសេសដល់កុមារដែលងាយរងគ្រោះបំផុត) បានទទួលការចាក់ថ្នាំបង្ការគ្រប់ចំនួន ដូចជា វ៉ាក់សាំង BCG ចំនួន០១ដូស (វ៉ាក់សាំងប្រឆាំងនឹងជំងឺរបេង) វ៉ាក់សាំង OPV ចំនួន០៣ដូស (វ៉ាក់សាំងប្រឆាំងនឹងជំងឺគ្រុនស្វិតដៃជើង) វ៉ាក់សាំង DPT- | | |

| | | | |
|---|---|---|---|
| | HepB-Hib ចំនួន០៣ដូស (វ៉ាក់សាំងប្រឆាំងនឹងជំងឺខាន់ស្លាក់ តេតាណូស ក្អកមាន់ ថ្លើមប្រភេទបេ និងរលាកស្បូត ស្រោមខួរ ឆ្អឹងខ្នង។ល។) និង វ៉ាក់សាំងកញ្ជ្រឹលចំនួន០១ដូស ព្រមទាំង ទទួលបានអាហារូបត្ថម្ភបន្ថែមបន្ទាប់ពីអាយុ០៦ខែ និង ការ ព្យាបាលទាន់ពេលវេលានៃជំងឺរលាកផ្លូវដង្ហើមធ្ងន់ | | |
| ៧ | ចំនួនកុមារដែលបានព្យាបាលជំងឺរាក ដោយថ្នាំស័ង្កសី និងទឹក អូរ៉ាលីត | | |
| ៨ | ចំនួនកុមារដែលបានបញ្ជូនទៅមន្ទីរពេទ្យទាន់ពេលវេលា ឬបាន ព្យាបាលជំងឺរលាកផ្លូវដង្ហើមធ្ងន់ទាន់ពេល | | |
| ៩ | ចំនួនកុមារអាយុ៣ទៅ៥ឆ្នាំ ចូលរៀនមត្តេយ្យសិក្សាសហគមន៍ | | |
| ១០ | ចំនួនកុមារអាយុក្រោម០៥ឆ្នាំ ដែលទទួលបានបន្ថែមថ្នាំជីវជាតិ អា និងថ្នាំទម្លាក់ព្រូន | | |
| ១១ | ចំនួនកុមារអាយុ០៦ ទៅ១១ឆ្នាំ បែងចែកតាមភេទជនជាតិដើម ភាគតិច និងកុមារពិការ | | |
| | | | |
| | **សកម្មភាព** | **ទីកន្លែង ពេលវេលា** | **បញ្ហាផ្សេងៗ** |
| ១ | វគ្គ ផ្សព្វផ្សាយ ដែលបានរៀបចំពីខែមុន | | |
| ២ | វគ្គបណ្តុះបណ្តាល | | |
| ៣ | វេទិកា និងការពិភាក្សាក្នុងសហគមន៍ | | |
| | | | |
| | **ធ្វើបច្ចុប្បន្នភាព** | | |
| ១ | ធ្វើបច្ចុប្បន្នភាពមត្តេយ្យសិក្សាសហគមន៍ (ដូចជា ចំនួនគ្រូ មត្តេយ្យសិក្សាសហគមន៍ សម្ភារៈបង្រៀននានា កន្លែងរៀន ការយកចិត្តទុកដាក់ និងតម្រូវការផ្សេងៗ) | | |
| ២ | ធ្វើបច្ចុប្បន្នភាពត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការ ឆ្លើយតប | | |
| ៣ | ធ្វើបច្ចុប្បន្នភាពគ្រួសារដែលងាយរងគ្រោះ និងគ្រួសាររបស់ពួក គេ | | |
| ៤ | ធ្វើបច្ចុប្បន្នភាពការងារអ្នកស្ម័គ្រចិត្តភូមិ ឃុំ | | |

ថ្ងៃទី.......ខែ........ឆ្នាំ...............

**ហត្ថលេខា**

### ៦.២.២. របាយការណ៍ផ្នែកសុខភាព

ប្រធានផ្នែក ឬតំណាងនៃមណ្ឌលសុខភាព ដោយមានការសម្របសម្រួលជាមួយមេភូមិ និងជំនួយការភូមិ ក្រុមអ្នកស្ម័គ្រចិត្តសុខភាពភូមិ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត គួរលើកទឹកចិត្តដល់ស្ត្រីដែលមានផ្ទៃពោះទាំងអស់ ឲ្យទៅមណ្ឌលសុខភាពពិនិត្យមុនពេលសម្រាល ដើម្បីសម្រាលកូនដោយសុវត្ថិភាព និងពិនិត្យក្រោយពេលសម្រាលដើម្បីធ្វើការតាមដាន។ កុមារទាំងអស់គួរទទួលបានការចាក់ថ្នាំបង្ការគ្រប់ចំនួនព្រមទាំងព្យាបាលទាន់ពេលវេលា ចំពោះជំងឺរាក និងជំងឺរលាកផ្លូវដង្ហើមធ្ងន់។ ប្រធាន ឬតំណាងនៃមណ្ឌលសុខភាពគួរប្រើទម្រង់របាយការណ៍ខាងក្រោមនេះ។

**ទម្រង់គំរូរបាយការណ៍**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត...........................
ក្រុង ស្រុក ខណ្ឌ ......................
ឃុំ សង្កាត់ .............................

**របាយការណ៍ពីមណ្ឌលសុខភាព**
**ខែ............ឆ្នាំ.............**

| ល.រ | ការបរិយាយ | ចំនួន | កំណត់សម្គាល់ |
|---|---|---|---|
| ១ | ចំនួនស្ត្រីមានផ្ទៃពោះដែលបានមកពិនិត្យមុនពេលសម្រាលនៅមណ្ឌលសុខភាពយ៉ាងហោចណាស់បានចំនួន០២ដង | | |
| ២ | ចំនួនស្ត្រីមានផ្ទៃពោះដែលបានសម្រាលកូននៅមណ្ឌលសុខភាព | | |
| ៣ | ចំនួនស្ត្រីដែលបានបំបៅកូនដោយទឹកដោះដំបូងបន្ទាប់ពីសម្រាលកូនភ្លាម នៅមណ្ឌលសុខភាព | | |
| ៤ | ចំនួនមរណភាពស្ត្រីក្នុងពេលមានផ្ទៃពោះ ពេលសម្រាលកូន ឬបន្ទាប់ពីសម្រាលកាលពីខែមុន | | |
| ៥ | ចំនួនមរណភាពទារកអាយុក្រោម០១ខែ នៅមណ្ឌលសុខភាព កាលពីខែមុន | | |
| ៦ | ចំនួនមរណភាពកុមារក្រោមអាយុ០១ឆ្នាំ នៅមណ្ឌលសុខភាព កាលពីខែមុន | | |
| ៧ | ចំនួនមរណភាពកុមារអាយុក្រោម០៥ឆ្នាំ នៅមណ្ឌលសុខភាព កាលពីខែមុន | | |
| ៨ | ចំនួនកុមាររងរបួស (បែងចែកតាមអាយុ និងប្រភេទ) ដោយមូលហេតុធ្លាក់ ពុលថ្នាំពស់ចឹក លង់ទឹក អំពើហិង្សា គ្រោះថ្នាក់ចរាចរណ៍ បានព្យាបាលនៅមណ្ឌលសុខភាព | | |
| ៩ | ចំនួនកុមារអាយុក្រោម០១ឆ្នាំ បានចាក់វ៉ាក់សាំងគ្រប់ចំនួន តាមរយៈដំណើរការកសាងផែនការខ្នាតតូច រវាងគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមប្រឹក្សាឃុំ សង្កាត់ | | |
| ១០ | នៅក្នុងខែមិថុនា និងធ្នូ ចំនួនកុមារអាយុក្រោម០៥ឆ្នាំទទួលបានវិតាមីនអា និងថ្នាំទម្លាក់ព្រូន | | |
| ១១ | ចំនួនកុមារដែលខ្វះអាហារូបត្ថម្ភត្រូវបានបញ្ជូនទៅ ឬត្រូវបានព្យាបាលនៅមណ្ឌល | | |

| | | | |
|---|---|---|---|
| | សុខភាព | | |
| ១២ | ចំនួនសកម្មភាពដែលចុះទៅដល់មូលដ្ឋានទៅតាមផែនការ ដែលបាន គ្រោងទុក ឬបានរៀបចំទុកដោយបុគ្គលិកមណ្ឌលសុខភាពដើម្បីធានាការចាក់វ៉ាក់សាំងគ្រប់ចំនួន ថ្នាំបញ្ចុះសត្វល្អិត និងការផ្តល់បន្ថែមនូវអាហារូបត្ថម្ភ | | |
| ១៣ | ចំនួនអ្នកជំងឺរាកដែលបានព្យាបាលទាន់ពេលវេលានៅមណ្ឌលសុខភាព | | |
| ១៤ | ចំនួនអ្នកជំងឺរលាកផ្លូវដង្ហើមធ្ងន់បានទទួលការព្យាបាលទាន់ពេលវេលា នៅមណ្ឌលសុខភាព ឬនៅភូមិ | | |
| ១៥ | ចំនួនបង្គន់អនាម័យដែលបានថែរក្សា និងបានបំពាក់កន្លែងលាងដៃ កន្លែងប្រើប្រាស់ទឹកស្អាត សម្រាប់អ្នកជំងឺ និងសម្រាប់បុគ្គលិកមណ្ឌលសុខភាព | | |

*ថ្ងៃទី.......ខែ........ឆ្នាំ..............*

**ហត្ថលេខា**

៦.២.៣. របាយការណ៍ផ្នែកអប់រំ

តាមរយៈការស្រង់ចំនួនប្រជាជនប្រចាំឆ្នាំទៅលើកុមារ និងក្នុងកិច្ចសហការជាមួយមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ សមាគមមាតាបិតាព្រមទាំងអ្នកពាក់ព័ន្ធផ្សេងៗ នាយកសាលារៀន ឬតំណាងដែលជាសមាជិក គ.ក.ន.ក គួរលើកទឹកចិត្តឲ្យកុមារគ្រប់រូបដែលមានអាយុចាប់ពី០៦ ទៅ១២ឆ្នាំ ទៅចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា និងបន្តចូលរៀន។ នាយកសាលារៀន ឬតំណាងគួររាយការណ៍អំពីព័ត៌មានផ្នែកអប់រំដោយប្រើប្រាស់ទម្រង់របាយការណ៍ខាងក្រោម។

**ទម្រង់គំរូរបាយការណ៍**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត...........................
ក្រុង ស្រុក ខណ្ឌ .......................
ឃុំ សង្កាត់ ..............................

**របាយការណ៍ពីសាលា**.........................
**ខែ**..........**ឆ្នាំ**............

| ល.រ | ការបរិយាយ | ចំនួនកុមារ | | |
|---|---|---|---|---|
| | | ស្រី | ប្រុស | សរុប |
| ១ | ចំនួនកុមារអាយុ០៦ទៅ១១ឆ្នាំ បានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា (បែងចែកតាមភេទ ជនជាតិដើមភាគតិច កុមារពិការ) | | | |
| ២ | ចំនួនកុមារអាយុ០៦ទៅ១១ឆ្នាំ បានចុះឈ្មោះចូលរៀនវិញ បន្ទាប់ពីអវត្តមានជាប់ៗគ្នាពីសាលារៀនច្រើនជាង១៥ថ្ងៃ (បែងចែកតាមភេទ ជនជាតិដើមភាគតិច និងកុមារពិការ) | | | |

| | | | | |
|---|---|---|---|---|
| ៣ | ចំនួនកុមារថ្នាក់បឋមសិក្សាដែលទទួលបានថ្នាំគ្រាប់ទម្លាក់ព្រូនក្នុងអំឡុងពេលសេវាសុខភាពចុះទៅដល់មូលដ្ឋាន(ដែលរៀបចំ២ដងក្នុង១ឆ្នាំដោយមណ្ឌលសុខភាពក្នុងកិច្ចសហការណ៍ជាមួយសាលារៀន) | | | |
| ៤ | ចំនួនបង្គន់អនាម័យដែលបានថែទាំ និងបានបំពាក់កន្លែងលាងដៃសាប៊ូ កន្លែងប្រើប្រាស់ទឹកស្អាតសម្រាប់សិស្ស និងសម្រាប់បុគ្គលិកសាលារៀន | | | |

*ថ្ងៃទី.......ខែ........ឆ្នាំ..............*

**ហត្ថលេខា**

៦.២.៤. របាយការណ៍នៃការចុះអត្រានុកូលដ្ឋាន

ស្មៀនឃុំ សង្កាត់ ដោយមានការសម្របសម្រួលជាមួយមេភូមិ ត្រូវលើកជំរុញឲ្យមានការចុះអត្រានុកូលដ្ឋានក្នុងឃុំ សង្កាត់ឲ្យបានគ្រប់ៗគ្នា។ ស្មៀនឃុំ សង្កាត់ត្រូវវាយការណ៍ពីការចុះអត្រានុកូលដ្ឋាន ដោយប្រើប្រាស់ទម្រង់នៃរបាយការណ៍ដូចខាងក្រោម។

**គំរូទម្រង់របាយការណ៍**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ......................

ក្រុង ស្រុក ខណ្ឌ..................

ឃុំ សង្កាត់..........................

**របាយការណ៍នៃការចុះអត្រានុកូលដ្ឋាន**

**ខែ**...........**ឆ្នាំ**.............

| ល.រ | ការបរិយាយ | ស្រី | ប្រុស | សរុប |
|---|---|---|---|---|
| ១ | ចំនួនទារកទើបកើតបានចុះបញ្ជីកំណើតក្នុងរយៈពេល៣០ថ្ងៃដំបូង | | | |
| ២ | ចំនួនអាពាហ៍ពិពាហ៍ដែលបានចុះបញ្ជី | | | |
| ៣ | ចំនួនមរណភាពដែលបានចុះបញ្ជី | | | |
| ៤ | បញ្ជីមូលហេតុនៃមរណភាព | | | |

*ថ្ងៃទី.......ខែ.......ឆ្នាំ...........*

**ហត្ថលេខា**

៦.២.៩. របាយការណ៍អំពីសន្តិសុខ និងសណ្តាប់ធ្នាប់

នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ឬតំណាងដែលជាសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវសហការជាមួយមេឃុំ ចៅសង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ មេភូមិ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីជំរុញ និងធានានូវសុវត្ថិភាពសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់ ហើយត្រូវវាយការណ៍អំពីញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់ដោយប្រើទម្រង់របាយការណ៍ដូចខាងក្រោម។

**គំរូទម្រង់របាយការណ៍**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ......................

ក្រុង ស្រុក ខណ្ឌ..................

ឃុំ សង្កាត់..........................

**របាយការណ៍អំពីបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់**

**សម្រាប់ខែ..........ឆ្នាំ...........**

| ល.រ | បញ្ហា | ដំណោះស្រាយ |
|---|---|---|
| ១ | ចំនួនកុមារដែលរងរបួសបានព្យាបាលនៅមណ្ឌលសុខភាព (បែងចែងតាមភេទ អាយុ និងប្រភេទរបួស ដូចជា ធ្លាក់ ពុល ពស់ចឹក លង់ទឹក អំពើហិង្សា គ្រោះថ្នាក់ចរាចរណ៍) និងសកម្មភាពអនុវត្តន៍ក្នុងការការពារគ្រោះថ្នាក់ ឬអន្តរាយ នានា | |
| ២ | ករណីចោរកម្ម | |
| ៣ | អំពើហិង្សា (រួមទាំងការរំលោភផ្លូវភេទ) | |
| ៤ | សកម្មភាពក្រុមក្មេងទំនើង | |
| ៦ | ល្បែងស៊ីសង | |

*ថ្ងៃទី.......ខែ.......ឆ្នាំ...........*

**ហត្ថលេខា**

៦.២.៦. របាយការណ៍អំពីការប្រើប្រាស់ថវិកា ក.គ.ន.ក

ស្មៀនឃុំ សង្កាត់ដែលជាបេឡាករឃុំ សង្កាត់ត្រូវធ្វើការជាមួយនឹងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងត្រូវវាយការណ៍អំពីការប្រើប្រាស់ថវិកាដោយប្រើទម្រង់របាយការណ៍ដូចខាងក្រោម។

**ទម្រង់គំរូរបាយការណ៍**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត .......................
ក្រុង ស្រុក ខណ្ឌ..................
ឃុំ សង្កាត់...........................

**របាយការណ៍អំពីការប្រើប្រាស់ថវិកា គ.ក.ន.ក**
**សម្រាប់ខែ..........ឆ្នាំ............**

| ល.រ | ការបរិយាយ | ថវិកាសរុប | ការចំណាយ | | | សមតុល្យ |
|---|---|---|---|---|---|---|
| | | | កន្លងមក | ក្នុងខែ | បូកយោង | |
| ១ | ការរៀបចំកិច្ចប្រជុំ | | | | | |
| ២ | សម្ភារៈការិយាល័យ | | | | | |
| ៣ | ថ្លៃធ្វើដំណើរ | | | | | |
| ៤ | អន្តរាគមន៍សេវាសង្គម | | | | | |
| **សរុប** | | | | | | |

*ថ្ងៃទី.......ខែ.......ឆ្នាំ...........*

**ហត្ថលេខា**

៦.២.៧. កំណត់ហេតុប្រជុំរបស់ ក.គ.ន.ក

ស្មៀនឃុំ សង្កាត់ ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវរៀបចំកំណត់ហេតុប្រជុំប្រចាំខែ ឆមាស និងប្រចាំឆ្នាំ ដោយប្រើទម្រង់កំណត់ហេតុប្រជុំដូចខាងក្រោម។

**ទម្រង់គំរូរបាយការណ៍**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ......................
ក្រុង ស្រុក ខណ្ឌ..................
ឃុំ សង្កាត់..........................

**កំណត់ហេតុប្រជុំ**
**របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់**
**សម្រាប់ខែ .............ឆ្នាំ.............**

ឆ្នាំ........ខែ..........ថ្ងៃទី..........វេលាម៉ោង...........(ថ្ងៃខែឆ្នាំត្រូវសរសេរជាអក្សរ) នៅ....................... បានរៀបចំកិច្ចប្រជុំប្រចាំខែ.............របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្រោមអធិបតីភាពលោកលោកស្រី........................... ជាប្រធាន គ.ក.ន.ក។

I. **សមាសភាពអ្នកចូលរួម**

សមាជិកសមាជិកានៃ គ.ក.ន.ក បានចូលរួមប្រជុំមានចំនួន............រូប ក្នុងនោះស្ត្រី.........រូបនៃសមាជិក គ.ក.ន.ក សរុបចំនួន.........រូប។

II. **របៀបវារៈ**

របៀបវារៈនៃការប្រជុំមានដូចខាងក្រោម ៖

១. ពិនិត្យលើរបាយការណ៍ប្រជុំខែមុន និងពិភាក្សាអំពីសកម្មភាពដែលបានអនុវត្ត
២. រាយការណ៍ និងពិភាក្សាអំពីបញ្ហាស្ត្រី និងកុមារដែលងាយរងគ្រោះបំផុត និងផ្តល់ព័ត៌មានទាន់ហេតុការណ៍អំពីព្រឹត្តិការណ៍ ឬសកម្មភាពសំខាន់ៗក្នុងសហគមន៍
៣. រាយការណ៍ និងពិភាក្សាអំពីផ្នែកអប់រំ
៤. រាយការណ៍ និងពិភាក្សាអំពីការចុះបញ្ជីកំណើតនៅក្នុងឃុំ សង្កាត់
៥. រាយការណ៍ និងពិភាក្សាអំពីការត្រៀមបម្រុង និងការឆ្លើយតប សម្រាប់ការសង្គ្រោះបន្ទាន់
៦. រាយការណ៍ និងពិភាក្សាអំពីបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់
៧. រាយការណ៍អំពីការប្រើប្រាស់ថវិការបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
៨. ផ្សេងៗ។

## III. លទ្ធផល

១). ពិនិត្យលើរបាយការណ៍ប្រជុំខែកន្លងមក

២). អំពីសកម្មភាព ឬព្រឹត្តិការណ៍សំខាន់ៗដែលទាក់ទងនឹងបញ្ហាស្ត្រី និងកុមារដែលងាយរងគ្រោះ

*ផែនការសកម្មភាព*

- ......................................................................................................................
- ......................................................................................................................
- ......................................................................................................................

៣). អំពីផ្នែកសេវាសុខភាព

*ផែនការសកម្មភាព*

- ......................................................................................................................
- ......................................................................................................................
- ......................................................................................................................

៤). អំពីផ្នែកអប់រំ

*ផែនការសកម្មភាព*

- ......................................................................................................................
- ......................................................................................................................
- ......................................................................................................................

៥). ការចុះបញ្ជីកំណើតកុមារនៅក្នុងឃុំ សង្កាត់

*ផែនការសកម្មភាព*

- ......................................................................................................................
- ......................................................................................................................
- ......................................................................................................................

៦). ការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការឆ្លើយតប

*ផែនការសកម្មភាព*

- ......................................................................................................................
- ......................................................................................................................
- ......................................................................................................................

៧). បញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងឃុំ សង្កាត់

*ផែនការសកម្មភាព*

- ......................................................................................................................

– ..........................................................................................................................

– ..........................................................................................................................

៧). ការប្រើប្រាស់ថវិកា គ.ក.ន.ក

– ..........................................................................................................................

– ..........................................................................................................................

– ..........................................................................................................................

៨). ផ្សេងៗ

– ..........................................................................................................................

– ..........................................................................................................................

– ..........................................................................................................................

**អ្នកធ្វើកំណត់ហេតុ**

ថ្ងៃទី..........ខែ..........ឆ្នាំ............

**ប្រធានអង្គប្រជុំ**

| |
|---|
| *បញ្ជាក់* ៖ របាយការណ៍តាមផ្នែកនីមួយៗ ត្រូវភ្ជាប់ជាមួយកំណត់ហេតុប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់។ |

៦.២.៨. របាយការណ៍រីកចម្រើនរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ

ស្មៀនឃុំ សង្កាត់ ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវរៀបចំរបាយការណ៍រីកចម្រើនរៀងរាល់០៣ខែម្តង (ពីខែមករាដល់ខែមីនា ខែមេសាដល់ខែមិថុនា ខែកក្កដាដល់ខែកញ្ញា និងខែតុលាដល់ខែធ្នូ) របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដោយប្រើទម្រង់របាយការណ៍ ទម្រង់ទី៦ និងទម្រង់ទី៧ ដូចបានរៀបរាប់ក្នុងផ្នែក៦.១ខាងលើ។

# ផ្នែកទីពីរ

# ការផ្ដោតស៊ីជម្រៅទៅលើសមធម៌សង្គម

# ១. ធ្វើការជាមួយសហគមន៍ដើម្បីត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងការដោះស្រាយ

## ១.១. ការប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជាធ្វើឲ្យមានបម្រែបម្រួលមួយចំនួនដូចជា ៖

- ការកើនឡើងកំដៅ
- ការប្រែប្រួលពេលវេលា និងថេរវេលានៃរដូវកាល (រដូវភ្លៀងមានរយៈពេលខ្លី រដូវក្តៅមានរយៈពេលវែង)
- ការកើនឡើងជាញឹកញាប់នៃទឹកជំនន់ និងភាពរាំងស្ងួត
- កម្រិតទឹកសមុទ្រកើនឡើងនៅតំបន់ឆ្នេរសមុទ្រ។

ការប្រែប្រួលអាកាសធាតុបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្ថានភាពនៃការរស់នៅ និងជីវភាពរបស់ប្រជាពលរដ្ឋ ជាពិសេស ទៅលើស្ត្រី និងកុមារដែលបញ្ហាទាំងនេះតម្រូវឲ្យ គ.ក.ន.ក ត្រូវត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់ និងឆ្លើយតបឲ្យបានទាន់ពេល និងទទួលបានប្រសិទ្ធភាពខ្ពស់។

គ្រោះមហន្តរាយ សំដៅទៅលើស្ថានភាពណាមួយដែលគំរាមកំហែងជីវិត និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ដែលតម្រូវឲ្យមានសកម្មភាពការពារបន្ថែមទៀតដើម្បីថែរក្សា ការពារ និងធានាអាយុជីវិតរបស់ពួកគេ។ គ្រោះមហន្តរាយអាចកើតឡើងភ្លាមៗ ឬក៏កើតឡើងយឺតៗ ដោយមិនបានរំពឹងទុកជាមុន ហើយស្ថានភាពនោះបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ជីវិត បំផ្លាញទ្រព្យសម្បត្តិ និងបង្អាក់ដល់សកម្មភាពនានា ដល់គ្រួសារ ឬដល់សហគមន៍ ដែលទាមទារឲ្យមានការប្រុងប្រយ័ត្ន និងស្វែងរកដំណោះស្រាយភ្លាមៗចំពោះគ្រោះមហន្តរាយនោះ។ គ្រោះមហន្តរាយអាចជាទឹកជំនន់ ភ្លើងឆេះផ្ទះ ភាពរាំងស្ងួត។ល។

## ១.២. គ្រោះមហន្តរាយអាចបង្អាក់ការអភិវឌ្ឍកុមារ

កុមារត្រូវទទួលរងបទពិសោធន៍អំពីគ្រោះមហន្តរាយខុសគ្នាពីមនុស្សពេញវ័យពីព្រោះ៖

- កុមាររស់នៅក្នុងវ័យដំបូង បានជះឥទ្ធិពលផ្ទាល់ទៅដល់ការអភិវឌ្ឍផ្នែកកាយសម្បទា បញ្ញាស្មារតី អារម្មណ៍ និងផ្នែកសង្គម
- គ្រោះមហន្តរាយអាចនាំឲ្យមានការព្រាត់ប្រាស់ក្រុមគ្រួសារ បាត់បង់សមាជិកគ្រួសារ។ ពួកគេមានអារម្មណ៍ត្រូវគេបោះបង់ និងអាចមានហិង្សាក្នុងចិត្ត
- គ្រោះមហន្តរាយងាយប៉ះពាល់ដល់កាយសម្បទារបស់កុមារ ដូចជា ពួកគេងាយឆ្លងជំងឺផ្សេងៗ
- គ្រោះមហន្តរាយអាចប៉ះពាល់ទៅដល់ការអប់រំរបស់កុមារ ដូចជា មិនអាចទៅសាលារៀនបាន
- ក្នុងករណីដែលគ្មានសុវត្ថិភាពស្បៀង ឬភាពរាំងស្ងួត កុមារជាច្រើន ជាពិសេស កុមារីបានបោះបង់ចោលការសិក្សា។

## ១.៣. សហគមន៍ងាយរងគ្រោះ

សហគមន៍មួយចំនួនងាយនឹងទទួលភាពរងគ្រោះជាងសហគមន៍ឯទៀត។ ភាពងាយរងគ្រោះនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងភាពក្រីក្រ និងភាពនៅដាច់ឆ្ងាយពីសង្គម។ ភាពងាយរងគ្រោះមានធាតុផ្សំពីរ ៖

ក. ហានិភ័យ ៖ ដូចជាទឹកជំនន់ វិបត្តិសេដ្ឋកិច្ច ការប្រមូលផលមិនបាន សង្គ្រាម ភាពអត់ការងារធ្វើ និងជំងឺធ្ងន់ផ្សេងៗ

ខ. សមត្ថភាព ៖ សមត្ថភាពឆ្លើយតប និងសមត្ថភាពសម្របខ្លួនពេលជួបគ្រោះមហន្តរាយ។

*សញ្ញាណខ្លះៗនៃការកើនឡើងនូវភាពតានតឹងផ្លូវចិត្ត ៖*

- ប្រើប្រាស់គ្រឿងស្រវឹង និងថ្នាំញៀន
- ខឹង (ឆាប់ផ្ទុះកំហឹង)
- នៅដាច់ឆ្ងាយពីសង្គម
- ថប់អារម្មណ៍ និងបាក់ទឹកចិត្ត
- សម្ព័ន្ធភាពប្រេះឆា
- ខ្វះការយកចិត្តទុកដាក់លើការរៀនសូត្រ ការធ្វើការងារ និងធ្វើឲ្យលទ្ធផលការងារធ្លាក់ចុះ
- មានជំងឺរ៉ាំរ៉ៃរោគសញ្ញាមិនច្បាស់លាស់ ឬមូលហេតុមិនគ្រប់គ្រាន់។

## ១.៤. សហគមន៍ដែលរឹងមាំ

សហគមន៍ដែលរឹងមាំ គឺជាសមត្ថភាពនៃប្រព័ន្ធមួយ ដូចជាសហគមន៍ ឬសង្គម ក្នុងការសម្របខ្លួនឲ្យត្រឡប់មកដំណើរការល្អឡើងវិញបន្ទាប់ពីជួបគ្រោះមហន្តរាយណាមួយ។ មានន័យថា សហគមន៍នោះអាចបង្កើនសមត្ថភាពរបស់ខ្លួនតាមរយៈគ្រោះមហន្តរាយពីអតីតកាល និងសម្រាប់ការការពារពេលអនាគត និងធ្វើឲ្យប្រសើរឡើងនូវវិធានការកាត់បន្ថយហានិភ័យ។

*សហគមន៍ដែលរឹងមាំគឺជាសហគមន៍ដែល ៖*

- គាំទ្រ និងពង្រីកការប្រាស្រ័យទាក់ទង និងភាពសុខដុមក្នុងសង្គម
- ពង្រឹងការជួយគ្នាក្នុងសហគមន៍ និងអ្នកជិតខាង ឧទាហរណ៍ ក្រុមជួយខ្លួនឯង
- ពង្រឹងបន្ថែមលើចំណុចខ្លាំង មិនមែនចំណុចខ្សោយ
- លើកកម្ពស់ការចូលរួមរៀបចំខ្លួនឯង និងភាពជាម្ចាស់
- ប្រើប្រាស់ធនធាននៅក្នុងសហគមន៍ ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយ និងកាត់បន្ថយផលប៉ះពាល់នោះ។

*សហគមន៍ខ្លះមានភាពរឹងមាំដោយសារៈ*

- ស៊ាំទៅនឹងភាពតក់ស្លុតដែលកើតឡើង ហើយសហគមន៍នៅតែដំណើរការការងាររបស់ខ្លួនបានដដែល
- អាចរៀបចំចាត់ចែង និងដោះស្រាយបានដោយខ្លួនឯងនៅពេលដែលសហគមន៍ជួបវិបត្តិ
- ពួកគេបង្កើតឡើងដើម្បីសង្គ្រោះជីវិត។

## ១.៥. ការត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយ

សហគមន៍មួយដែលរឹងមាំ គឺជាសហគមន៍ដែលធ្វើការរួមគ្នាយ៉ាងសស្រាក់សស្រាំ ដើម្បីរៀបចំផែនការសហប្រតិបត្តិការមួយដែលត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយដោយ ៖

- កំណត់រកតំបន់ដែលងាយរងផលប៉ះពាល់ពីគ្រោះមហន្តរាយ។ ឧទាហរណ៍ តំបន់ទំនាបជិតស្ទឹង

ទន្លេ និងតំបន់ងាយរងគ្រោះដោយទឹកជំនន់

- កំណត់រកតំបន់គ្រោះថ្នាក់ (hotspot) ដែលត្រូវដាក់សញ្ញាគ្រោះថ្នាក់។ ឧទាហរណ៍ ចម្ការមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- កំណត់ឲ្យបាននូវប្រការគំរាមកំហែង ឬស្ថានភាពធ្ងន់ធ្ងរណាមួយដែលស្ត្រី និងកុមារអាចនឹងទទួលរងគ្រោះ (សិស្សមត្តេយ្យ និងសិស្សបឋមសិក្សាត្រឡប់មកផ្ទះវិញនៅពេលមានទឹកជំនន់ ស្ត្រីមានផ្ទៃពោះត្រូវសម្រាលកូននៅរដូវភ្លៀង)
- លើកកម្ពស់ឲ្យមានការពិភាក្សា និងការសម្រេចចិត្តអំពីកម្រិតនៃភាពចាំបាច់ និងកម្រិតអប្បបរមាចំពោះអ្វីដែលបានត្រៀម
- ធានាថាគ្រប់អ្នកពាក់ព័ន្ធទាំងអស់យល់ដឹងពីការងារចម្បង និងការទទួលខុសត្រូវរបស់ខ្លួនក្នុងពេលមានគ្រោះមហន្តរាយ (តើនរណានឹងទទួលខុសត្រូវលើការងារអ្វី?) ព្រមទាំងព្រមព្រៀងលើយន្តការសម្របសម្រួលដើម្បីធានាពីចរន្តនៃការប្រាស្រ័យទាក់ទង
- កំណត់តម្រូវការ និងកសាងសមត្ថភាពសមាជិក គ.ក.ន.ក និងអ្នកពាក់ព័ន្ធនានា។ ការត្រៀមលក្ខណៈរបៀបនេះ គឺធ្វើឲ្យពួកគាត់អាចជួយសហគមន៍បាននៅពេលដែលត្រូវការការសង្គ្រោះបន្ទាន់
- កំណត់អ្វីដែលត្រូវធ្វើក្នុងការរៀបចំសម្រាប់ការសង្គ្រោះបន្ទាន់ (ឧទាហរណ៍ ត្រៀមបម្រុងទីទួលសុវត្ថិភាពសម្រាប់ជម្លៀសប្រជាពលរដ្ឋ)
- កំណត់រកអ្នកណាទទួលខុសត្រូវ អ្វីដែលត្រូវត្រៀមបម្រុង និងពេលវេលាដែលត្រូវធ្វើ

***សំណួរមួយចំនួនជាជំនួយក្នុងការត្រៀមបម្រុងសម្រាប់គ្រោះទឹកជំនន់ ៖***

សំណួរទី១ ដល់ទី៨ ជាជំនួយនៅក្នុងការកសាងផែនការត្រៀមបម្រុងសម្រាប់គ្រោះទឹកជំនន់ និងសំណួរទី៩ ជាជំនួយក្នុងការកសាងផែនការឆ្លើយតបទៅនឹងគ្រោះទឹកជំនន់ (មុនពេលរដូវវស្សា)។

| សំណួរ | ការឆ្លើយតបមួយចំនួន |
|---|---|
| ១. តើប្រជាជនរស់នៅតំបន់ដែលរងគ្រោះដោយទឹកជំនន់ដឹងពីរបៀបរក្សាទុកឯកសារ (សំបុត្រកំណើត ប្លង់ដី សំបុត្រអាពាហ៍ពិពាហ៍ ឲ្យមានសុវត្ថិភាព ងាយស្រួលរកនៅពេលមានទឹកជំនន់ឬទេ? | យកកិច្ចប្រជុំភូមិដើម្បីជូនដំណឹងដល់ប្រជាពលរដ្ឋពីសារៈសំខាន់នៃបញ្ជីអត្រានុកូលដ្ឋាន និងការថែរក្សាបញ្ជីទាំងនោះទុកឲ្យមានសុវត្ថិភាព។ ពន្យល់ពួកគាត់ពីផលលំបាកប្រសិនបើសំបុត្រទាំងនោះបាត់បង់។ |
| ២. តើមានចាស់ជរា និងជនពិការដែរឬទេ? | ធ្វើការជាមួយសមាជិក គ.ក.ន.ក ដើម្បីរៀបចំតារាងចំនួនចាស់ជរា ឬជនពិការ និងទីតាំងដែលពួកគាត់រស់នៅ។ |
| ៣. តើមានស្ត្រីប៉ុន្មាននាក់ដែលសម្រាលកូននៅក្នុងរដូវភ្លៀង? | - បង្កើតតារាងឈ្មោះស្ត្រីមានផ្ទៃពោះទាំងអស់ ព្រមទាំងទីកន្លែងដែលគាត់រស់នៅ (ក្នុងភូមិណា?)<br>- ពិពណ៌នាពីចម្ងាយផ្លូវពីផ្ទះរបស់គាត់ទៅមណ្ឌលសុខភាព និងស្ថានភាពផ្លូវនោះក្នុងរដូវភ្លៀង និងពេលមានទឹកជំនន់<br>- ពិភាក្សាជាមួយបុគ្គលិកសុខាភិបាលដើម្បីធានាថា ស្ត្រីមានផ្ទៃពោះទាំងអស់អាចទៅមណ្ឌលសុខភាពដើម្បី |

| | |
|---|---|
| | ពិនិត្យផ្ទៃពោះ សម្រាលនៅមណ្ឌលសុខភាព និងថែទាំសុខភាពក្រោយពេលសម្រាលនៅអំឡុងពេលរដូវភ្លៀង និងទឹកជំនន់<br>- តើនរណាគួរជួយ ឬទៅជាមួយគាត់?<br>- តើអាចមានសេវាសុខភាពចល័តរៀបចំឡើងឬទេ?<br>- តើស្ត្រីមានផ្ទៃពោះទាំងនោះដឹងទេថា ពួកគាត់ត្រូវទៅពិនិត្យផ្ទៃពោះញឹកញាប់ប៉ុណ្ណា?<br>- តើអ្វីខ្លះដែល គ.ក.ន.ក អាចគាំទ្រពួកគាត់បាន? |
| ៤. តើមានត្រៀមមធ្យោបាយពន្យារកំណើតសម្រាប់ពេលមានគ្រោះមហន្តរាយដែរឬទេ? | សហការជាមួយបុគ្គលិកមណ្ឌលសុខភាពកំណត់ពីតម្រូវការមធ្យោបាយពន្យារកំណើត និងត្រៀមនូវចំនួនសមស្របណាមួយសម្រាប់ពេលមានអាសន្ន |
| ៥. តើមានការកំណត់តំបន់ណាខ្លះដែលជាតំបន់គ្រោះថ្នាក់ (hotspots)នៅពេលមានគ្រោះទឹកជំនន់ដែរឬទេ? | - កំណត់តំបន់ដែលមានគ្រោះថ្នាក់ដោយភាពកខ្វក់នៅពេលដែលមានទឹកជំនន់មកដល់ (តំបន់រ៉ែ តំបន់ធ្វើជី និងកន្លែងចាក់សំរាម។ល។)<br>- ធ្វើការជាមួយសមាជិកសហគមន៍ដើម្បីធានាថាពួកគាត់រក្សាទុកជីនិងសារធាតុគីមីផ្សេងៗឲ្យមានសុវត្ថិភាពល្អ |
| ៦. តើមានសមាជិកណាម្នាក់ក្នុងសហគមន៍តាមដានកម្រិតទឹកឡើង ឬស្រកដែរឬទេ? | - ធ្វើការជាមួយមេភូមិដើម្បីធានាថា មានការតាមដានកំពស់ទឹកជាប្រចាំ<br>- ធានាថាព័ត៌មាននេះត្រូវបានកត់ទុក និងរាយការណ៍ជាប្រចាំជូនថ្នាក់ស្រុក និងថ្នាក់ខេត្ត<br>- កំណត់កម្រិតសំខាន់ជាយុទ្ធសាស្ត្រដើម្បីត្រៀមក្នុងការផ្លាស់ប្តូរទីតាំង និងជម្លៀសប្រជាជន |
| ៧. នៅទីទួលសុវត្ថិភាព ៖<br>- តើអ្នកមានកំណាត់កៅស៊ូ ធុងជ័រ គ្រែ។ល។ គ្រប់គ្រាន់សម្រាប់ជម្រកបណ្តោះអាសន្នដែរឬទេ?<br>- តើមានបង្គន់អនាម័យគ្រប់គ្រាន់ដែរឬទេ? ( បង្គន់មួយសម្រាប់មនុស្ស២០នាក់)<br>- តើពួកគាត់អាចទទួលបានទឹកស្អាតដែរឬទេ? តើមានទីកន្លែងលាងដៃដែលមានសាប៊ូទុកនៅជាប្រចាំដែរឬទេ?<br>- តើអ្នកបានទុកដាក់វត្ថុសំខាន់ៗនៅក្នុងកន្លែងត្រឹមត្រូវហើយឬនៅ?<br>- តើអ្នកបានទុកដាក់ម្ហូបអាហារបានត្រឹមត្រូវហើយឬនៅ?<br>- តើអ្នកអាចទុកចំណីសម្រាប់សត្វពាហនៈបានត្រឹមត្រូវហើយឬនៅ?<br>- តើអ្នកមានទុកកន្លែងទំនេរខ្លះសម្រាប់ជាកន្លែងក្មេងលេង និងកន្លែងសុវត្ថិភាពរបស់កុមារឬទេ? | ធ្វើការជាមួយមេភូមិដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពី ៖<br>- តើទីទួលសុវត្ថិភាពនៅឯណា? ដីទួល?<br>- តើការជម្លៀសនឹងធ្វើតាមរបៀបណា?<br>- តើយើងគួរប្រមូលប្រជាពលរដ្ឋមកពីតំបន់ណាខ្លះ?<br>- តើអ្វីខ្លះដែលប្រជាពលរដ្ឋគួរយកតាមខ្លួន?<br>- តើពួកគាត់គួរតែទុកផ្ទះចោលឲ្យមានសុវត្ថិភាពតាមរបៀបណា?<br>- តើពួកគាត់រក្សាទុកឯកសារសំខាន់ៗយ៉ាងដូចម្តេច? (បញ្ជីកំណើត ប្លង់ដី។ល។)<br>- ធានាថាមានការអនុវត្តអនាម័យបានត្រឹមត្រូវ ដូចជា លាងដៃជាមួយសាប៊ូ<br>និងមានបង្គន់ប្រើប្រាស់នៅទីទួលសុវត្ថិភាពដោយធានាថាទាំងស្ត្រី និងបុរសមានបង្គន់អនាម័យសម្រាប់ប្រើប្រាស់ មានកន្លែងលាងដៃដែលមានសាប៊ូជាប្រចាំ<br>- ធានាថាពួកគាត់ទទួលបានទឹកដែលមានសុវត្ថិភាព<br>- ធានាសម្ភារៈផ្គត់ផ្គង់ការរៀនសូត្រជាមូលដ្ឋានអាចរកបាន |

| | |
|---|---|
| | - រៀបចំថ្នាក់រៀន និងកន្លែងលេងដែលមានសុវត្ថិភាពសម្រាប់កុមារដែលត្រូវជម្លៀសទៅទីទួលសុវត្ថិភាព<br>- ធានាថាពួកគាត់ទទួលបានការថែទាំសុខភាពជាមូលដ្ឋាន។<br>***<u>សម្គាល់</u>*** ៖ សាលារៀនគួរតែជាជម្រើសចុងក្រោយក្នុងការធ្វើការសម្រេចចិត្តក្នុងការជម្លៀស ឬផ្លាស់ប្តូរទីកន្លែង។ ដោយសារតែការផ្លាស់ប្តូរនេះធ្វើឲ្យបង្អាក់នូវប្រព័ន្ធអប់រំ។ |
| ៨. តើសមាជិកសហគមន៍ រួមទាំងកុមារដឹងថា តើអ្វីដែលពួកគេត្រូវការក្នុងករណីមានគ្រោះមហន្តរាយដែរឬទេ? | - ផ្តល់ឲ្យសមាជិកសហគមន៍នូវព័ត៌មានអំពីគ្រឿងប្រដាប់សម្រាប់ការសង្គ្រោះបន្ទាន់<br>- លើកទឹកចិត្តឲ្យពួកគាត់រៀបចំគ្រឿងប្រដាប់មុនពេលរដូវភ្លៀង លើកទឹកចិត្តឲ្យពួកគាត់ពិភាក្សាជាមួយកុមារ<br>***<u>សម្គាល់</u>*** ៖ សាប៊ូ មុង យ៉ាងហោចណាស់មានធុងទឹក០២ មួយសម្រាប់យួរទឹក និងមួយទៀតសម្រាប់ផ្ទុកទឹក ខោអាវសម្រាប់ផ្លាស់ប្តូរ និងគ្រាប់ពូជសម្រាប់ការដាំដុះលើកក្រោយទៀត។ |
| ៩. ទឹក និងអនាម័យ ៖<br>- តើទួលសុវត្ថិភាពមានទឹកស្អាតសម្រាប់ដាំបាយ និងអនាម័យផ្ទាល់ខ្លួនទេ?<br>- នៅទួលសុវត្ថិភាព បើសិនទឹកមិនស្អាត តើពួកគាត់ត្រូវធ្វើយ៉ាងណា? (ដាំទឹក ចម្រោះទឹក ឬប្រើថ្នាំក្លរ៉ាមីន)<br>- តើត្រូវស្តុកទឹកទុកដោយរបៀបណា?<br>- តើសហគមន៍ដឹងពីរបៀបរក្សាទឹកស្អាត និងមានសុវត្ថិភាព នៅពេលមានទឹកជំនន់ដែរឬទេ? (ធុងទឹកធំៗដើម្បីផ្ទុកទឹកឲ្យមានសុវត្ថិភាព ធុងចម្រោះ ថ្នាំក្លរ៉ាមីន បើសិនជាដាំទឹក តើមាន អុស ធ្យូង ឬហ្គាស ឈើគូស និងដែកកែសគ្រប់គ្រាន់ដែរឬទេ?<br>- តើស្ត្រី និងកុមារទាំងអស់ដឹងពីគ្រោះថ្នាក់នៃសុខភាពដោយសារជំងឺនានានៅពេលទឹកជំនន់ដែរឬទេ? (គ្រុនចាញ់ គ្រុនឈាម រាករូសស្រួចស្រាវ រាកមួលពស់ចឹក)<br>តើពួកគាត់មានកំណាត់ប្លាស្ទិកគ្រប់គ្រាន់សម្រាប់ជម្រកបណ្តោះអាសន្នដែរឬអត់? | ធ្វើការជាមួយមន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទ និងសុខាភិបាលដើម្បី ៖<br>- ផ្តល់ព័ត៌មានពីគ្រោះថ្នាក់នៃការមិនមានអនាម័យ និងវិធីការពារមួយចំនួន (ការឆ្លងមេរោគក្នុងទឹកអណ្តូង សារៈសំខាន់នៃការ ដាំទឹក ចម្រោះទឹក និងដាក់ថ្នាំក្លរ៉ាមីន លាងដៃជាមួយសាប៊ូមុនពេលទទួលទានបាយ ពេលរៀបចំអាហារ ក្រោយចេញពីបង្គន់ ក្រោយពេលប៉ះពាល់សត្វ និងក្រោយពេលលាងគូថឱ្យកូន។<br>- តាមដានការអនុវត្តអនាម័យសំខាន់ៗព្រមទាំងប្រដាប់ប្រដាមួយចំនួន ដូចជា តើមានម៉ាស៊ីនបូមទឹក និងឧបករណ៍ចម្រោះទឹកនៅដំណើរការល្អឬទេ? តើបង្គន់ថែទាំបានស្អាត ឬទេ? តើមានសាប៊ូនៅអាងលាងដៃដែរឬទេ?<br>- ផ្សព្វផ្សាយពីរបៀបរក្សាទឹកស្អាត (ដាំទឹក ចម្រោះទឹក និងដាក់ថ្នាំក្លរ៉ាមីន)<br>- ធានាថាបុគ្គលិកផ្នែកសុខាភិបាលរក្សាបញ្ជីថ្នាំដែលត្រូវការចាំបាច់ឱ្យមាននៅក្នុងដៃ និងដឹងពីរបៀប និងកន្លែងដែលត្រូវស្នើសុំថ្នាំសម្រាប់ផ្គត់ផ្គង់នៅអំឡុងពេលមានទឹកជំនន់<br>- តើសេវាកម្មវេជ្ជសាស្ត្រចល័ត (mobile medical service) អាចធ្វើឡើងនៅពេលបន្ទាន់បានទេ?<br>តើសម្ភារៈបរិក្ខារពេទ្យ និងថ្នាំពេទ្យការពារបានល្អទេ? |
| ១០.ការបន្តការអប់រំ តាមរយៈការធ្វើឲ្យប្រក្រតីឡើងវិញ (ជាការសំខាន់ណាស់សម្រាប់កុមារ ក្នុងការត្រឡប់ទៅរកប្រក្រតីភាពឡើងវិញឲ្យបានឆាប់) ៖<br>- តើកុមារ និងគ្រូអាចទៅសាលាដោយសុវត្ថិភាពបានឬនៅ?<br>- តើពួកគេយល់ដឹងពីគ្រោះថ្នាក់ពេលទៅសាលារៀន | ធ្វើការជាមួយសមាជិក គ.ក.ន.ក ជាពិសេសអ្នកតំណាងសាលា និងមាតាបិតាសិស្ស ដើម្បីការពារហានិភ័យនានាដែលអាចកើតឡើងក្នុងការធ្វើដំណើរនៅពេលមានទឹកជំនន់។ តើយើងគួរធ្វើអ្វីខ្លះដើម្បីកុំឱ្យមានហានិភ័យនោះកើតឡើង? ប្រមើលមើលថាតើថ្នាក់រៀនអាចរៀបចំនៅទីទួលសុវត្ថិភាពបានដែរឬទេ? |

| | |
|---|---|
| នៅអំឡុងពេលមានទឹកជំនន់ដែរឬទេ?<br>- តើសៀវភៅសិក្សា (សម្ភារៈសិក្សា គ្រឿងសង្ហារឹមនានាក្នុងសាលារៀន ត្រូវបានការពារបានត្រឹមត្រូវឬទេ?<br>- បើសិនជាមានការជម្លៀសទៅទីទួលសុវត្ថិភាព តើមានរៀបចំសាលាឲ្យកុមាររៀនដែរឬទេ? | |
| ១១.កិច្ចការពារកុមារ ៖<br>- តើមានកុមារកំព្រា កុមារងាយរងគ្រោះ ឬកុមារបែកពីគ្រួសារ ហើយតើនរណាថែទាំពួកគេ?<br>- តើនរណាជួយពួកគេក្នុងពេលជំលៀស? | - សហការជាមួយសមាជិក គ.ក.ន.ក ដើម្បីឱ្យគាត់ដឹងពីតម្រូវការរបស់កុមារកំព្រា និងកុមារងាយរងគ្រោះ ដែលអាចត្រូវការជំនួយពិសេសណាមួយ<br>- តែងតាំងអ្នកទទួលខុសត្រូវដែលជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ |
| ១២.តើមានផែនការត្រៀមបម្រុងសម្រាប់ការសង្គ្រោះបន្ទាន់រួចរាល់ហើយឬនៅ? | ធ្វើការជាមួយ គ.ក.ន.ក និងអ្នកពាក់ព័ន្ធដើម្បីកសាងផែនឆ្លើយតបនឹងគ្រោះមហន្តរាយរួមមាន ៖<br>- កំណត់របៀបដែលឃុំ សង្កាត់ត្រូវធ្វើសកម្មភាពនៅពេលមានគ្រោះទឹកជំនន់<br>- កំណត់ថាតើនរណាត្រូវធ្វើការប៉ាន់ប្រមាណបន្ទាន់ (សូមមើលតារាង១.៦ខាងក្រោម) និងរបៀបចែករំលែកព័ត៌មានជាមួយឃុំ សង្កាត់ ខេត្ត និងដៃគូអភិវឌ្ឍន៍ (អង្គការក្នុងស្រុក និងអង្គការអន្តរជាតិ)<br>- កំណត់ពីរបៀបសហការណ៍ក្នុងការឆ្លើយតបរបស់ឃុំ សង្កាត់ (តើនរណាត្រូវធ្វើអ្វី?) ធានាថាសមាជិកម្នាក់ៗដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន និងរបៀបដែលពួកគាត់ចែករំលែកតួនាទី និងភារកិច្ច (នរណានឹងត្រូវកោះហៅមកប្រជុំ? នរណាទំនាក់ទំនងជាមួយនគរបាល? នរណាធ្វើការទាក់ទងជាមួយដៃគូអភិវឌ្ឍន៍ នរណាធ្វើការទាក់ទងជាមួយគ្រួសារដែលរងគ្រោះ? |
| ១៣.ផ្សេងៗ<br>- សួរខ្លួនឯងនូវសំណួរផ្សេងៗដែលទាក់ទងទៅនឹងសហគមន៍របស់អ្នក | - កំណត់តួនាទី និងការទទួលខុសត្រូវ<br>- បែងចែកការងារក្នុងចំណោមសមាជិក គ.ក.ន.ក |

# គ្រឿងប្រដាប់សម្រាប់សង្គ្រោះបន្ទាន់







សាប៊ូ


មុង


ធុងជ័រ


សម្លៀកបំពាក់


គ្រាប់ពូជ

## ១.៦. **បញ្ជីប៉ាន់ប្រមាណបន្ទាន់** (ត្រូវធ្វើនៅអំឡុងពេលពី៤៨ ទៅ៧២ម៉ោង បន្ទាប់ពីមហន្តរាយកើតឡើង)

តម្រូវការដើម្បីឆ្លើយតបនឹងការសង្គ្រោះបន្ទាន់ប្រកបដោយប្រសិទ្ធភាព ត្រូវចាប់ផ្តើមពីការធ្វើការប៉ាន់ប្រមាណបន្ទាន់ ដែលដឹកនាំ និងសម្របសម្រួលដោយ គ.ក.ន.ក។

| | |
|---|---|
| ១. ការកំណត់ព័ត៌មាន | - នៅតាមភូមិ ឃុំ សង្កាត់ |
| ២. ចំនួនប្រជាជន ការតាំងទីលំនៅ ការប្តូរទីលំនៅ | - ជំនួនប្រជាជនសរុបដែលបានធ្វើការប៉ាន់ប្រមាណ (ចែកតាមភេទ អាយុ០ដល់០៥ឆ្នាំ ០៦ដល់១១ឆ្នាំ ក្មេងជំទង់ មនុស្សពេញវ័យ) ជនដែលរងគ្រោះដោយមហន្តរាយ (ចែកតាមអាយុ ភេទ ចំនួនអ្នកស្លាប់ អ្នកបាត់ខ្លួន និងអ្នកដែលខូចខាតផ្ទះសម្បែង) |
| ៣. ការការពារកុមារ | - តើមានកុមារដែលព្រាត់ប្រាស់ឳពុកម្តាយដែរឬទេ?<br>- តើមានក្មេងកំព្រាទេ?<br>- តើនរណាថែរក្សាកុមារកំព្រា កុមារដែលព្រាត់ប្រាស់ឳពុកម្តាយ?<br>- តើមានការព្រួយបារម្ភចំពោះសុវត្ថិភាពដែរឬទេ?<br>- តើមានការព្រួយបារម្ភចំពោះកាយសម្បទាដែរឬទេ? |
| ៤. ការអប់រំ | - ចំនួនសាលាដែលអាចប្រើការបានមុនពេលមានគ្រោះមហន្តរាយ (មត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ<br>- ចំនួនសាលារៀនដែលត្រូវបំផ្លាញខូចខាត<br>- ចំនួនគ្រូដែលរងគ្រោះដោយមហន្តរាយ<br>- ប្រភេទសម្ភារៈ ឬឧបករណ៍ដែលទទួលរងការខូចខាត<br>- ប្រភេទសម្ភារៈ ឬឧបករណ៍ដែលចាំបាច់សម្រាប់ការអប់រំ<br>- តើសម្ភារៈសម្រាប់ការរៀនសូត្រអាចជួសជុលបានវិញសម្រាប់ការរៀនសូត្រឬទេ? |
| ៥. សុខភាព | - ចំនួនស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅកូនដោយទឹកដោះ<br>- ចំនួនកុមារអាយុក្រោម០៥ឆ្នាំ<br>- សេវាសុខភាព (មណ្ឌលសុខភាព ផ្គត់ផ្គង់ថ្នាំពេទ្យ និងសម្ភារៈបរិក្ខារពេទ្យ) ដែល |

| | |
|---|---|
| | សហគមន៍អាចទទួលបាន និងចម្ងាយផ្លូវដែលសហគមន៍ទៅទទួលសេវានោះ<br>- តំណាងបុគ្គលិកសុខាភិបាលនៅមណ្ឌលសុខភាព រួមទាំងឆ្មប<br>- ចំនួនកុមារដែលឆ្លងជំងឺ មានរបួស រាករូស រាកមូល ជំងឺផ្លូវដង្ហើម ជំងឺគ្រុនឈាម ជំងឺគ្រុនចាញ់ ឬពស់ចឹក។ល។ |
| ៦. កង្វះអាហារូបត្ថម្ភ | - ចំនួនកុមារខ្វះអាហារូបត្ថម្ភដែលបានព្យាបាលនៅមណ្ឌលសុខភាព (ទទួលបានបទពិសោធន៍អ្វីខ្លះនៅពេលមានគ្រោះទឹកជំនន់កើនឡើងជាបន្តបន្ទាប់?) |
| ៧. សុវត្ថិភាពស្បៀង | - តើមានផ្សារបើកលក់ឬទេ?<br>- តើផ្ទះនីមួយៗមានស្បៀងសម្រាប់បរិភោគដែរឬទេ?<br>- តើផ្ទះនីមួយៗមានប្រាក់សម្រាប់ទិញស្បៀងដែរឬទេ?<br>- តើផ្ទះនីមួយៗអាចទទួលបានទឹកសុវត្ថិភាពដែរឬទេ?<br>- តើស្បៀងប្រភេទណាដែលអាចរកបាន?<br>- តើអាចរកបានចំណីសត្វឬទេ? |
| ៨. ទីជម្រក និងសម្ភារៈសំខាន់ៗ | - ចំនួនគ្រួសារដែលបាត់បង់ផ្ទះសម្បែង<br>- ចំនួនផ្ទះដែលខូចខាត<br>- ចំនួនគ្រួសារដែលរស់នៅក្នុងជម្រកបណ្ដោះអាសន្ន (ស្ថានភាពជម្រក[១])<br>- តើគ្រួសារនានា ស្ត្រី និងកុមារ មានភាពឯកជនឬទេ? តើពួកគេមានសុវត្ថិភាពដែរឬទេ?<br>- តើជម្រកនោះស្ថិតនៅឯណា?<br>- តើនរណាជាអ្នកផ្ដល់ជម្រក?<br>- តើពួកគេមានបង្គន់[២]គ្រប់គ្រាន់ និងកន្លែងលាងដៃសម្រាប់មនុស្សគ្រប់គ្នាដៃឬទេ?<br>- ការទទួលបានសម្ភារៈដូចជាសម្លៀកបំពាក់សម្រាប់ប្ដូរ ភួយ អនាម័យ កញ្ចប់សម្រាប់បុរស និងស្ត្រី ធុងទឹក និងគ្រឿងប្រដាប់សម្រាប់ចម្អិន រួមមានដែកកេសជាដើម។ល។ |
| ៩. ទឹក និងអនាម័យ | - ការទទួលបានទឹក (ទឹកផឹក ទឹកងូត ទឹកដាំបាយ)[៣]<br>- តើមានចែកបន្ទប់ទឹកសម្រាប់ស្ត្រីផ្សេង និងបុរសផ្សេងដែរឬទេ?<br>- តើមានប្រភពទឹកស្អាតសម្រាប់ទឹកផឹកដែរឬទេ?<br>- តើប្រជាពលរដ្ឋត្រូវធ្វើដំណើរឆ្ងាយប៉ុណ្ណាដើម្បីទៅរកទឹក?<br>- តើអ្នកណាជាអ្នកផ្គត់ផ្គង់ទឹក?<br>- តើបង្គន់អនាម័យនៅដំណើរការល្អឬទេ?<br>- តើប្រជាពលរដ្ឋបន្ទោរបង់នៅឯណា? |
| ១០.ការឆ្លើយតបរបស់ដៃគូអភិវឌ្ឍន៍នានាក្នុងពេលមានទឹកជំនន់ | បញ្ជីដៃគូអភិវឌ្ឍន៍នានា (អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ភ្នាក់ងាររដ្ឋាភិបាល) ដែលបានចូលរួមធ្វើអន្តរាគមន៍ តាម ៖<br>- វិស័យនីមួយៗ<br>- តំបន់ភូមិសាស្ត្រនានា។<br>គួរមានផែនទីទីតាំងធ្វើអន្តរាគមន៍ដើម្បីដឹងពីគម្លាត និងការជាន់គ្នា។ |

[១] បទដ្ឋានរបស់ Sphere បានណែនាំថា ត្រូវមានកន្លែងទំហំ៣.៥ម$^{២}$ និងទឹក១៥លីត្រសម្រាប់ជម្រករបស់មនុស្សម្នាក់

[២] បទដ្ឋានរបស់ Sphere បានណែនាំថា ត្រូវមានបង្គន់អនាម័យ០១ សម្រាប់មនុស្ស២០នាក់

[៣] បទដ្ឋានរបស់ Sphere បានណែនាំថា ត្រូវមានទឹក១៥លីត្រក្នុង០១ថ្ងៃសម្រាប់មនុស្សម្នាក់

# ២. ការថែទាំកុមារជាមួយគ្រួសារ និងយន្តការគាំទ្រសហគមន៍ តួនាទីរបស់ គ.ក.ស.ក

នៅឆ្នាំ២០១១ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយយូនីសេហ្វ បានធ្វើការសិក្សាពីឥរិយាបថរបស់កុមារដែលរស់នៅក្នុងមណ្ឌលថែទាំ។ ការសិក្សានេះបានរកឃើញថា ចំនួនកុមារដែលរស់នៅមណ្ឌលថែទាំបានបន្តកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

ករណីសិក្សានេះកំណត់បាននូវមូលហេតុពីរ ដែលជាហេតុធ្វើឲ្យមានចំនួនកុមារកាន់តែច្រើនឡើងៗ ត្រូវយកទៅថែទាំនៅមណ្ឌលថែទាំ។ មូលហេតុទី១គឺ គ្រួសារខ្លះមិនមានលទ្ធភាពថែរក្សាកូនៗរបស់ខ្លួនបាន ដោយសារតែភាពក្រីក្រ។ មូលហេតុទី២ គឺគ្រួសារខ្លះជឿថាការឲ្យកូនៗរបស់ខ្លួនទៅនៅក្នុងមណ្ឌលថែទាំ កូននឹងមានឱកាសល្អជាងនៅជាមួយគាត់។ ទោះយ៉ាងណាក៏ដោយនេះមិនមែនជាករណីដែលត្រឹមត្រូវទេ។ តាមការស្រាវជ្រាវនៅប្រទេសកម្ពុជា និងប្រទេសផ្សេងៗ ទៀតបានបង្ហាញថា ៖

- ការថែរក្សាកុមារនៅក្នុងមណ្ឌលថែទាំអាចនាំឱ្យមានផលជះជាអវិជ្ជមានចំពោះការអភិវឌ្ឍកុមារ រួមមាន ៖ ការអភិវឌ្ឍសង្គម កាយសម្បទា ប្រាជ្ញា និងអារម្មណ៍ ដែលផលជះនេះនឹងនៅជាមួយពួកគាត់រហូតដល់ធំ។ ការស្រាវជ្រាវបានបង្ហាញថា កុមារដែលបានទទួល ការចិញ្ចឹមបីបាច់នៅមណ្ឌលថែទាំអាចទទួលរងទុក្ខពីភាពយឺតយ៉ាវនៃការអភិវឌ្ឍខួរក្បាល ក្រចេះនិយាយ និងភាពយឺតយ៉ាវនៃការលូតលាស់ ផ្នែកកាយសម្បទា ងាយឆ្លងជម្ងឺ និងអាកប្បកិរិយាមិនមានរបៀប និងអាម្មណ៍មិនមានសុវត្ថិភាព។
- ការផ្លាស់ប្តូរអ្នកថែទាំជាញឹកញាប់អាចបង្ករជាផលជះជាអវិជ្ជមានដល់កុមារ ដោយសារតែកុមារត្រូវ ព្យាយាមក្នុងការបង្កើតចំណងអារម្មណ៍ជាមួយអ្នកថែទាំដែលត្រូវផ្លាស់ប្តូរហើយម្តងទៀត។ ក្នុងការកសាងឱ្យមានភាព ប្រក្រតីកុមារទាមទារឱ្យភ្ជាប់ចំណងរឹងមាំ ជាមួយអ្នកថែទាំដែលពួកគាត់ នៅបង្កើតឡើងតាំងពីនៅក្នុងផ្ទៃ និងបន្តជីវិតជាកុមារភាពរបស់គាត់។
- មណ្ឌលថែទាំកុមារមានហានិភ័យខ្ពស់ក្នុងការរំលោភបំពានទាំងផ្លូវកាយ និងផ្លូវភេទ។ កុមារភាគច្រើនរងទុក្ខដោយសារតែមិនបានទទួលការយកចិត្តទុកដាក់លើផ្នែកកាយសម្បទា និងអារម្មណ៍ ឬដោយសារត្រូវគេសំឡុត និងត្រូវគេប្រើអំពើហឹង្សាលើ(ដោយអ្នកថែទាំ អ្នកមកសួរសុខទុក្ខ និងកុមារផ្សេងៗទៀត)។
- ជាញឹកញាប់កុមារដែលរស់នៅក្នុងមណ្ឌលថែទាំ ក្នុងរយៈពេលវែងជួបប្រទះនូវការលំបាកក្នុងការសម្របខ្លួនទៅក្នុងសហគមន៍វិញនៅពេលដែលពួកគេចេញពីមណ្ឌលថែទាំ។ ជាញឹកញាប់ពួកគេមិនអាចធ្វើអ្វីបាន ដោយឯករាជ្យ ពួកគេអាចនឹងប្រឈមនឹងការរើសអើងនៅក្នុងសហគមន៍ ជាពិសេសពួកគេខ្វះជំនាញសង្គម ដែលជួយពួកគេឱ្យសម្របខ្លួនបានក្នុងការប្រើប្រាស់ជីវិតសហគមន៍របស់ពួកគេ។
- កម្ពុជាមានការថែទាំជាប្រពៃណីដ៏យូរអង្វែងសម្រាប់កុមារដែលងាយរងគ្រោះ តាមរយៈសហគមន៍ និងការថែទាំកុមារជាមួយគ្រួសារដែលមានសមាជិកច្រើន ហើយនេះជាកន្លែងអាទិភាពដែលកុមារកំព្រារស់នៅបច្ចុប្បន្ននេះ។ ការកើនឡើងយ៉ាងឆាប់រហ័សនៃមណ្ឌលថែទាំនាំឱ្យមានការសឹករិចរិលនៃប្រព័ន្ធថែទាំក្មេងឱ្យនៅជាមួយគ្រួសារ ព្រមទាំងទុកឱ្យកុមារប្រឈមនឹងហានិភ័យខ្ពស់។
- នៅក្នុងប្រទេសកម្ពុជាមណ្ឌលថែទាំខ្លះប្រឈមនឹងបញ្ហាខ្វះខាតថវិកា។ នេះមានន័យថាកុមារអាចខ្វះខាតអាហារ និងការអប់រំ។ ការរស់នៅក្នុងលក្ខ័ណ្ឌបែបនេះមិនមែនជាការគួរឱ្យពេញចិត្តនោះទេ។ ការខ្វះខាត ថវិកាអាចនាំឱ្យ

មានការប្រើប្រាស់ពលកម្មកុមារដូចជា ការបង្ខំកុមារឱ្យទៅនេសាទ ធ្វើស្រែ និងចំការ ឬទៅ សម្តែងរបាំបុរាណជូនអ្នកទេសចរទស្សនា ដើម្បីប្រមែប្រមូលថវិកា។ នេះក៏អាចជាហេតុក្នុងការដាក់កុមារនៅក្នុងស្ថានភាពគ្រោះថ្នាក់ ដូចជាការរៃអង្គាសប្រាក់សម្រាប់មណ្ឌលថែទាំកុមារនៅពេលយប់។

មណ្ឌលថែទាំធ្វើឱ្យកុមារមានហានិភ័យពីការរំលោភបំពានរាងកាយ និងផ្លូវភេទ។ កម្ពុជាមានប្រពៃណីថែរក្សាក្មេងដែលងាយរងគ្រោះ តាមរយៈការថែទាំដោយញាតិសន្តាន ហើយកុមារកំព្រាភាគច្រើននៅប្រទេសកម្ពុជារស់នៅជាមួយគ្រួសារដែលមានគ្នាច្រើន។ ការថែទាំជាមូលដ្ឋាននៅក្នុងសហគមន៍ អាចឲ្យកុមាររីកធំធាត់នៅក្នុងបរិស្ថានជាលក្ខណៈគ្រួសារ និងដោយវប្បធម៌របស់ពួកគេផ្ទាល់។ ការថែទាំកុមារនៅក្នុងបរិស្ថានល្អអាចធ្វើឲ្យពួកគេក្លាយជាសមាជិកពេញលេញរបស់សង្គមនៅពេលដែលពួកគេធំឡើង។ លើសពីនេះទៀត ការថែទាំនៅក្នុងសហគមន៍ អាចចំណាយតិចជាងការថែទាំពួកគេនៅមណ្ឌលថែទាំឆ្ងាយណាស់។ ផ្អែកតាមមូលហេតុទាំងនេះ ការដាក់កុមារឲ្យរស់នៅក្នុងមណ្ឌលថែទាំ គួរតែជាជម្រើស និងជាដំណោះស្រាយចុងក្រោយបំផុត។ គោលការណ៍នេះ មិនទាន់មានការយល់ដឹងទូលំទូលាយក្នុងផ្នត់គំនិតរបស់ប្រជាជនកម្ពុជានៅឡើយ។

យោងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ(ខែមិថុនា ឆ្នាំ២០១១) របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា ករណីទុកដាក់កុមារតាមការថែទាំជំនួសទាំងអស់ គឺជាការថែទាំបណ្តោះអាសន្នលើកលែងតែការទុកដាក់កុមារជាមួយគ្រួសារអចិន្ត្រៃយ៍។ បន្ទាប់ពីបានខិតខំប្រឹងប្រែងធ្វើការបង្រួបបង្រួមគ្រួសាររអស់លទ្ធភាព ការទុកដាក់តាមការថែទាំជំនួសបណ្តោះអាសន្នចំពោះកុមារត្រូវអនុវត្តតាមលំដាប់លំដោយជាអាទិភាព ដូចខាងក្រោម ៖

ក. ការទុកដាក់ជាមួយញាតិ

ខ. ការទុកដាក់ជាមួយគ្រួសារចិញ្ចឹមនៅក្នុងសហគមន៍

គ. ការទុកដាក់តាមរបៀបថែទាំនៅក្នុងសហគមន៍ ដូចជា ការថែទាំជាក្រុម និងការថែទាំតាមវត្ត (គ្រួសារនៅក្នុងសហគមន៍តែមួយ ហើយកុមារអាចទៅជួបឪពុកម្តាយជាទៀងទាត់)

### *តួនាទីអ្វីខ្លះដែល គ.ក.ន.ក អាចធ្វើបាន ដើម្បីលើកកម្ពស់ការថែទាំកុមារនៅជាមួយក្រុមគ្រួសារ?*

ខាងក្រោមនេះជាសកម្មភាពមួយចំនួនដែល គ.ក.ន.ក អាចធ្វើបាន ៖

- ប្រើប្រាស់ព័ត៌មាន និងសារគន្លឹះនៅក្នុងប័ណ្ណព័ត៌មានពិត (សូមមើលឯកសារបណ្តុះបណ្តាល) ដើម្បីផ្សព្វផ្សាយឲ្យមានការយល់ដឹងដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សហគមន៍ និងក្រុម គ្រួសារពីផលប៉ះពាល់ជាអវិជ្ជមានពីការរក្សាកុមារនៅមណ្ឌលថែទាំ និងសារៈប្រយោជន៍ដែលកុមាររីកលូតលាស់ជាមួយគ្រួសារ និងសហគមន៍របស់ពួកគេ
- ប្រសិនបើកុមារមិនត្រូវបានថែទាំឲ្យសមរម្យនៅក្នុងបរិស្ថានគ្រួសារត្រឹមត្រូវទេ ត្រូវយកកុមារទៅទទួលសេវាសង្គមដែលសមរម្យមួយដោយសហការជាមួយការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក
- ក្នុងករណីកុមារកំពុងស្ថិតក្នុងសភាពគ្រោះថ្នាក់ (ដូចជាកុមារដែលត្រូវគេបោះបង់)វិធានការបន្ទាន់គឺ គ.ក.ន.ក ត្រូវសហការជិតស្និទ្ធជាមួយអាជ្ញាធរពាក់ព័ន្ធ និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន

និងយុវនីតិសម្បទាស្រុក ដើម្បីរៀបចំការថែទាំកុមារនៅសហគមន៍ជាបណ្តោះអាសន្ន រួមមាន ការរក្សាកុមារឲ្យនៅជាមួយក្រុមគ្រួសារជាមួយសាច់ញាតិ ឬការថែទាំជាកូនធម៌

- កិច្ចសហប្រតិបត្តិការជាមួយការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលនានា ក្នុងការជួយគាំទ្រកុមារដែលបានចាកឆ្ងាយពីគ្រួសារទៅរស់នៅក្នុងមណ្ឌលថែទាំ ឲ្យសម្របខ្លួនមកនៅជាមួយគ្រួសារ និងសហគមន៍វិញ។ កិច្ចការនេះរួមមាន ការធ្វើការប៉ាន់ប្រមាណពីការត្រៀមខ្លួនរួចរាល់របស់ក្រុមគ្រួសារសម្រាប់ការវិលត្រឡប់របស់កុមារ ត្រៀមធនធានដើម្បីឆ្លើយតបតាមតម្រូវការរបស់គ្រួសារ និងការចុះសួរសុខទុក្ខក្រុមគ្រួសារដែលកូនៗ របស់ពួកគាត់ទើបតែបានវិលត្រឡប់ចូលក្នុងក្រុមគ្រួសារវិញ
- ក្នុងករណីគ្រួសារងាយរងគ្រោះ ត្រូវគាំទ្រគ្រួសារនោះក្នុងការរៀបចំសេចក្តីព្រាងផែនការសេវាសង្គម ធ្វើយ៉ាងណាឲ្យពួកគេងាយស្រួលទទួលបានសេវាសង្គម និងកម្មវិធីរបស់មូលដ្ឋានផ្សេងៗទៀត ដើម្បីធានាក្នុងការការពារកុមារដោយមិនចាំបាច់ឲ្យពួកគេឃ្លាតឆ្ងាយពីក្រុមគ្រួសារឡើយ
- ពង្រឹងបណ្តាញនានាជាមួយសេវាគាំទ្រនៅមូលដ្ឋាន ដូចជា អង្គការមិនមែនរដ្ឋាភិបាល វត្តអារាម និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីអាចជួយគាំទ្រក្រុមគ្រួសារកុមារមុនពេលមានការបំបែកកុមារពីគ្រួសារកើតឡើង
- ស្វែងរកមតិគាំទ្រសម្រាប់មេភូមិ ដើម្បីលើកទឹកចិត្ត និងគាំទ្រមាតាបិតាក្នុងការថែទាំកូនៗ របស់ខ្លួននៅផ្ទះ ជាជាងបញ្ជូនកូនគាត់ទៅនៅក្នុងមណ្ឌលថែទាំ
- ប្រើប្រាស់សៀវភៅអាសយដ្ឋានសេវាកម្មសម្រាប់អ្នកដែលរងគ្រោះ សម្រាប់ស្វែរកលទ្ធភាពគាំទ្រដល់គ្រួសារដែលងាយរងគ្រោះ និងជម្រើសនានា ជាជាងដាក់កុមារនៅមណ្ឌលថែទាំ
- ប្រើប្រាស់មូលនិធិសង្គមការពារកុមារដើម្បីគាំទ្រពីតម្រូវការរបស់កុមារងាយរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ
- ប្រមូល និងវិភាគព័ត៌មានពីកុមារដែលងាយរងគ្រោះនៅក្នុងឃុំរបស់ខ្លួន និងធានាថាបញ្ហារបស់កុមារត្រូវបានយកមកឆ្លុះបញ្ចាំងនៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។

# ៣. ការប្រើប្រាស់ទិន្នន័យដើម្បីមានឥទ្ធិពលលើអ្នកដទៃ

តួនាទីសំខាន់បំផុតរបស់ គ.ក.ន.ក គឺកំណត់រកគ្រួសារដែលងាយរងគ្រោះបំផុតនៅក្នុងឃុំ សង្កាត់ វិភាគ និងរកមើលអ្វីដែលនៅបង្កប់ពីក្រោយបញ្ហា និងរៀបចំការផ្តល់សេវាសង្គម។ តាមរយៈ ការវិភាគបញ្ហាដែលរួមចំណែកទៅដល់ភាពងាយរងគ្រោះរបស់ស្ត្រី និងកុមារ គ.ក.ន.ក អាចយល់ដឹងយ៉ាងច្បាស់ពីតម្រូវការ និងអាចស្នើសុំអន្តរាគមន៍ដើម្បីស្វែងរកដំណោះស្រាយក្នុងមូលដ្ឋានចំពោះការព្រួយបារម្ភមួយចំនួន។ គ.ក.ន.ក ត្រូវធ្វើការតស៊ូមតិជំនួសមុខឲ្យស្ត្រី និងកុមារងាយរងគ្រោះទាំងឡាយ ដើម្បីកៀរគរធនធានពីអ្នកពាក់ព័ន្ធផ្សេងៗ ដែលអាចរួមជាកម្លាំងក្នុងការនាំឲ្យមានការផ្លាស់ប្តូរនៅមូលដ្ឋាន។

## ៣.១. ការកំណត់គ្រួសារងាយរងគ្រោះ

ខាងក្រោមនេះជាសំណួរពាក់ព័ន្ធមួយចំនួនដែលអាចប្រើប្រាស់នៅពេលធ្វើការកំណត់គ្រួសារដែលងាយរងគ្រោះបំផុត ៖

- តើនរណាខ្លះដែលងាយរងគ្រោះជាងគេ? តើទិន្នន័យអ្វីខ្លះដែលអ្នកមានក្នុងដៃ? (អ្នកអាចប្រើប្រាស់ទិន្នន័យដែលអាចប្រើប្រាស់បាននៅក្នុងផែនទីសេវាសង្គម ប័ណ្ណពិន្ទុគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ប្រព័ន្ធព័ត៌មានសុខភាព និងសៀវភៅទិន្នន័យឃុំសង្កាត់)
- តើបញ្ហាអ្វីខ្លះដែលស្ត្រី និងកុមារកំពុងជួបប្រទះ?
- តើអ្វីជាឫសគល់នៃបញ្ហាទាំងនេះ និងអ្វីខ្លះជាផលប៉ះពាល់នៃបញ្ហាទាំងនេះ?
- តើអ្នកអាចដោះស្រាយបញ្ហានេះបានតាមរបៀបណា? (លើកឡើងនូវសកម្មភាពមួយចំនួន ដើម្បីដោះស្រាយបញ្ហាទាំងនោះ)
- តើនរណាខ្លះត្រូវបានចូលរួមពាក់ព័ន្ធជួយឲ្យមានការប្រាស្រ័យទាក់ទងកើតឡើង?
- តើនរណាខ្លះអាចចូលរួមវិភាគទាន?
- តើនរណាអាចនាំឲ្យមានការផ្លាស់ប្តូរបាន?

| គ្រួសារងាយរងគ្រោះ និងបញ្ហាដែលជះឥទ្ធិពលដល់ស្ត្រី និងកុមារ | មូលហេតុជាមូលដ្ឋានដែលរួមចំណែកដល់បញ្ហា | តើត្រូវធ្វើអ្វីដើម្បីដោះស្រាយបញ្ហា? | តើមាននរណាទៀតដែលត្រូវចូលរួមដោះស្រាយ? ដោយវិធីណា? |
|---|---|---|---|
| | | | |

## ៣.២. ការវិភាគអ្នកពាក់ព័ន្ធ

- តើអ្នកកំពុងយកចិត្តទុកដាក់លើបញ្ហាអ្វីខ្លះ?
- តើនរណាខ្លះជាអ្នកពាក់ព័ន្ធនៅក្នុងការកសាងបណ្ដាញ (ដែលអ្នកទាំងនោះអាចផ្ដល់នូវការគាំទ្រ និងធនធានផ្សេងៗផងដែរនោះ)? តើនរណាដែលមិនអាចគាំទ្រនូវរាល់សកម្មភាពដែលស្នើឡើង?
- តើអ្វីខ្លះដែលអ្នកអាចសង្ឃឹមពីអ្នកពាក់ព័ន្ធផ្សេងៗដែលអ្នកបានកំណត់ហើយ?
- តើអ្នកធ្វើការប្រាស្រ័យទាក់ទងជាមួយពួកគេតាមរបៀបណា?

## ៣.៣. ការតស៊ូមតិដើម្បីសេវាសង្គមប្រកបដោយសមធម៌

មានមូលហេតុជាច្រើនដែលតម្រូវឲ្យ គ.ក.ន.ក ធ្វើការស្វែងរកមតិគាំទ្រ។ នៅក្នុងការអនុវត្តការងាររបស់លោកអ្នក លោកអ្នកនឹងប្រឈមមុខជាមួយនឹងបញ្ហានៃភាពក្រីក្រ និងបញ្ហាសង្គមជាច្រើនទៀតដែលជះឥទ្ធិពលដល់ស្ត្រី និងកុមារ ហើយដែលលោកអ្នកប្រហែលជាចង់ឲ្យមានការផ្លាស់ប្ដូរ។ ការតស៊ូមតិត្រូវធ្វើចេញពីបេះដូងក្នុងការប្រឹងប្រែងដោះស្រាយបញ្ហាលំបាកៗ ឬបញ្ហាមិនយុត្តិធម៌មួយចំនួន។ ការតស៊ូមតិមានគោលដៅស្វែងរកបញ្ហាពីខាងក្រោយ ព្រមទាំងធ្វើការផ្លាស់ប្ដូរមូលហេតុនៃបញ្ហានោះ និងឫសគល់មានលក្ខណៈជាប្រព័ន្ធនៃបញ្ហាក្នុងសង្គម។

ឧទាហរណ៍ កុមារម្នាក់កំពុងតែធ្លាក់ចូលទៅក្នុងទឹកជ្រៅ មានមនុស្សជាច្រើនរត់ទៅជួយកុមារនោះ ប៉ុន្តែការពិតពួកគេគ្រាន់តែទៅមើលឲ្យឃើញថាមានកុមារប៉ុន្មាននាក់ដែលកំពុងលង់ទឹក។ តើអ្នកព្យាយាមសង្គ្រោះកុមារដែលធ្លាក់ទឹក ឬក៏គ្រាន់តែទៅរកមូលហេតុដែលធ្វើឲ្យកុមារធ្លាក់ទឹក ហើយចាត់វិធានការដោះស្រាយសម្រាប់ពេលអនាគត ដើម្បីការពារកុមារកុំឲ្យកុមារធ្លាក់ទឹកទៀត?

### ៣.៣.១. តើអ្វីជាការតស៊ូមតិ?

ការតស៊ូមតិមានន័យថា ជាការនិយាយចេញមកសម្រាប់អ្នកណាម្នាក់ ឬគាំទ្រនរណាម្នាក់ឲ្យ និយាយឡើងសម្រាប់ខ្លួនគេ។ ការតស៊ូមតិ គឺសំដៅទៅដល់ការជួយនរណាម្នាក់ឲ្យសំឡេងរបស់គាត់ត្រូវបានគេស្ដាប់ឮ។ មនុស្សជាច្រើនអាចធ្វើជាអ្នកតស៊ូមតិ និងប្រើប្រាស់ការតស៊ូមតិជារៀងរាល់ថ្ងៃ។ ជាឧទាហរណ៍ សមាជិក គ.ក.ន.ក ស្ដាប់តម្រូវការស្ត្រី និងកុមារ មាតាបិតាស្ដាប់បំណងប្រាថ្នារបស់កូន អ្នកគ្រប់គ្រងឆ្លើយតបទៅគំនិត ឬទស្សនៈរបស់បុគ្គលិក មិត្តភក្ដិគាំទ្រគ្នាទៅវិញទៅមក។ ការតស៊ូមតិទាំងនេះ ភាគច្រើនជាការតស៊ូមតិមិនផ្លូវការ ហើយក៏ជាផ្នែកមួយនៃជីវភាពប្រចាំថ្ងៃដែរ។ ប៉ុន្តែនៅពេលខ្លះ ការតស៊ូមតិក៏ត្រូវធ្វើឡើងតាមបែបផ្លូវការផងដែរ ដែលការតស៊ូមតិរបៀបនេះ ភាគច្រើនបង្ហាញពីការចង់ឲ្យមានកែប្រែគោលនយោបាយ និងច្បាប់ជាដើម។

ចំពោះ គ.ក.ន.ក ការតស៊ូមតិ គឺជាឧបករណ៍ដើម្បីធានាថាស្ត្រី ឬកុមារ និងជនដែលងាយរងគ្រោះនៅក្នុងសហគមន៍ ដែលជាទូទៅគឺជាអ្នកដែលបាត់ប្រៀប មានមធ្យោបាយយល់ដឹងអំពីអ្វីមួយ ឬទទួលបាននូវឱកាសក្នុងការទទួលបានសេវាសាធារណៈនានា។ ការតស៊ូមតិ គឺ ៖

- ដើម្បីជួយឲ្យមនុស្សគ្រប់គ្នាមានសំឡេង និងធានាថាពួកគាត់មិនត្រូវបានគេបដិសេធដោយសារតែពួកគេមិនអាចបង្ហាញពីទស្សនៈរបស់ខ្លួនឱ្យអ្នកដទៃបានយល់ឡើយ
- ជាការធ្វើសកម្មភាពដើម្បីជួយឲ្យប្រជាពលរដ្ឋនិយាយពីអ្វីដែលពួកគាត់ចង់និយាយ ដើម្បីធានាបាននូវសិទ្ធិរបស់ពួកគេ ដើម្បីបង្ហាញពីផលប្រយោជន៍របស់ពួកគេ និងដើម្បីទទួលបានសេវាដែលពួកគេត្រូវការ
- ជាការជួយលើកកម្ពស់សេវាសង្គមប្រកបដោយសមធម៌ និងយុត្តិធម៌សង្គម
- ជាការប្រកួតប្រជែងនឹងការបដិសេធ និងការរើសអើងក្នុងសង្គម។

ការតស៊ូមតិទាក់ទងនឹងសកម្មភាពជាច្រើន រួមមាន ការត្រួតពិនិត្យ និងការរាយការណ៍អំពីសកម្មភាពនានា ការលើកកម្ពស់ការយល់ដឹង ការកៀរគរអ្នកភូមិឲ្យចូលរួមប្រជុំ ការសម្របសម្រួលកិច្ចប្រជុំ ការរៀបចំវគ្គបណ្តុះបណ្តាល ការពិភាក្សាជាមួយមនុស្សមានឥទ្ធិពល ការបង្រួបបង្រួមដៃគូដែលមានចិត្តគំនិតដូចគ្នា ការចូលរួមវេទិកាពិភាក្សា តាមវិទ្យុ និងទូរទស្សន៍ ការសរសេរប្រកាសព័ត៌មាន និងការសរសេរអត្ថបទកាសែតជាដើម។

### ៣.៣.២. មូលដ្ឋានគ្រឹះនៃការតស៊ូមតិ

| | |
|---|---|
| ការតស៊ូមតិគឺពាក់ព័ន្ធនឹងឥទ្ធិពលនៃជំនឿ ការគិត និងទង្វើរបស់អ្នកដទៃ ដែលអាចធ្វើឲ្យមានការផ្លាស់ប្តូរទៅតាមផ្លូវដែលអ្នកចង់បាន។<br>ការតស៊ូមតិទំនងជាមានឱកាសជោគជ័យនៅពេលដែល ៖<br>• អ្នកចេះប្រើទិន្នន័យដើម្បីគាំទ្រហេតុផលនៃការផ្លាស់ប្តូរ<br>• នៅពេលមានមនុស្សច្រើនចូលរួម<br>• ការខិតខំតស៊ូមតិត្រូវបានរៀបចំផែនការដោយការប្រុងប្រយ័ត្ន | កម្មវិធីការតស៊ូមតិប្រកបដោយប្រសិទ្ធភាពនឹងទទួលបានចម្លើយតាមសំណួរដូចខាងក្រោម ៖<br>• តើអ្វីដែលអ្នកចង់ផ្លាស់ប្តូរ? ហេតុអ្វី?<br>• តើសកម្មភាពអ្វីខ្លះដែលត្រូវធ្វើដើម្បីទទួលបានការផ្លាស់ប្តូរ?<br>• តើអ្នកណាដែលអាចជួយអ្នកដើម្បីឲ្យមានការផ្លាស់ប្តូរ?<br>• តើអ្នកនឹងប្រើនូវវិធីសាស្ត្រអ្វីខ្លះ?<br>• តើនរណានឹងត្រូវធ្វើអ្វី? នៅពេលណា?<br>• តើយុទ្ធសាស្ត្ររបស់អ្នកមានប្រសិទ្ធភាពឬទេ? កន្លែងណាដែលអ្នកត្រូវការសម្របខ្លួន? |

### ៣.៣.៣. វដ្តនៃការតស៊ូមតិ

អ្នកអាចប្រើវដ្តដែលមានចំនួន៦ជំហាន ជាមូលដ្ឋានដើម្បីរៀបចំផែនការ និងអនុវត្តសកម្មភាពតស៊ូមតិគ្រប់ប្រភេទ ដោយចាប់ផ្តើមពីការកំណត់រកបញ្ហាចម្បងៗដែលជះឥទ្ធិពលដល់ស្ត្រី និងកុមារ ដូចជា ៖

១. កំណត់រកបញ្ហាចម្បងៗ តាមរយៈការសួរសំណួរថា ហេតុអ្វីបានជាលោកអ្នក និងអ្នកផ្សេងទៀតព្យាយាមចង់ឲ្យមានការផ្លាស់ប្តូរ? តើស្ថានភាពអាចមានការផ្លាស់ប្តូរដោយសារការតស៊ូមតិឬទេ?

២. ប្រមូលទិន្នន័យដើម្បីកំណត់ពីបញ្ហាចម្បងៗ និងបញ្ហាពាក់ព័ន្ធនានា ព្រមទាំងកំណត់រកមូលហេតុនៃបញ្ហាទាំងនោះ លើកជាដំណោះស្រាយសមស្រប កំណត់រកអ្នកពាក់ព័ន្ធនានាឲ្យចូលរួម និងដើម្បីវិភាគអំពីហានិភ័យ និងសមត្ថភាព។

៣. យល់ស្របចំពោះបំណងនៃការផ្លាស់ប្តូរ និងសូចនាករដើម្បីទទួលបានជោគជ័យ (កំណត់ភាពជោគជ័យ)
៤. រៀបចំផែនការសកម្មភាព (សកម្មភាពអ្វីខ្លះ? អ្នកណាខ្លះ? នៅពេលណា?)
៥. អនុវត្តផែនការសកម្មភាព
៦. វាយតម្លៃលទ្ធផល (អ្វីដែលដំណើរការល្អ? អ្វីដែលអ្នកនឹងត្រូវធ្វើបែបផ្សេងពីនេះនៅពេលក្រោយ?)